## មាតិការឿង

១. បទសម្ភាសន៍លោក ខៀវ សំផន.............. ០៣
២.សង្គមស៊ីវិល, ស្ដាប់សៀមនិយាយ............ ០៤
៣.វិចារណកថា............................................ ០៥
៤.មតិពលរដ្ឋខ្មែរជុំវិញការចរចា.................... ០៦
៥.ខ្មែរចុះទឹកក្រពើ..., សុខភាព.................. ០៧
៧.កម្ពុជាក្នុងប្រវត្តិកីឡាអូឡាំពិក.................. ១០
៦.ទីក្រុងដែលសំបូរដោយអំពើហឹង្សា.............. ១៤



# ខ្មែរប៉ុស្តិ៍ The khmer Post



ទូរស័ព្ទពាណិជ្ជកម្មខ្មែរប៉ុស្តិ៍ ហ្វីឡាដែលហ្វីយ៉ា

❖សុបិន : (២៦៧) ២៥៣-៣៩៤៧
❖ទូរស័ព្ទ នៅរ៉ូដអាយឡិន
❖សេរី : (៤០១) ៩១៩-៩៩៥៤
ទូរស័ព្ទវិទ្យុសម្លេងខ្មែរអាមេរិកាំង
❖ស៊ីជន : (២១៥) ២៨៤-១៣៤៣
Email : khmerpostec@gmail.com



KHMER BILINGUAL BIWEEKLY NEWSPAPER

VOLUME 02 ISSUE 21 August 23th-09th 2008 ADVERTISING (267) 253-3947 WWW.THEKHMERPOST.COM


## ស្លាប់ លោកឯកអគ្គរាជទូត ខ្មែរ ប្រចាំ អ.ស.ប



ខ្មែរប៉ុស្តិ៍

•••លោក សៀក កុសល ឯកអគ្គរដ្ឋទូតប្រចាំ អ.ស.ប បាននិយាយ នាឱកាសរាត្រីសមោលស (តទៅទំព័រទី០៨)

## គេចខ្លួនចុះចាញ់ដោយសុវត្ថិភាព FUGITIVE SAFE SURRENDER




•••ឱកាសដ៏ល្អមួយសំរាប់អ្នកដែលគេចខ្លួនពីសំណាញ់តុលាការ បានបើកឱ្យមានការចូលខ្លួនចុះចាញ់ ដោយមានការលើកទោសជូនដល់អ្នកជាប់ពិរុទ្ធមួយចំនួន ។

ពីថ្ងៃទី១៧ ដល់ ២០កញ្ញា នៅវិហារ Trve Gospel Tapenado ពីម៉ោង៨ព្រឹកដល់ ៥ល្ងាច 1606 MIFFLIN Street Philadelphia.

កាលើកទោសដោយបណ្ដាញតុលាការ និងប៉ូលិសហ្វីឡា-ដែលហ្វីយ៉ា អាចធ្វើទៅចំពោះឧក្រិដ្ឋកម្មដោយគ្មានហឹង្សា មានប្រវត្តិ ដែលគ្មានប្រព្រឹត្តហឹងសាពីមុខមក និងហ៊ានទទួលខុសត្រូវលើអ្វីដែលខ្លួនបានធ្វើពីអតីតកាល ។

អ្នកដែលមានទោសក្នុងលក្ខខណ្ឌខាងលើ អាចទូរស័ព្ទទៅ REVERREND Dr.ERNEST Mc NEAR លេខ 215-686 7233.

## អតីតមេគុកទួលស្លែងនឹងត្រូវឡើង សវនាការសាលាដំបូង



*ភ្នំពេញ, ខ្មែរប៉ុស្តិ៍ : ចាន់ កុសល*

•••កាំង ហ្គេចអ៊ាវ ហៅ ឌុច អតីតមេគុកទួលស្លែង ដ៏សាហាវឃោរឃៅ ដែលបានរៀបចំផែនការសំលាប់ពលរដ្ឋខ្មែរក្នុងឆ្នាំ ១៩៧០-១៩៧៥ ហើយត្រូវបានអាជ្ញាធរចាប់ខ្លួនបញ្ជូនទៅអង្គជំនុំជំរះវិសាមញ្ញក្នុងតុលាការកម្ពុជា ហៅសាលាក្ដីខ្មែរក្រហមពេលនេះត្រូវសហចៅក្រមស៊ើបអង្កេតឃើញមានភស្តុតាងជាច្រើន រួចបញ្ជូនសំនុំរឿងឱ្យសហចៅក្រមសាលាក្ដីខ្មែរក្រហម (តទៅទំព័រទី១៧)

# សហរដ្ឋអាមេរិក មានគូរប្រជែងក្នុង តំណែងប្រធានាធិបតី ឆ្នាំ២០០៨



បារ៉ាក់ អូបាម៉ា និង ជោ បាយដិន



ចន ម៉ាកេន និងសារ៉ា ប៉ាលីន

•••សន្និបាទគណបក្សប្រជាធិបតេយ្យ បានតែងតាំង :

- បារ៉ាក់ អូបាម៉ា ជាបេក្ខជនប្រធានាធិបតី ស្បែកខ្មៅដំបូងបង្អស់ ។
- ជោ បាយដិន បេក្ខជនអនុប្រជានាធិបតី

រីឯសន្និបាទគណបក្សសាធារណរដ្ឋ វិញបាន ជ្រើសរើសយក ។

- ចន ម៉ាកេន ជាបេក្ខជនប្រធា នាធិបតី
- សារ៉ា ប៉ាលីន ស្ត្រីភេទដំបូងបង្អស់ ជាបេក្ខជនអនុប្រធានាធិបតី ។

**ការស្ទង់មតិ** : អូបាម៉ា បាន ៤៥% ម៉ាកេន បាន ៤៨% GAL-LVP (9/៤-៩/៦/B).

សមាសភាពនេះ បានធ្វើឱ្យគេឃើញថា គណបក្សប្រជាធិបតេយ្យ បានចំណាយលុយរាប់រយលានដុល្លារ សំរាប់លើកដំកើងការបោះឆ្នោតឱ្យស្ត្រីភេទជា មគ្គទេសនៃសហរដ្ឋអាមេរិក នារយៈពេល២ឆ្នាំចុងក្រោយនេះ តែចុងបញ្ចប់បែរជាគណបក្សសាធារណរដ្ឋ ទៅវិញទេ ដែលមានបេក្ខនារី សម្រាប់ឱ្យប្រជាពលរដ្ឋបោះឆ្នោតឱ្យទៅវិញ ។

គណបក្សជាគូរប្រឆាំងគ្នាទាំងពីរនេះ មានគោលការណ៍ធំៗខុសគ្នាដូចជាគណបក្សសាធារណរដ្ឋ គិតគូពីទំនាក់ទំនងក្រៅប្រទេសច្រើនជាងគណបក្សប្រជាធិបតេយ្យ ដែលគិតពីបញ្ហាសុខមាភាព និងសេដ្ឋកិច្ចក្នុងប្រទេសជាការសំខាន់ជាង ។ គណបក្សសាធារណរដ្ឋប្រកាន់នយោបាយអភិរក្សនយោបាយសម្រាប់សង្គម រីឯគណបក្សប្រជាធិបតេយ្យ ប្រកាន់យកលក្ខណៈសេរីនិយមច្រើនជាង ។ល។

បញ្ហាដែលការឃោសនានាឱកាសដំបូងរបស់ បេក្ខជនទាំង៤រូបនេះ គឺលោក ចន ម៉ាកេន ស្ថិតនៅជិតនយោបាយសង្គ្រាមក្រៅប្រទេសជិតលោកប្រធានាធិបតីបច្ចុប្បន្ន ជច ប៊ុស រីឯលោក បារ៉ាក់ អូបាម៉ា ចង់ផឱ្យមានការដកទ័ពអាមេរិកាំងចេញពីបរទេសជាប្រញាប់ ។ ការខុសគ្នាខ្លះៗទៀត នៅលើបញ្ហាកាត់យកលុយកាក់. បញ្ហាថាមពល ដែលកំពុងតែឡើងថ្លៃ និងពលរដ្ឋអាមេរិកាំង កាន់តែច្រើនធ្លាក់ចូលក្នុងជីវភាពក្រីក្រ អត់មានការងារធ្វើ និងបាត់បង់ផ្ទះសម្បែង ដែលនេះជាកំលាំងរបស់ អូបាម៉ា. បាយដិន រីឯខាង ម៉ាកេន-ប៉ាលិន វិញថ្លែងថា អូបាម៉ា គ្មានបទពិសោធន៏ខាងគ្រប់គ្រងប្រទេសទេ ។

## McCain Will Bring Back the Military Draft

In his convention speech, McCain did mention that neighbor on the border with Russia and how we have to press for its admission to NATO.

(តទៅទំព័រទី១២)

# ពលរដ្ឋខ្មែរប្រមាណ១០លាននាក់ រស់នៅមិនសូវមានអនាម័យល្អ

*ភ្នំពេញ, ខ្មែរប៉ុស្តិ៍ : ចាន់ កុសល*

•••ដោយសារតែភាពទីទល់ក្រ ការរៀនសូត្រ បានតិចតួច និងទំលាប់រស់នៅតាមបែបធម្មជាតិ តំណពីដូនតាខ្លួន គេសង្កេតឃើញពលរដ្ឋខ្មែរ ភាគច្រើននៅតែបន្ទបត់ជើងតូច-ធំតាមវាលស្រែ គុម្ពោតព្រៃដដែល ។

ទំលាប់នេះបានធ្វើឱ្យខាតបង់ពេលវេលា ប៉ះពាល់ដល់សុខភាព ធ្វើឱ្យអ្នកស្រុកកើតជំងឺញឹកញាប់ មានរាងកាយស្គមស្គាំង និងស្លាប់បាត់បង់ជីវិតជាបន្តបន្ទាប់ ។ បើតាមរបាយការណ៍ របស់ធនាគារពិភពលោកបានឱ្យដឹងថា ការចំណាយទៅលើអនាម័យសុខភាពក្នុង១ឆ្នាំៗ អស់ប្រហែល១.៥ពាន់លានដុល្លារ ។

ក្នុងនោះមនុស្សស្លាប់១១.០០០នាក់ ចុករាកចំនួន៩.៥លានករណីដែលកើតចេញពីការខ្វះអនាម័យ ហើយបើតាមទូរលេខ គឺមានប្រជាពលរដ្ឋប្រមាណ១០លាននាក់ ក្នុងចំណោម ជាង១៤លាននាក់ នៃប្រជាពលរដ្ឋសរុប (តទៅទំព័រទី១០)


សូមអញ្ជើញស្ដាប់វិទ្យុសម្លេងខ្មែរអាមេរិកាំង នៅ ហ្វីឡាដែលហ្វីយ៉ា AM1540 នៅរៀងរាល់ថ្ងៃសៅរ៍ ពីម៉ោង ៣ ដល់ ៤ រសៀល

# Cambodian-American Voters Conference

# កិច្ចប្រជុំអ្នកបោះឆ្នោត ខ្មែរ-អាមេរិកាំង

Are you concerned about your career, your child's education or your civil rights? If so, come and find out how you can:

**Get involved!**
**Be informed!**
**Make a difference!**
**Make your voice heard!**

## Conference Information

Date: Sunday, September 21, 2008
Time: 11:00 AM – 2:00 PM
Location: BCTGM Local 6
5416 Rising Sun Avenue
(Across from the Soriyaransey Buddhist Temple)

This conference will feature voter registration, voter education on the election process and voter rights & responsibilities

តើលោកអ្នកមានការព្រួយបារម្ភចំពោះកិច្ចការចិញ្ចឹមជីវិត ការសិក្សារបស់កូនចៅ ឬសិទ្ធិជាពលរដ្ឋ របស់លោកអ្នកឬទេ?
បើមាន សូមអញ្ជើញមកចូលកិច្ចប្រជុំដើម្បីស្វែងយល់ថាតើលោក អ្នកអាចធ្វើអ្វីខ្លះ:

ការចូលរួមចំណែករបស់លោកអ្នក
ការស្វែងយល់អំពីពត៌មានផ្សេងៗទាក់ទងនឹងនយោបាយ
ធ្វើអ្វីដែលអាចជួយអោយសហគមបានប្រសើរ
បញ្ចេញយោបល់លោកអ្នកដើម្បីអោយមានសំឡេង

កិច្ចប្រជុំនេះនឹងមានការចុះឈ្មោះបោះឆ្នោត ការសិក្សាអំពីដំណើរការបោះឆ្នោត នឹងការយល់ដឹងពីសិទ្ធិរបស់លោកអ្នកក្នុងពេលបោះឆ្នោត។

ពេលវេលា: ថ្ងៃអាទិត្យ ទី ២១ ខែ កញ្ញា
ម៉ោង ១១ ព្រឹក ដល់ម៉ោង ២ រសៀល
ទីកន្លែង: **BCTGM Local 6**
**5416 Rising Sun Avenue** (ទល់មុខវត្តសុរិយារង្សី)

**For more information, please contact:**
**Koeun Chea or Rorng Sorn at (215) 324-4070**

This event is made possible through the joint efforts of the City Commissioners, several concerned Cambodian Americans and the Cambodian Association of Greater Philadelphia.

កិច្ចប្រជុំនេះធ្វើទៅបានដោយមានការចូលរួមសហការពីគណកម្មការបោះឆ្នោតប្រចាំទីក្រុងហ្វីឡាដែលហ្វ្យា សមាជិកសហគមខ្មែរមួយចំនួន និងសមាគមខ្មែរតំបន់ហ្វីឡាដែលហ្វ្យា។

# បទសម្ភាសន៍លោក ខៀវ សំផន ជាមួយនិង ពិន សំខុន ថ្ងៃទី០៤ មិនា ឆ្នាំ១៩៩៨

**តមកពីលេខមុន**

**សំនួរ** : តើថ្ងៃទី៤ មិនា ឆ្នាំ១៩៩៨ ដែលជាថ្ងៃគេកាត់ទោសស្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ដោយតុលាការនៅភ្នំពេញ ពីបទទាក់ទងជាមួយខ្មែរក្រហម ហើយរត់ពន្ធអាវុធខុសច្បាប់ នេះមានន័យអ្វីខ្លះសំរាប់អន្លង់វែង ?

**ចំលើយ** : បាទសុំអរគុណលោកតំណាងវិទ្យុអាស៊ីសេរី លោកបានមកលើកសំនួរនេះចំពោះខ្ញុំជាឱកាសឱ្យខ្ញុំបានជំរាបជាតិ និងប្រជាជនយើងទាំងក្នុង និងក្រៅប្រទេសផង សូមជំរាបជូនប្រទេសនៅលើសកលលោកទាំងតូច ទាំងធំទាំងនៅក្នុងតំបន់ផង នូវការគិតគូររបស់ជាតិ និងប្រជាជនកម្ពុជា ។ ថ្ងៃនេះទី៤ មិនា ១៩៩៨ នេះជាថ្ងៃយួនកុម្មុយនីស្ត អាហ៊ុន សែន និង អាយ៉ងខ្ញុំកញ្ជះរបស់វាកាត់ទោសសម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ គឺជាថ្ងៃមួយដែលអនុវត្តន៍ច្បាប់ច្រាស់ជើង ប្រជាធិបតេយ្យច្រាស់ជើង យ៉ាងម៉េចបានជាខ្ញុំថាច្រាស់ជើង ? ពីព្រោះយួនកុម្មុយនីស្តឈ្លានពានវាទៅជារួចខ្លួន វាទៅជាអ្នកកាត់ទោសអ្នកស្នេហាជាតិទៅវិញ ។ ស្តេចក្រុមព្រះ ខ្ញុំនិងជាតិប្រជាជនយើងចាត់ទុកថាជាកំលាំងជាតិមួយ លោកអត់មានទោសពៃរ៍អ្វីទេ ! ហើយមិនមែនតែកំលាំងជាតិមួយទេ លោកជានាយករដ្ឋមន្ត្រីទី២ ស្របច្បាប់ ដែលចេញពីការបោះឆ្នោតអង្គការសហប្រជាជាតិនាឆ្នាំ១៩៩៣ ឯយួនកុម្មុយនីស្ត អាហ៊ុន សែន **ទី១** វាឈ្លានពាន វាក្បត់ជាតិ អាយ៉ងខ្ញុំកញ្ជះយួនឈ្លានពាន ។ **ទី២** មានទោសសម្លាប់ជាតិ និងប្រជាជនកម្ពុជា, សម្លាប់អ្នកកាសែត, កំទេចហ៊្វុនស៊ិនប៉ិច ជាបន្តបន្ទាប់ រហូតដល់កំទេចបាតុកម្មនៅមុខរដ្ឋសភា នៅថ្ងៃទី៣០ មិនា ១៩៩៧ ។ វាមានទោសដោយធ្វើរដ្ឋប្រហារនៅថ្ងៃទី៥-៦ កក្កដា ឆ្នាំ១៩៩៧ វាបែរជាទៅកាត់ទោសអ្នកដែលរងគ្រោះ គឺស្តេចក្រុមព្រះទៅវិញ ។ នេះហើយដែលខ្ញុំថា ច្បាប់ច្រាស់ជើង ច្បាប់យួនកុម្មុយនីស្ត មិនមែនច្បាប់ខ្មែរ មិនមែនច្បាប់ជាតិ និងប្រជាជនកម្ពុជាទេ ហើយក៏មិនមែនជាច្បាប់របស់ព្រះរាជាណាចក្រកម្ពុជាដែរ វាជាច្បាប់យួនកុម្មុយនីស្តឈ្លានពាន ថ្ងៃនេះដែលវាបញ្ជាក់ច្បាស់អញ្ចឹង ។ វាមានភស្តុតាងហូរហែរមកហើយ តែថ្ងៃនេះវាបញ្ជាក់ច្បាស់អញ្ចឹង... នេះជាបញ្ហាមួយ ឯបញ្ហាមួយទៀត គឺជាឱកាសដើម្បីជាតិ និងប្រជាជនកម្ពុជាគ្រប់ស្រទាប់សង្គម ដើម្បីអ្នកនយោបាយកម្ពុជា អ្នកនយោ-បាយខ្មែរគ្រប់និន្នាការនយោបាយ ដែលមិនមែនខ្ញុំកញ្ជះយួន ដូច អាហ៊ុន សែន យកមកគិតគូរដកពិសោធន៍ថា ហេតុអ្វីបានជាមានថ្ងៃទី៤ មិនា ឆ្នាំ១៩៩៨ នេះមកដល់អញ្ចឹង ? ដើម្បីអ្វី ?

ដើម្បីកុំឱ្យមានថ្ងៃទី៤ មិនា ឆ្នាំ១៩៩៨ នេះទៀតនៅថ្ងៃក្រោយ ហើយនិយាយឱ្យច្បាស់ទៅ



លោក ខៀវ សំផន និង លោក ពិន សំខុន

កុំឱ្យមានពិសោធន៍ដ៏ជូរចត់ប្រកបទៅដោយឈាមរបស់ជាតិ និងប្រជាជន ។ ខ្ញុំមិនរាប់ពីឆ្នាំ១៩៧៩ ទៅចុះ ខ្ញុំរាប់តែពីឆ្នាំ១៩៩២-៩៣ រហូតដល់ថ្ងៃទី៥-៦ កក្កដា ឆ្នាំ១៩៩៧ វាត្រលប់មកវិញ វាសារដើមមកវិញ នេះដែលខ្ញុំលើកយ៉ាងនេះ ។ ឥឡូវពិសោធន៍យ៉ាងម៉េច ក៏សុំឱ្យមានមតិជូនជាតិ និងប្រជាជនកម្ពុជាយើង ជូនប្រទេសដែលស្នេហាសន្តិភាព និងយុត្តធម៌នៅក្នុងតំបន់ និងក្នុងសកលលោកគិតគូរត្រិះរិះពិចា-រណា ។ ពិសោធន៍ទី១ គឺរដ្ឋអំណាច ដែលយួនកុម្មុយនីស្តលើកបន្តុកឡើងតាមចុងកាណុងរបស់វា តាំងពីឆ្នាំ១៩៧៩ រហូតមកដល់សព្វថ្ងៃវានៅតែជារដ្ឋអំណាចយួនកុម្មុយនីស្ត និងអាយ៉ងខ្ញុំកញ្ជះវាឥតមានប្រែប្រួល កំលាំងយួនឈ្លានពានដែលកិច្ចទី៣ កិច្ចព្រមព្រៀងក្រុងប៉ារីស កំណត់ថា ឱ្យមានការផ្សះផ្សាជាតិ ៤ភាគី តាមរូបភាពក្រុមប្រឹក្សាជាន់ខ្ពស់ ដែលមានសម្តេចនរោត្តម សីហនុ ពេលនោះលោកជាព្រះប្រធាន ខនេះក៏មិនបានអនុវត្តន៍ ហើយខមួយទៀត គឺត្រូវបោះឆ្នោតក្នុងបរិយាកាសអព្យាក្រិត្យក៏អត់បានអនុ-វត្តន៍ ។ ឥឡូវការរៀបចំបោះឆ្នោតនៅក្នុងឆ្នាំ១៩៩៨ ខាងមុខនេះគេកំពុងតែរៀបចំសារដើមឡើងវិញដដែល ហើយក្នុងលក្ខណៈសម្បត្តិដែលអាក្រក់ជាងមុនទៅ ទៀត អាក្រក់យ៉ាងម៉េច ? អាក្រក់ត្រង់ថា យួនកុម្មុយនីស្តវាផ្តាច់មុខ អាយ៉ងខ្ញុំកញ្ជះវា ដែលមាន អាហ៊ុន សែន ជាមេក្លោង វាផ្តាច់មុខតាមចិត្តទៅ វាធ្វើរដ្ឋប្រហារថ្ងៃទី៥-៦ កក្កដា ហើយវាមករៀបចំបោះឆ្នោត ហើយសកលលោកបោះ ត្រាឱ្យវាមានសិទ្ធិបោះឆ្នោត មានន័យថា បើអញ្ចឹងវាបោះត្រាឱ្យកុម្មុយនីស្ត និងអាយ៉ងខ្ញុំកញ្ជះវាត្របាក់យកកម្ពុជា នេះហើយជាគ្រោះថ្នាក់ណាស់ដល់ជាតិ និងប្រជាជនកម្ពុជា ដល់ពូជសាសន៍កម្ពុជា ជាគ្រោះថ្នាក់ដល់អាយុជីវិតជាតិ និងពូជសាសន៍ប្រជាជនកម្ពុជាតែម្តង នេះដែលខ្ញុំសុំជំរាបនូវយោបល់របស់ខ្ញុំចំពោះថ្ងៃទី៤ មិនា ឆ្នាំ១៩៩៨ នេះ ចំពោះឆាកល្ខោនកាត់ទោស ដែលអាយ៉ងខ្ញុំកញ្ជះ ដែលមាន អាហ៊ុន សែន ជាមេក្លោង ដែលរៀបចំនៅថ្ងៃទី៤ មិនា ឆ្នាំ១៩៩៨ នេះឡើយ ។

**សំនួរ** : សំនួរនេះផ្តោតទៅលើការឈប់បាញ់គ្នា ដែលប្រកាសឡើងដោយស្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ នាថ្ងៃទី២៧ កុម្ភៈ ឆ្នាំ១៩៩៨ កន្លងទៅនេះ ហើយភ្នំពេញក៏ទទួលការឈប់បាញ់គ្នានេះដែរ ហើយសារព័ត៌មានជាច្រើនបាននិយាយថា ការឈប់បាញ់គ្នានេះមានតែ២ភាគីទេ ខាងអន្លង់វែងអត់មាននិយាយពីរឿងឈប់បាញ់គ្នាទេ តើគំនិតនេះបានន័យយ៉ាងណាដែរ ចំពោះលោក ?

**ចំលើយ** : លើបញ្ហាហ្នឹងខ្ញុំក៏សុំឱ្យមតិជាតិ និងប្រជាជនកម្ពុជាយើងគ្រប់ស្រទាប់សង្គម ពិសេស អ្នកនយោបាយ ដែលមានការពាក់ព័ន្ធដល់បញ្ហានេះ ពិនិត្យពិចារណាថែមទៀត ហើយខ្ញុំក៏សុំឱ្យប្រទេសតូច-ធំ នៅក្នុងសកលលោកដែលស្នេហាយុត្តិធម៌ ពិនិត្យពិចារណាថែមទៀត។ យើងខ្ញុំយល់ការឈប់បាញ់គ្នា បើការឈប់បាញ់គ្នា វាជាផ្នែកមួយនៃការបញ្ចប់ សង្គ្រាមហើយជាផ្នែកមួយនៃការរៀបចំឱ្យមានសន្តិភាពឡើងវិញ ឱ្យមានការផ្សះផ្សាជាតិពិតប្រាកដ ដោយមានកំលាំងជាតិទាំងអស់ចូលរួម ខ្ញុំក៏ដូចជាជាតិ និងប្រជាជនកម្ពុជា ទូទាំងប្រទេស រីករាយអបអរសាទរ ក៏ប៉ុន្តែបើឈប់បាញ់គ្នា ដើម្បីត្រៀមបាញ់ទៀតនោះ អានេះជាតិ និងប្រជាជនកម្ពុជាមិនអាចទទួលបានទេ! ម៉េចបានជាខ្ញុំថាឈប់បាញ់គ្នា ដើម្បីត្រៀមបាញ់គ្នាទៀត ពីព្រោះអត់មានផ្សះផ្សាជាតិ អត់មានបញ្ចប់យួនកុម្មុយនីស្តឈ្លានពាន អត់មានសន្តិភាព ឈប់បាញ់គ្នារបៀបហ្នឹង គឺមានខុសអីពីការរៀបចំរដ្ឋាភិបាលក្បាលពីរកាលពីឆ្នាំ១៩៩២-៩៣ អត់ខុសគ្នាទេ ! ហើយពិសោធន៍ពី១៩៩២-៩៣ រហូតមកដល់ថ្ងៃទី៥-៦ កក្កដា ហួសពីច្បាប់ មិនបាច់អីខ្ញុំនិយាយអីថែមទៀតទេ ថាការឈប់បាញ់របៀបហ្នឹង គឺ "ការឈប់បាញ់គ្នា **(តនៅទំព័រទី១១)**


## ការិយាល័យនិពន្ធ

**កាសែត " ខ្មែរប៉ុស្តិ៍ " ប្រចាំសហរដ្ឋអាមេរិក**

**ឆ្នេរខាងលិច**

- មាជ សុវណ្ណារ៉ា
- គីម សារឿន
- ម៉ៅ ចិត្រា
- រ៉ា នាថ
- សុភា ឫទ្ធិ
- ម៉ី សម្ផស្ស
- ចាន់ កុសល
- សុវណ្ណារិទ្ធ

**ឆ្នេរខាងកើត**

- ពិន សំខុន
- សួន សេរី
- ម៉ម យិន
- គីម ភឿន
- ឆន យ៉ុង



## HIGH TECH AUTO REPAIR

Foreign and Domestic

# "ហាយតិច"

## ជួសជុលរថយន្ត

មានជំនាញដូចខាងក្រោមៈ

- ធ្វើម៉ាស៊ីនឡាន
- ធ្វើភ្លើង "អេឡិចទ្រិច"
- ធ្វើបំពុងផ្សែង
- ធ្វើហ្វ្រាំង (BRAKE)
- ប្តូរប្រេង
- ធ្វើ "ការថ្លឹងភ្លើង" (TUNE UP)
- ត្រួតពិនិត្យ សុវត្ថិភាព នឹងផ្សែង (INSPECTION & EMISSION)







1601 Belfield Ave. Philadelphia, Pa 19141

Tel: 215-455-1344 Fax: 215-455-2085

# សង្គមស៊ីវិល
## ជំរុញឱ្យកែទំរង់ច្បាប់បោះឆ្នោត

*ភ្នំពេញ, ខ្មែរប៉ុស្តិ៍ : ចាន់ កុសល*

•••អង្គការ សមាគមជាតិ និងអន្តរជាតិចំនួន ៦៤ ដែលឃ្លាំមើលពីដំណើរការបោះឆ្នោតជាតិ កាលពីថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៨ បានចេញ ត្រូវគេលប់ឈ្មោះចេញពីបញ្ជី ហើយបាត់បង់សិទ្ធិបោះឆ្នោត ។

ការបាត់បង់ឈ្មោះរបស់ប្រជាពលរដ្ឋក្នុងបញ្ជីបោះឆ្នោតនេះ ដោយសារបច្ចេកទេសថ្មី ឬ





ប្រជាពលរដ្ឋខ្មែរ ចុះឈ្មោះបោះឆ្នោតកាលពីថ្ងៃទី២៧ កក្កដា ២០០៨

សេចក្តីថ្លែងការណ៍រួមគ្នាមួយស្តីពីភាពមិនប្រក្រតីមុនថ្ងៃបោះឆ្នោត និងថ្ងៃបោះឆ្នោត ដែលមានការគំរាមកំហែងសកម្មជននយោបាយ សេរីភាពក្នុងការសំរេចចិត្ត និងការបញ្ចេញមតិ ។

ករណីនៃការគំរាមកំហែងបានកើតឡើងចំនួន៥៨ករណី ស្ទើរគ្រប់ខេត្ត-ក្រុង អ្នកដែលប្រព្រឹត្តបទល្មើសក្នុងការកាប់សំលាប់ ការគំរាមកំហែងដល់អ្នកគាំទ្រគណបក្សនយោបាយ អ្នកសារព័ត៌មាន និងអ្នកបោះឆ្នោតមិនត្រូវបានអាជ្ញាធរ ឬសមត្ថកិច្ចចាប់ខ្លួនយកទៅផ្តន្ទាទោសឡើយ ។

ក្នុងសេចក្តីថ្លែងការណ៍របស់សម្ព័ន្ធអង្គការសង្គមស៊ីវិល ដែលមានគណៈកម្មាធិការខុមហ្វ្រែល គណៈកម្មាធិការប្រព្រឹត្តិកម្ម គណៈកម្មាធិការនិកហ្វិក វេទិកានៃប្រជាពលរដ្ឋស្តីពីកម្ពុជា-ប្រទេសជប៉ុន PEFOCJ បានបញ្ជាក់ថា ដំណើរការនៅថ្ងៃបោះឆ្នោតមានលក្ខណៈល្អប្រសើរជាងលើកមុនៗ ។

ទន្ទឹមនឹងនេះដែរ សម្ព័ន្ធអង្គការសង្គមស៊ីវិលក៏បានរកឃើញនូវភាពមិនប្រក្រតីជាច្រើននៅថ្ងៃបោះឆ្នោត ដោយសារប្រជាពលរដ្ឋជាច្រើននាក់ចេតនានយោបាយ និងការខ្វះខាតភាពទទួលខុសត្រូវរបស់ គ.ជ.ប និងអាជ្ញាធរឃុំ-សង្កាត់ ។ ដូច្នេះអង្គការសង្គមស៊ីវិលចង់ឱ្យ គ.ជ.ប ធ្វើកំណែទំរង់ច្បាប់ទេធ្វី ដើម្បីចៀសវាងភាពមិនប្រក្រតីកើតឡើងទៀត ប៉ុន្តែខាង គ.ជ.ប បែរជាបដិសេធ និងមិនព្រមកែទំរង់ទេ លុះត្រាតែកែរដ្ឋធម្មនុញ្ញ ។

លោក ធន សារាយ ប្រធានគណៈកម្មាធិការខុមហ្វ្រែល និងជាប្រធានសមាគមអាដហុក បានមានប្រសាសន៍ក្នុងសន្និសីទកាលពីថ្ងៃទី១២ ខែសីហា សណ្ឋាគារសាន់វេ ថា ការបាត់បង់សិទ្ធិអ្នកបោះឆ្នោតនេះ វាអាចធ្វើឱ្យប៉ះពាល់ដល់ដំណើរការបោះឆ្នោត ការរំលោភសិទ្ធិមនុស្ស ហើយការចេញទំរង់១០១៨ វាធ្វើឱ្យមានភាពមិនប្រក្រតីខ្លាំងណាស់ ។

លោក ធន សារាយ បានបន្តថា ដើម្បីចៀសវាងការតវ៉ាប្តឹងប្តល់ពេលបោះឆ្នោតម្តងៗ គ.ជ.ប គួរតែរៀបចំបញ្ជីឈ្មោះអ្នកបោះឆ្នោតថ្មី សំរួលនីតិវិធីឱ្យអ្នកបោះឆ្នោតមានឯកសារ អាចបោះឆ្នោត និងព័ត៌មានការិយាល័យអចិន្ត្រៃយ៍ ក្នុងការគោរពសិទ្ធិមនុស្សឱ្យបានស្របច្បាប់ ពេញលេញ ។

(តទៅទំព័រទី១៥)

# ស្តាប់សៀមនិយាយពីខ្សែបន្ទាត់
## ព្រំដែន រវាងខ្មែរ និង សៀម

*ដោយ : សន ជ័យសិទ្ធិ*

•••ចំណុចបញ្ហារឿងផ្ទៃដីដែលប្រកាសជាកម្មសិទ្ធិជាន់គ្នា បានផ្ទុះចេញមកម្តងទៀត ក្រោយពីមានការនាំរឿងផលប្រយោជន៍ប្រេងឥន្ទនៈ ចុះបញ្ជីប្រាសាទព្រះវិហារបានសំរេច ក្នុងការប្រជុំយូណេស្កូក្នុងខែកក្កដា រួមមកហើយនេះបាននោះ ។

នេះគ្រាន់តែជាការសន្និដ្ឋាន ដែលជាពាក្យ



ជំនួបពិភាក្សារវាងរដ្ឋមន្ត្រីការបរទេសខ្មែរ និងសៀម

និងឧស្ម័នធម្មជាតិក្នុងផ្ទៃដីដែលថា ជាកម្មសិទ្ធិជាន់គ្នាក្នុងឈូងសមុទ្រសៀម ដែលប៉ាន់ស្មានថាអាចមានតម្លៃរហូតដល់ជាង៥លានលានបាត ។

តែដែលគួរឱ្យចាប់អារម្មណ៍ជាងនេះទៅទៀតនោះ គឺថាមានការពាក់ព័ន្ធថា អាចមានអ្នកនយោបាយមានឈ្មោះល្បីរបស់សៀមម្នាក់បានទទួលផលប្រយោជន៍ជាសម្បទាន ក្នុងដីពោលខាងលើ ប្រសិនបើអាចជួយជំរុញឱ្យកម្ពុជាចោទប្រកាន់ដើម្បីប្រើវាយប្រហារលោក ណុបផៈដុន ប៉ាត់ថៈម៉ៈ អតីតរដ្ឋមន្ត្រីក្រសួងការបរទេស រហូតទ្រមោខ្លួនជាង៥ម៉ោង នៅក្នុងការបើកការប្រជុំសភាប្រកាសការមិនទុកចិត្តលើរដ្ឋាភិបាល តែភាពច្បាស់លាស់រឿងផែនទី និងផលប្រយោជន៍នៃផ្ទៃដីដែលមានកម្មសិទ្ធិជាន់គ្នា ក៏នៅតែមិនច្បាស់លាស់ដដែល ។ ហាក់ដូចជាថា វិតតែបិទបាំង... ( តទៅទំព័រទី២១)


# ទៅណាទៀត ?
## បន្ទាប់ពីជួបវេជ្ជបណ្ឌិតរួចហើយ
## ឱសថស្ថានWASHINGTON AVENUE
## នឹងជួយជល់តម្លៃនិញថ្នាំពេទ្យ ជាពិសេសចំពោះ
## គ្រួសារ ដែលមានប្រាក់ចំណូលតិចតួច

កុំភ្លេចយក

៣០ សីហា

រទ្វាន់ដោយ ឥតគិតថ្លៃ



កាតាបធ្វើដំណើរ

នៅមានរង្វាន់ទីពីរទៀត



ជបវីតាមីនមួយ
វីតាមីនD
វីតាមីនC
វីតាមីនសំរាប់ស្ត្រី
វីតាមីនសំរាប់បុរស

ពិសេសសំរាប់អ្នកមាន ជំងឺកាន់ខាងផ្អែម

ប្រដាប់វាស់ស្ករឈាមដោយឥតគិតថ្លៃ



* ស្ពាលញ
* ញើស
* ក្រពះ
* ឥតឈឺ

Washington Ave
ឱសថស្ថាន
215-755-5100

600 Washington ave, Unit 18E Phila, PA - phone: 215-755-5100

# មតិពលរដ្ឋខ្មែរជុំវិញការចរចាខ្មែរ_ថៃ ស្តីពីជម្លោះនៅព្រះវិហារ

**ដកស្រង់ដោយ : ម៉ម យិន**

•••ប្រជាពលរដ្ឋខ្មែរមួយចំនួន បានសម្តែងមតិ យោបល់រៀងៗខ្លួនជុំវិញដំណើរការចរចារបស់ភាគីខ្មែរ-ថៃ អំពីជម្លោះនៅតំបន់ប្រាសាទព្រះវិហារ ដោយបានជួបសម្ភាសន៍ជាមួយវិទ្យុអាមេរិកាំង វិទ្យុបារាំង វិទ្យុអូស្ត្រាលី វិទ្យុខ្មែរជាដើម ។

❖លោក អាំងអែង សុភាព ជាវេជ្ជបណ្ឌិតម្នាក់ លោកមានការអន់ចិត្តជាខ្លាំងចំពោះទង្វើរបស់ រដ្ឋាភិបាលខ្មែរ ដែលមិនព្រមប្រគល់រឿងនេះ ទៅអង្គការសហប្រជាជាតិជាអ្នកដោះស្រាយ ដើម្បីបញ្ចប់បញ្ហាជម្លោះព្រំដែនជាមួយថៃទាំងស្រុង ។ លោកបានបន្តទៀតថា បើសិនជារដ្ឋាភិបាលយើងឆ្លាត យើងត្រូវបានចំណេញនៅកន្លែងហ្នឹង ប្តឹងឱ្យអង្គការសហប្រជាជាតិសើរើព្រំដែនកម្ពុជា-ថៃ ទាំងមូលតែម្តង នេះបានយើងមានផ្លូវចំណេញបាន ។ ភាគីខាងគេ គេមករំលោភខាងយើង យើងធ្វើសម្បទានបន្តិច គេសម្បទានបន្តិច អ៊ីចឹងមានន័យថា យើងជាអ្នកចាញ់ហើយ ។

❖លោក ស៊ិន ធន់ គ្រូបង្រៀននៅកំពង់ធំ លោកមិនដែលឃើញខ្មែរចំណេញទាល់តែសោះ នៅក្នុងការចរចាររវាងខ្មែរ និងយួន និងសៀម ចោរយួន ចោរសៀម បញ្ហាព្រំដែននេះ គឺអត់បានផលប្រយោជន៍អ្វីទេ ពីព្រោះមិនអាចចរចាបានទេ ព្រោះប្រាសាទព្រះវិហាររបស់យើងៗត្រូវអន្តរជាតិដោះស្រាយ ឱ្យអង្គការសហប្រជាជាតិដោះស្រាយ ព្រោះជារបស់ខ្មែរ ។

❖អ្នកស្រី រ៉ានី ពីខេត្តពោធិ៍សាត់ : មោទនៈភាពជាតិខ្មែរ មិនដឹងនៅកន្លែងណាទេ បើប្រាសាទជារបស់ខ្មែរ បែរមន្ត្រីខ្មែរ ដាក់ខ្លួនយ៉ាងទន់ភ្លន់ទៅចរចាជាមួយប្រទេសសៀម ដែលជាអ្នករំលោភឈ្លានពានយកនោះទៅវិញ ។ បើមោទនៈភាពគ្រាន់តែដើរអង្វរចោរហើយឥឡូវហ្នឹង ។ ខ្ញុំខកចិត្តចំពោះទង្វើរបស់រដ្ឋាភិបាល ។ ខ្ញុំមានអារម្មណ៍ធុញទ្រាន់ណាស់ ពីរឿងចរចាពីរឿងរ៉ែអង្គាសវិភាគទានស្អី សប្បុរសជនសប្បុរសធម៌ហ្នឹង ។ បើតាមខ្ញុំ ខ្ញុំគិតថា ការចរចាផ្អែមល្ហែមហ្នឹង វាសំរាប់អ្នកដែលខុសទៅចរចាជាមួយអ្នកត្រូវ ប៉ុន្តែដល់យើងនេះ ជាអ្នកអស់ទឹកដី ជាជនរងគ្រោះ ដែលត្រូវជនបរទេសឈ្លានពានរំលោភដីធ្លី តែបែរទៅជាទន់ភ្លន់អង្វរករគេ ចុះហេតុអ្វី ក៏យើងមិនធ្វើតាមច្បាប់ទៅ ?

❖និស្សិត ហ៊ុន ឈិន អាយុ ២៨ឆ្នាំ : រដ្ឋាភិបាលគ្មានចេតនាដោះស្រាយបញ្ហានោះទេ ទំនងមានពាក់ព័ន្ធនឹងបញ្ហាអ្វីមួយផ្សេងទៀត នៅពីខាងក្រោយរឿងហ្នឹងហើយ ។ ក្នុងនាមខ្ញុំជាប្រជាពលរដ្ឋខ្មែរម្នាក់ ខ្ញុំគិតថា វាគ្រាន់តែជាល្បែងនយោបាយរបស់អ្នកដឹកនាំខ្មែរ តែបណ្តើងទេ ។

❖លោក ថេន ចាន់ថា អាយុ ៣២ឆ្នាំ : ការចរចានិងធ្វើឱ្យកម្ពុជាខាតបង់រឹតតែច្រើន ។ ការទម្លាក់រឿងរ៉ាវនេះ ឱ្យសមាជិកអាស៊ាន ឬក៏អង្គការសហប្រជាជាតិដោះស្រាយនឹងធ្វើឱ្យពលរដ្ឋខ្មែរមានទំនុកចិត្តច្រើនជាងទង្វើបច្ចុប្បន្ន ដែលផ្តោតទៅលើការចរចា ។ លោកបន្ថែមទៀតថា : ខ្ញុំយល់ថា បើសិនជាមិនប្តឹងទៅអង្គការសហប្រជាជាតិទេ ហើយយើងចរចាគ្នារវាងកម្ពុជា-ថៃ ហ្នឹង ខ្ញុំជឿថាខ្មែរនឹងខាតបង់ប្រយោជន៍ ។ ថ្វីដ្បិតតែគេថា ដកមែន តែគេនៅមានគំនិតមួយ គេនៅចង់ឱ្យព្រំដែនហ្នឹង ខ្មែរកាន់មិនបាន ថៃក៏កាន់មិនបាននៅគំនូសស ខ្មែរអត់ដដែលហ្នឹង ។

❖អាជីវករ ឈ្មោះ ផាន់ ទី អាយុជាង ៤០ឆ្នាំ ខ្ញុំមានការភ័យព្រួយបារម្ភ ទៅលើបញ្ហាដី ដែលជារបស់ខ្មែរ ហើយត្រូវគេឈ្លានពាន ។ ខ្ញុំមិនជឿថា ការចរចាបែបហ្នឹង ទទួលបានជោគជ័យក្រៅពីអង្គការសហប្រជាជាតិ ទេ ។

❖លោក កេង វណ្ណថា គ្រូបង្រៀន : ការដកទ័ពរបស់ខ្មែរថា ជាទង្វើកំសាក ទឹកដីខ្មែរបានបាត់បង់ជាបន្តបន្ទាប់មកទល់បច្ចុប្បន្ននេះ ប៉ុន្តែខ្មែរនៅតែខំចរចាមិនដោះស្រាយតាមផ្លូវច្បាប់ ដែលមានស្រាប់ សម្រាប់តំបន់ប្រាសាទព្រះវិហារ ។ ថៃបានរំលោភយ៉ាងធ្ងន់ធ្ងរទាំងកម្រាលតែម្តង ទៅលើសាលក្រមរបស់តុលាការអន្តរជាតិក្រុងឡាអេ ។ អ្វីដែលទាក់ទងនឹងការព្រួយបារម្ភនោះ គឺខ្លាចបាត់បង់ទឹកដីដ៏ច្រើន ប្រហែលជាអស់ ៣/៤ (អស់៣ភាគ៤) នៅសល់ប្រហែល ១/៤ (១ភាគ៤ទេ) ទឹកដីបច្ចុប្បន្ន ។ បើរដ្ឋាភិបាលយើងនៅតែប្រកាន់ជំហរដោះស្រាយៗតែក្នុងលក្ខណៈមួយរណបឱ្យបរទេស មិនគួរណាចរចាឱ្យដកទ័ពនេះ ជារឿងមួយកំសាករបស់រដ្ឋាភិបាល ខ្ញុំយល់ថាអ៊ីចឹង ។

នៅក្នុងការសាកសួរពលរដ្ឋសាម័ញ្ញជាច្រើននាក់ គេហាក់ដូចជា ពិបាករកឃើញអ្នកផ្តល់មតិយោបល់យល់ស្របចំពោះការដកកងទ័ពខ្មែរចេញពីតំបន់ប្រាសាទព្រះវិហារ និងការចរចាដែលមន្ត្រីខ្មែរកំពុងធ្វើបច្ចុប្បន្ននេះ ។

ប៉ុន្តែតាមរដ្ឋមន្ត្រីការបរទេស លោក ហោ ណាំហុង ដែលទើបត្រលប់មកពីក្រោយការចរចានោះ បាននិយាយថា "ការចរចាបានទទួលជោគជ័យជាបន្តបន្ទាប់ ដោយភាគីទាំងពីរសុខចិត្តដកកងទ័ពចេញរៀងៗខ្លួន ចៀសវាងសង្គ្រាម ហើយរង់ចាំដោះស្រាយដោយសន្តិវិធី" ។

ទស្សនៈបន្ថែមរបស់លោក ពិន សំខុន : មានបញ្ហាធំៗច្រើនណាស់ ដែលរដ្ឋាភិបាលខ្មែរសព្វថ្ងៃបានបង្កើតឡើង ហើយពុំបានដោះស្រាយឱ្យបានជោគជ័យជ្រះស្រឡះ ហើយមានផលប្រយោជន៍ដល់ជាតិ មាតុភូមិខ្មែរ ជាដុំកុំភួននោះទេ ។ តាមការពិតឃើញមានផលប្រយោជន៍សំខាន់ៗជារបស់មាតុភូមិ និងជាតិខ្មែរច្រើនណាស់ត្រូវខាត់បង់ទៅជារៀងរាល់ថ្ងៃ តែផ្ទុយទៅវិញ រដ្ឋាភិបាលខ្មែរ ថ្លែងអះអាងថា ជាជោគជ័យទៅវិញ ។

បញ្ហាប្រាសាទព្រះវិហារ និងតំបន់ព្រំដែនយើងមានបន្ថែមបញ្ហាប្រាសាទតាមាន់ធំ-តូច និងតំបន់ព្រំដែនទាំងអស់ កាលបើក្រឡេកមើលទៅឯប្រទេសថៃ ឯណោះវិញ មានបណ្តាញទូរទស្សន៍ថៃមួយឈ្មោះ អេ អេស ធី វី ( ASTV) បានធ្វើការផ្សព្វផ្សាយចំនួន ២៤ម៉ោង រៀងរាល់ថ្ងៃ គ្មានថ្ងៃណាមួយដែល ( ASTV) នេះមិនផ្សាយចោទប្រទេសខ្មែរ ជាតិខ្មែរថា ជាអ្នកឈ្លានពានរំលោភលើកទឹកដីសៀម **(តនៅទំព័រទី២០)**


# លោកមានសុខភាពរាល់ថ្ងៃ មិនប្រក្រតី សូមប្រើ reliv

## សក្ខីកម្ម

ខ្ញុំមានជំងឺ Cancer ខួរក្បាល ហើយបានវះក្បាលពីរដង ខ្ញុំ ស្ថិតក្នុងការព្យាបាល Chemotheraphy ១៨ ខែ ....ពីរ ឆ្នាំក្រោយមកខ្ញុំមានគ្រោះថ្នាក់រថយន្តទៀត ។

ពេលបានជួប Relive មួយ ឆ្នាំក្រោយមកការឈឺចុកចាប់ក៏បាត់ទៅអស់ ខ្ញុំប្រែមាន កម្លាំង ហើយអាចហាត់ប្រាណវិញបាន មិនតែប៉ុណ្ណោះចុះ ទម្ងន់ទៀតផង ។

Stephanis
-Emmons (817) 847-5476

The Reliv scientists formulate the most recent nutrition research into products that scientifically advance, nutritionally complete, and is proven to restore the boby functions.

**របៀបប្រើ :** រៀងរាល់ព្រឹក ដួស RELIV មួយស្លាបព្រារង្វាល់ពីកំប៉ុង A មួយស្លាបព្រារង្វាល់ទៀត ពីកំប៉ុង B ដាក់ទៅក្នុងកែវមានទឹកធម្មតា ឬទឹកផ្លែ ឈើ កូរលាយគ្នា រួចពិសារព្រឹកម្តង ល្ងាចម្តងទទួលលទ្ធផលទាន់ចិត្ត

□ **ទូរស័ព្ទសំរាប់ជាវ** (636) 537-9715

**ជាវ** ① RELIV CLASSIC : A
② RELIV INNERGIZE : B

**កុំភ្លេចឱ្យលេខ** Reliv Distributor :
(RNC.# 7070 438001)

□ **ទូរស័ព្ទ :** (267) 253-3947 **សំរាប់ហៅ**
**បើលោកអ្នកចង់ចែកចាយជូនមិត្តភក្តិបងប្អូនបន្តទៅទៀតជា** Relive Distributor

**RCN# 7070438001 www.reliv.com**

នៅ **VIRGINIA CALL VANNDY 1-703 415-6257**

**Please Call : (267) 253-3947**



# ខ្មែរចុះទឹកជួបសត្វក្រពើ ខ្មែរឡើងលើជួបសត្វខ្លា

**ដោយ : ម៉ម យិន**

•••បញ្ហាប្រាសាទព្រះវិហារ បានដាស់សតិជនជាតិខ្មែរស្នេហាជាតិពិតប្រាកដ នៅក្នុង និងក្រៅប្រទេសពាសពេញលើពិភពលោក ធ្វើឱ្យជាតិខ្មែរ ខំប្រឹងសំដែងនូវទឹកចិត្ត អំពើព្រៃផ្សៃយង់ឃ្នងរបស់រដ្ឋាភិបាលកងទ័ព និងជនជាតិសៀមដែលបានរំលោភឈ្លានពានមកលើបូរណភាពអធិប តេយ្យភាពទឹកដីខ្មែរយ៉ាងជាក់ស្តែងខ្លាំងណាស់ ។

ព្រឹត្តិការណ៍នាថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៨ បានផ្ទុះឡើងប្រៀបបានការផ្ទុះឡើងនៃការរញ្ជួយ ផែនដី នៅតំបន់ប្រាសាទព្រះវិហារ ។

បន្ទាប់ពីឃើញកម្លាំងកងទ័ពសៀម បញ្ចេញសកម្មភាព ចូលមកគគ្រឹកគគ្រេង នៅក្នុងបរិវេណប្រាសាទព្រះវិហារ កម្លាំងកងទ័ពខ្មែរក៏បានបញ្ជូនទៅយ៉ាងទាន់ហន់ និងសន្ទឹកសន្ទាប់ដែរដោយមានបេសកកម្មទៅឈរមើលកងទ័ពសៀមថាតើគេនាំគ្នាមកធ្វើអ្វីនៅលើដែនដីខ្មែរ ? ។

ព្រឹត្តិការណ៍ទាំងនេះ បណ្តាលឱ្យមានការតានតឹង ដោយសារតែស្ថានការណ៍យោធានៃប្រទេសទាំងពីរ បម្រុងនឹងផ្ទុះអាវុធ លើកជាសង្គ្រាមដ៏កាចសាហាវមួយរវាងអ្នកឈ្លានពានទឹកដីគេនឹងអ្នកម្ចាស់ការពារទឹកដីរបស់ខ្លួន ។

រយៈពេលជាង៣០ថ្ងៃ ចាប់តាំងពីថ្ងៃទី១៥ ខែកក្កដាមកភាពតានតឹងមិនបានប្រែប្រួលទេ លុះមកដល់ថ្ងៃទី១៦ ខែសីហា ស្រាប់តែមានការផ្សាយឱ្យដឹងថា កងទ័ពសៀម និងកងទ័ពខ្មែរបាននាំគ្នាលួចដកកងទ័ពចេញដោយស្ងាត់ៗតែរៀងខ្លួន ដោយបន្សល់ទុកកងទ័ពមួយចំនួនតូច ដើម្បីឱ្យនៅលើតំបន់ លើកហេតុនោះដដែល ។

ការដកចេញកងទ័ពដោយស្ងាត់ៗ និងបន្សល់ឱ្យឃើញថា តំបន់ព្រំដែននៅលើប្រាសាទព្រះវិហារនេះខាងភាគីខ្មែរក៏ជាអ្នកពុំដឹងថា តំបន់នេះជារបស់ផងខ្លួនពិតប្រាកដទេ ចំណែកខាងភាគីសៀម គេបានប្រកាសថា តំបន់ប្រាសាទព្រះវិហារនោះជារបស់ប្រទេសថៃពិតប្រាកដ គេថែមទាំងប្រឆាំងតវ៉ាទាមទារឱ្យរាជរដ្ឋាភិបាលខ្មែរដកកងកម្លាំងទ័ពចេញ ហើយប្រគល់ទៅឱ្យប្រទេសថៃវិញជាដាច់ខាត ឱ្យក្រុមអ្នកធ្វើវិភាគនយោបាយជាច្រើនមានការមន្ទិលសង្ស័យទៅលើការរៀបចំផែនការនយោបាយរបស់ខ្លួន សម្រាប់ទាញយកផលប្រយោជន៍ដ៏ធំមួយពីព្រឹត្តិការណ៍នេះ ដូចជានៅមុនថ្ងៃបោះឆ្នោត២០០៨ មួយថ្ងៃមានអង្គការឃោសនាព័ត៌មានសំខាន់ៗ របស់បក្សកាន់អំណាច បានផ្សាយយ៉ាងរន្ថើនៗ រំលឹកទៅដល់ប្រជាពលរដ្ឋជាម្ចាស់សន្លឹកឆ្នោតថា ប្រជាពលរដ្ឋខ្មែរទាំងអស់ត្រូវតែនាំគ្នាទៅបោះឆ្នោតឱ្យគណបក្សប្រជាជនកម្ពុជា ឱ្យបានទទួលជ័យជំនះពិតប្រាកដ ទើបប្រទេសកម្ពុជាបានសុខសន្តិភាពតទៅទៀតបើកាលណាគណបក្សប្រជាជនចាញ់ឆ្នោត សង្គ្រាម រវាងកម្ពុជា-ថៃ មុនជាផ្ទុះឡើង ហើយនៅក្នុង បញ្ហាជម្លោះប្រាសាទព្រះវិហារដែលកងកម្លាំងទ័ព ទាំងពីរកំពុងតែប្រឈមមុខដាក់គ្នា ។

ដោយសារតែប្រជាពលរដ្ឋខ្មែរ ចង់បានសន្តិភាព ហើយភ័យខ្លាចសង្គ្រាមផ្ទុះឡើង នៅលើប្រាសាទព្រះវិហារ ធ្វើឱ្យលទ្ធផលនៃការបោះឆ្នោត ត្រូវតែបានមហាជោគជ័យទៅលើបក្សកាន់អំណាចពិតប្រាកដមែន នៅក្នុងអណត្តិទី៤នេះ។

ដំណោះស្រាយបញ្ហាប្រាសាទព្រះវិហារ បានក្លាយទៅជាគោលដៅមួយសំខាន់បំផុត ត្រូវធ្វើ



លោកតា ម៉ម យិន

យ៉ាងណាកុំឱ្យមានផ្ទុះអាវុធឱ្យសោះ ហើយត្រូវតែខំប្រឹងធ្វើយ៉ាងណាឱ្យបញ្ហាដ៏ធំនេះ បានដោះស្រាយរួចដោយសន្តិវិធី ដូចពាក្យ សន្យារបស់គណបក្សកាន់អំណាច ។

បញ្ហាដ៏អាថិកំបាំងនេះ ពុំអាចមានអ្នកវិភាគនយោបាយណាមួយ លើកយកមកហែកហួរកកូរ កកាយបានឡើយ សូម្បីតែសង្គមស៊ីវិលជាតិនិងអន្តរជាតិ និងអង្គការ សកម្មជនស្នេហាជាតិនៃអង្គការ ដែលដឹកនាំដោយលោក វ៉ុងឈុននិងលោក ជា មុនី បានសុំសេចក្តីអនុញ្ញាតិធ្វើការប្រជុំដែរហែក្បួន ដោយអហិង្សាសន្តិវិធី ដើម្បីសំដែងទឹកចិត្តស្នេហាជាតិ និងគាំទ្រដល់សេចក្តីប្រឹងប្រែងរបស់រដ្ឋាភិបាល ក្នុងការជួបចរចាជាមួយរដ្ឋាភិបាលថៃ ឱ្យបានទទួលជោគជ័យនៅថ្ងៃទី១៨-១៩ ខែសីហានេះក៏ដោយ ។

ការជួបប្រជុំគ្នានៃអង្គការសកម្មជនទាំងពីរ បានចាប់ផ្តើមធ្វើឡើងនាព្រឹកថ្ងៃអាទិត្យ ទី១៧ សីហា នៅខាងមុខរដ្ឋសភាចាស់ មិនទាន់ទាំងបានរៀបចំស្រួលបួលផង ស្រាប់តែកងនគរបាលរក្សាសន្តិសុខ ទីក្រុងភ្នំពេញ បានបញ្ជូនទៅកាន់មុខរដ្ឋសភា ដោយមានខែលក្បាំងការពារ ដំបងឆក់ និងប្រដាប់បាញ់ផ្សែងបង្ហូទឹកភ្នែក បានបញ្ចេញសកម្មភាពវាយបំបែកហ្វូងសកម្មជនដោយខ្លាំងក្លាបំផុត ប្រៀបបាននឹងការវាយបំបែកកងទ័ពយួនចូលលុកលុយប្រទេសកម្ពុជានាចុងឆ្នាំ១៩៧៨ បង្ហាញឱ្យឃើញថា រាជរដ្ឋាភិបាលកម្ពុជា មិនបណ្តោយឱ្យក្រុមសកម្មជនឬជនជាតិខ្មែរដទៃណាចេញមុខមកសម្តែងទឹកចិត្ត ឬធ្វើការតវ៉ា ទាមទារអ្វីដែលសមស្របនឹងច្បាប់រដ្ឋធម្មនុញ្ញខ្មែរ ហើយជាកាយវិការមួយស្របគ្នាទាំងស្រុងទៅនឹងសកម្មភាពរបស់រាជរដ្ឋាភិបាលផងនោះបានឡើយ ។

ចំពោះនៅក្នុងប្រទេសថៃទាំងមូល សូម្បីតែជនជាតិសៀមដើមកំណើតខ្មែរជាច្រើន ក៏គេបាននាំគ្នាក្រោកឡើងទាំងកម្រោលប្រជុំគ្នាហែរក្បួន ស្រែកទាមទារតវ៉ាឱ្យកងទ័ពខ្មែរដកចេញពីប្រាសាទព្រះវិហារ ហើយប្រគល់ប្រាសាទព្រះវិហារឱ្យទៅប្រទេសថៃវិញ កងទ័ពខ្មែរមិនត្រូវរំលោភឈ្លានពានមកលើទឹកដីថៃដូច្នេះទេ ។ ជាច្រើនឆ្នាំកន្លងមកហើយ ទាំងថ្ងៃទាំងយប់គ្រប់វិនាទី រដ្ឋាភិបាលថៃពុំដែលមានបញ្ហាឱ្យចេញទៅបង្ក្រាបម្តងណាទេ ហើយការចាប់ចង និងការបាញ់សម្លាប់ក៏ពុំមានដែរ នៅក្នុងក្រុងបាងកក ។

តើមកពីហេតុអ្វី បានជារាជរដ្ឋាភិបាលខ្មែរ

**(តទៅទំព័រទី១៤)**

# ជំងឺរលាកសន្លាក់ឆ្អឹង ARTHRITIS

សុខភាព

**1-** <u>និយមន័យ</u> **(Definition) :** ជំងឺសន្លាក់ឆ្អឹងមានន័យថា ការរលាកនៅក្នុងសន្លាក់ឆ្អឹង ។ មានជំងឺសន្លាក់ឆ្អឹងប្រហែលជាងមួយរយប្រភេទ ។ ជំងឺទាំង នោះមានសភាពប្រហាក់ប្រហែលគ្នា ប៉ុន្តែមាន



Arthritis Hand



Arthritis Knee



Arthritis Hand

រោគសញ្ញាខុសគ្នា រួមមានការឈឺចាប់- តឹងហើយរឹង-រលាក ហើយឈឺចាប់ក្នុងសន្លាក់ឆ្អឹង ។ ទោះបីជារោគសញ្ញាទាំងនេះដូចគ្នាក៏ដោយ ទំរង់នៃជំងឺសន្លាក់ឆ្អឹងនេះ មានភាពខុសគ្នាពីមួយទៅមួយទៀត ។ ទំរង់នៃជំងឺសន្លាក់ឆ្អឹងនេះ មានបែងចែកជា៣ ប្រភេទសំខាន់ៗគឺ: ជំងឺរលាកសន្លាក់សរសៃ (rheumatoid arthritis) , ជំងឺរលាកសន្លាក់ឆ្អឹង (osteoarthritis) និងជំងឺប៉ោងរឹងសន្លាក់ (gout) ។

**2-** មូលហេតុ **(Cause):**

មូលហេតុនៃបណ្តាប្រភេទ ជំងឺសន្លាក់ឆ្អឹងទាំងពីរគឺ : ជំងឺរលាកសន្លាក់សរសៃ និងជំងឺរលាកសន្លាក់ឆ្អឹង នៅមិនទាន់ច្បាស់នៅឡើយ ។ នៅពេលមួយវេជ្ជបណ្ឌិតជឿថា គឺគ្រាន់តែជាផ្នែកមួយនៃការរីកចំរើននៃអាយុតែប៉ុណ្ណោះ ។ ពួកគេបានគិតថា សន្លាក់ឆ្អឹងសឹកចាស់ហួសកំណត់ទៅហើយ ។ បច្ចុប្បន្ននេះ អ្នកស្រាវជ្រាវកំពុងស្វែងរកមូលហេតុ នៃជំងឺទាំងពីរនេះ ។

**ជំងឺរលាកសន្លាក់សរសៃ (Rheumatoid Arthritis):**

ទ្រឹស្តីថ្មីៗនេះ បានលើកឡើងថាជំងឺនេះ បណ្តាលមកពីកត្តាឆ្លងតាមពូជ ។ នោះគឺមនុស្សម្នាក់បានកើតមក ដោយមាន និន្នាការអភិវឌ្ឍន៍ ឬមិនអភិវឌ្ឍន៍ស្ថានភាពនោះ ។ បន្ទាប់មកវត្ថុខ្លះនៅក្នុងបរិស្ថានបង្កើតឱ្យមានភាពឥតសណ្តាប់ធ្នាប់

ដោយខ្លួនឯង។ ទ្រឹស្តីមួយទៀតនិយាយថា ភ្នាក់ងារចំលង ដូចជា បាកតេរី ឬ វីរុស ចាប់ផ្តួចផ្តើមជាជំងឺនេះឡើងបានដែរ។

ទោះជាមូលហេតុណាក៏ដោយ RA គឺបណ្តាលមកពីភាពស៊ាំស្វ័យប្រវត្តិរបស់រាងកាយកើតឡើងគឺគ្មានសណ្តាប់ធ្នាប់នៅក្នុងល័ក្ខខ័ណ្ឌមួយ ដែលប្រព័ន្ធស៊ាំរបស់រាងកាយនេះ ចាប់ផ្តើមមានប្រតិកម្មមិនធម្មតា ។ ប្រព័ន្ធស៊ាំនេះ គឺជាបណ្តាញរបស់សរីរាង្គ មានជាលិកា-កោសិកា និងសារជាតិគីមី ដែលមានមុខងារការពាររាងកាយតទល់និងមេរោគខាងក្រៅ ដូចជា បាក់តេរី និង វីរុស ។ល។ នៅពេលដែលប្រព័ន្ធស៊ាំ ក្លាយទៅជាច្របូកច្របល់ វាមិនអាចទទួលខុសត្រូវលើបណ្តាផ្នែកខ្លះ នៃរាងកាយ ប្រសិនបើមានការវាតត្បាតពីមេរោគពីក្រៅ ។ ប្រព័ន្ធនេះក៏បើកបញ្ចេញទ័ព និងអាវុធសំរាប់ចេញប្រឆាំង ជាមួយមេរោគ នៅផ្នែកខ្លះនៃរាងកាយ។ នៅពេលដែលប្រព័ន្ធស៊ាំនេះមានប្រតិកម្មប្រឆាំងនឹងផ្នែកខ្លះនៃសន្លាក់ឆ្អឹងពេលនោះ RA ក៏កើតឡើង ។

**រលាកសន្លាក់ឆ្អឹង (Osteoarthritis) :**

អ្នកវិទ្យាសាស្ត្រ ទទួលស្គាល់ថាជំងឺ Osteoarthritis នេះមានពីរតំណាកកាល ។ Osteoarthritis តំណាក់កាលទីមួយ បណ្តាលមកពីការសង្កត់មិនធម្មតា ទៅលើសុខភាពនៃសន្លាក់ឆ្អឹង ឬដោយសារការចុះខ្សោយនៃសន្លាក់ឆ្អឹង ។ **(តទៅទំព័រទី២០)**

From :Philadelphia



ហាងខ្មែរជួសជុលរថយន្ត

បើចង់ឱ្យរថយន្តលោកអ្នករត់បានល្អ សូមអញ្ជើញ

**Rathe`s Auto Service**

State and Emission
Inspection General
Repairs and Maintenance

MON-SAT, 8:30AM -5:30PM
SUN. EMERGENCY ONLY




-ជាងមានបទពិសោធន៍ជាយូរឆ្នាំ -ជួសជុលរថយន្តគ្រប់ប្រភេទ
-មានដូរប្រេង ដូរប្រ៊្រាំង ដូរកង់ និងករណីជាច្រើនទៀត ។
-មានត្រួតពិនិត្យគ្រឿងម៉ាស៊ីន DIAGNOSTICS ដោយឥតគិតថ្លៃ -មានចុះថ្លៃពិសេស ចាប់ពីខែកុម្ភៈ ២០០៨
ទៅ : -ដូរប្រេងកឺរិត ៥ ក្វាត $22. - INSPECTIONS រថយន្តឆ្នាំ 96 up $49.99+ ពាក់-មានជូនប័ណ្ណពិសេស សំរាប់ដូរប្រេង ចុះថ្លៃពាក់កណ្តាល នៅពេលយកមកជួសជុលអស់តម្លៃ $150.
-តម្លៃជួសជុលទូទៅ សមរម្យ ដោយទាបជាងហាងជួសជុលផ្សេងៗទៀត
- ប្តេជ្ញាចិត្តធ្វើជូនដោយហ្មត់ចត់ គុណភាពខ្ពស់ មិនឱ្យខុសបំណងលោកអ្នកឡើយ ។
ពិសេស ជួយទៅពិនិត្យដល់កន្លែងនូវរថយន្តណាដែលខូច STARTER ឬធុងអាគុយអស់ភ្លើងដោយឥតគិតថ្លៃ ។ *សូមអរគុណ !*

5105 N.2ND ST., PHILADELPHIA, PA 19120. TEL: (215) 329-2418
Fax: (215) 329-2419.Rath CELL: (215) 431-6376

## (តមកពីទំព័រទី០១) ស្តាប់លោកឯកអគ្គរាជទូតខ្មែរ...

អង្គាសប្រាក់ ទៅធ្វើជាអំណោយដល់យុទ្ធជនខ្មែរ នៅប្រាសាទព្រះវិហារ កាលពីថ្ងៃទី២៣ សីហា ឆ្នាំ២០០០៨ ស្តីពីព្រឹត្តិការណ៍ទំនាស់រវាងខ្មែរ និង ថៃ នៅតំបន់ប្រាសាទព្រះវិហារ យ៉ាងដូច្នេះថា :

ការចូលរួមរបស់អស់លោក លោកស្រី នៅថ្ងៃនេះ បង្ហាញនូវទឹកចិត្តដ៏ស្មោះសរ និងទឹកចិត្តស្នេហាជាតិ ចំពោះមាតុភូមិដ៏មហាបវររបស់យើង បើទោះបីជាបងប្អូនមករស់នៅសហរដ្ឋអាមេរិក នេះទៅហើយក៏ដោយ ។

ខ្ញុំជាឯកអគ្គរដ្ឋទូតប្រចាំនៅ អ.ស.ប ខ្ញុំបានប្រឡូកផ្ទាល់នូវការងារបញ្ហាប្រាសាទព្រះវិហារនេះ... លោក លោកស្រី បានដឹងរួចមកហើយនៅប្រមាណសប្តាហ៍កន្លងមកនេះ បញ្ហាប្រាសាទព្រះវិហារ និងតំបន់ជុំវិញព្រះវិហារ គឺជាការទាមទាររវាងព្រះរាជាណាចក្រកម្ពុជាយើង និងព្រះរាជាណាចក្រថៃ តាំងពីដើមសតវត្សទី២០មក ។ កាលពីយើងនៅសម័យអាណាព្យាបាលបារាំង បារាំង និងសៀម បានចុះហត្ថលេខាជាមួយគ្នា នៅឆ្នាំ ១៩០៤ បន្ទាប់មកទៀត ១៩០៧ ទាក់ទងទៅនឹងការកំណត់ព្រំដែននៃប្រទេសទាំងពីរ ហើយដល់ពេលយើងបានឯករាជ្យឆ្នាំ១៩៥៣ ពេលបារាំងដកទ័ពថយចេញពីកម្ពុជា សៀមក៏បានចូលមកកាន់កាប់ប្រាសាទព្រះវិហារ ពេលនោះខ្មែរបានធ្វើលិខិតតវ៉ា ឱ្យសៀមប្រគល់ព្រះវិហារមកឱ្យខ្មែរវិញ បន្ទាប់ពីការកាន់កាប់ខុសច្បាប់នាពេលនោះ ។ នៅឆ្នាំ១៩៦២ តុលាការក្រុងឡាអេ បានកាត់សេចក្តី ហើយបានប្រគល់ជូនកម្ពុជាវិញនូវប្រាសាទព្រះវិហារ នៅក្នុងសាលក្រមថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៦២ តាំងពីពេលនោះមកសៀមក៏បានដកទ័ពចេញពីព្រះវិហារ ។

ថ្មីនេះកម្ពុជា បានទទួលជោគជ័យយ៉ាងធំធេង ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាល ដែលមានសម្តេច ហ៊ុន សែន ជាប្រមុខ ដាក់ប្រាសាទព្រះវិហារនេះ ឱ្យទៅជាសម្បត្តិវប្បធម៌ពិភពលោក កាលពីខែកក្កដា ឆ្នាំ២០០៨ កន្លងទៅនេះ នៅកេបិច ប្រទេសកាណាដា ។ ការដាក់ចូលក្នុងបញ្ជី UNESCO នេះប្រទេសថៃគេមិនសប្បាយចិត្តទេ ពួកជ្រុលនិយមថៃមួយចំនួន បានប្រឆាំងនឹងការដាក់ចូលប្រាសាទព្រះវិហារ នេះ ជាបេតិកភណ្ឌអន្តរជាតិ ក៏ប៉ុន្តែ WORLD HERITATE COMMITEE បានសម្រេចកាលពីថ្ងៃទី៧ កក្កដា ២០០៨ គឺសម្រេចជាឯកច្ឆន្ទ គឺប្រទេសទាំង២១ បានគាំទ្រសំណើររបស់កម្ពុជាតែស្រុងតែម្តង គឺនៅពេលឯកឧត្តម ឧបនាយករដ្ឋមន្ត្រី សុខ អាន បានធ្វើសងគុណទៅគេ អង្គការហ្នឹងគេបានទះដៃអបអរសាទរយើងមែនទែន ហើយបន្ទាប់មកនៅពេលថៃឡើងថ្លែងការណ៍ម្តងវិញ គ្មាននរណាទះដៃមួយសោះ ថៃពេលនោះ បាក់មុខមែនទែន ។ ព្រឹត្តការណ៍បន្ទាប់មក គឺថ្ងៃ១៥ កក្កដា ២០០៨ ថៃបានចូលលុកលុយប្រាសាទព្រះវិហារ ដែលជាហេតុធ្វើឱ្យមានការតវ៉ា ហើយចរចាជាទ្វេភាគី

(តទៅទំព័រទី១៨)

កំណាព្យ

# " ពាក្យស្អិតមានបី "

***ដោយ : នាង សុវណ្ណតារា ( ឡូវែល)***

ពាក្យស្អិតមានបី    កុលបុត្រប្រុសស្រីត្រូវចងចាំ
ស្អិតមួយស្អិតចេក ដែលយើងញ៉ាំ    ស្អិតមួយចងចាំសិតសក់ថៃ ។
ស្និទ្ធមួយស្និទ្ធស្នេហ៍    បងប្អូនជាតិខ្មែរជិតដិតមេត្រី
ស្និទ្ធនឹងមនុស្សជិតដិតនឹងស្រី    ពាក្យស្អិតមានបីមួយស្អិតស្អាល ។

លោក សុវណ្ណតារា ជាគ្រូសិល្បះ នៅសមាគមខ្មែរឡូវែល លោកបានស្វាគមន៍ " ខ្មែរប៉ុស្តិ៍ " ដែលបានទៅដល់រដ្ឋ ម៉ាសាឈូសែត នាចុងខែសីហា ឆ្នាំ២០០៨ នេះ ជា មួយនឹងអត្ថបទសួនកំណាព្យរបស់លោក ។

យើងសង្ឃឹមថាលោកអ្នកអាននឹងប្រាស្រ័យទាក់ទងស្វែងរកភាពរីកចំរើននៃសមាគមខ្មែរយើងជាមួយនឹង " ខ្មែរប៉ុស្តិ៍ " ជាប្រាកដ ។ ប្រាស្រ័យទាក់ទងជាមួយខ្មែរប៉ុស្តិ៍ គឺមានទំនាក់ទំនងជាមួយសមាគមខ្មែរនៅឆ្នេរខាងកើតទាំងមូល ហើយក៏មានទំនាក់ទំនងជាមួយសមាគមខ្មែរ នៅឆ្នេរខាងលិច នៃសហរដ្ឋអាមេរិកខ្លះៗដែរ ដោយសារអត្ថបទខុសគ្នាប្រមាណ៣០% រវាងខ្មែរប៉ុស្តិ៍ នៃតំបន់ទាំងពីរនេះ ។

លោកអ្នកនឹងទទួលបានការធានាថា ខ្មែរប៉ុស្តិ៍ និយាយការពិតមិនញ្ញោះញ្ញង់ជីកកកាយស្រាវជ្រាវ ហើយជាពិសេសមិនលំអៀងទៅការពារអយុត្តិធម៌ ឬអំពើទុច្ចរិតណាមួយឡើយ ។ លោកអ្នកអានជាច្រើន សំដែងការចូលចិត្តអាន " ខ្មែរប៉ុស្តិ៍ " នេះ គឺជារង្វាន់ដ៏ថ្លៃថ្លាជូនដល់សមាគមខ្មែរយើងវិញ ហើយជាពិសេសលើកទឹកចិត្តដល់កិច្ចការយើង " ជាអ្នកនាំសារ " យ៉ាងជ្រាលជ្រៅ ។ លោកអ្នកនៅទីឆ្ងាយលំបាកមកទទួល " ខ្មែរប៉ុស្តិ៍ " នៅទីប្រជុំជន សូមអញ្ជើញស្នើរឱ្យយើងផ្ញើ " ខ្មែរប៉ុស្តិ៍ " រៀងរាល់លេខដល់អាស័យដ្ឋានលោកអ្នកក៏បាន ។

" ដៃពីរជីវិតមួយ " ជារូបមន្តនៃដៃម្ខាងផលិត នៃម្ខាងទៀតគាំទ្រ ទើបឆាកជីវិតនៃសមាគម " ខ្មែរសម័យថ្មី " ដែលអណ្តែតនៅលើសមុទ្រអាមេរិកនេះបាន ។

**ខ្មែរប៉ុស្តិ៍**

**Washington Wellness Care** មន្ទីរថែរក្សាខ្លួនប្រាណ "វ៉ាស៊ីនតុន"
Medical & Rehab.
ដោយវិជ្ជាពេទ្យ និងការបង្ហាត់រាងកាយឱ្យដើរឡើងវិញ

Medical & Rehab.
500 Washington Ave., 1st Fl.
Philadelphia, Pa 19147
Phone: 215.551.6838. Fax: 215.551.6718

**Dr. Scott C. Tran, D.C. Dr. Michael Barno, D.C. Dr. Zohar Stark, M.D.**

***We are specialized in treating:***

- Auto Accident Injuries - Work Related Injuries - Slip & Fall Injuries

**យើងមានជំនាញក្នុងការព្យាបាល :**

☞ របួសដោយគ្រោះថ្នាក់រថយន្ត ☞ របួសដោយទាក់ទងនឹងកន្លែងធ្វើការ ☞ របួសដោយរអិល ឬដួល

We have staffs who speaks Vietnamese, Chinese, and Cambodian
For Cambodian and Vietnamese Speaking Staff, please call Ricky Son at 215.380.1350
For English Speaking Staff, please call 215.551.6838

**យើងមានបុគ្គលិកដែលនិយាយភាសា វៀតណាម, ភាសាចិន , និងភាសាខ្មែរ**
ទាក់ទងជាមួយបុគ្គលិកខ្មែរ និងវៀតណាម សូមទូរស័ព្ទទៅ រីគី សុន (215) 380-1350
ទាក់ទងទៅបុគ្គលិកនិយាយភាសាអង់គ្លេស សូមទូរស័ព្ទទៅ (215) 551-6838

# កម្មករខ្មែរធ្វើការងារសំណង់កាន់តែច្រើន

***ភ្នំពេញ, ខ្មែរប៉ុស្តិ៍ : ម៉ី សម្ផស្ស***

●●●ដោយសារតែការតស៊ូព្យាយាមអត់ធ្មត់ចំពោះការងារ និងការដកពិសោធន៍គ្នាទៅវិញទៅមកកម្មករខ្មែរដែលធ្វើការងារសំណង់នៅតាមបុរី ឬសំណង់ធំៗបានពង្រីកចំណេះដឹងកាន់



ការដ្ឋានសំណង់នៅរាជធានីភ្នំពេញ

តែខ្ពស់ និងអាចដណ្តើមការងារកាន់តែច្រើនពីកម្មករយួន ព្រមទាំងមានជំនាញច្បាស់លាស់ទៀតផង ។

កាលពីជាង១០ឆ្នាំមុន កម្មករក្នុងវិស័យសំណង់ភាគច្រើនជាជនជាតិយួន ប៉ុន្តែពេលនេះកម្មករខ្មែរបានចូលធ្វើការក្នុងវិស័យនេះកាន់តែច្រើនហើយ ។

ជាពិសេសនោះ ពួកគេមួយចំនួនក្លាយជាអ្នកជំនាញមានសមត្ថកិច្ចខ្ពស់ មើលការងារនៅតាមការដ្ឋានសំណង់មួយចំនួនថែមទៀតផង ។

ក្នុងពេលបំពេញការងារដែលមានសំលៀក-បំពាក់សុទ្ធតែដី និងខ្លួនបែកញើសជោកនោះ លោក ឡេង ម៉ៅ អាយុ៤២ឆ្នាំ ដែលមានស្រុកកំណើតនៅភូមិពាមរាំង ឃុំពាមរាំង ស្រុកលើកដែក ខេត្តកណ្តាល បានឱ្យដឹងថា កាលពីមុនគាត់ដើរធ្វើការងារសំណង់ស្ទើរគ្រប់ទីកន្លែង ហើយគ្មានជំនាញអ្វីក្នុងខ្លួនអ្វីទេ ហើយត្រូវមេការសំឡុតគំរាមកំហែងតាមអំពើចិត្ត ។

លោក ឡេង ម៉ៅ បានបន្តថា ដោយសារការតស៊ូព្យាយាមរយៈពេលជាង១០ឆ្នាំ និងការរៀនលួចចំណេះពីកម្មករយួននោះ គាត់ក៏មានជំនាញអាចរៀបឥដ្ឋការ៉ូ ធ្វើក្បាច់ផ្សេងៗ បានយ៉ាងរហ័សទាន់ចិត្ត ហើយទទួលបានប្រាក់កំរៃខ្ពស់ជាងមុន ។

កម្មករជំនាញរូបនេះបានបន្តថា ការងារសំណង់មានតែជនជាតិយួនទេដែលធ្វើបានល្អ ហើយរហ័សដែលជាទីពេញចិត្តរបស់ម្ចាស់គេខ្លាំងណាស់ ។ ប៉ុន្តែសព្វថ្ងៃនេះកម្មករខ្មែរយើងក៏អាចធ្វើបានប្រកួតប្រជែងដណ្តើមទីផ្សារលើវិស័យសំណង់នេះកាន់តែច្រើន ហើយទទួលបានការគាំទ្រជាបណ្តើរៗផងដែរ ។

ក្នុងការដ្ឋានបុរីសន្តិភាព លោក លី ម៉េងហុង អាយុ៣៨ឆ្នាំ ជាអ្នកម៉ៅការសំណង់បានឱ្យដឹងថា គាត់ក្លាយខ្លួនជាអ្នកម៉ៅការសំណង់នេះ ជាង១០ឆ្នាំហើយ ដែលតាមការសង្កេតរបស់លោកពីដើមពិតជាមានកម្មករយួនច្រើនមែន ប៉ុន្តែសព្វថ្ងៃហាក់ដូចជាមានការថយចុះហើយ ។

លោក លី ម៉េងហុង បានបន្តថា កម្មករខ្មែរសព្វថ្ងៃនេះចេះរៀបការ៉ូ បូក ចាក់គ្រឹះកាន់តែច្រើនគួរឱ្យកត់សំគាល់ ។ ចំណែកការថយចុះនៃកម្មករយួននោះ គឺវាបណ្តាលមកពីកត្តាមួយចំនួនដូចជា ទី១.កម្មករខ្មែរមានសមត្ថភាព អាចប្រកួតប្រជែងលើវិស័យសំណង់បាន និងទី២



កម្មករខ្មែរកំពុងតែបូកស៊ីម៉ង់ និងរៀបឥដ្ឋ



កម្មករយួនស៊ីថ្លៃជាងកម្មករខ្មែរពាក់កណ្តាលសំរាប់រយៈពេលដូចគ្នា ។ ឧទាហរណ៍ ការរៀបការ៉ូកម្មករយួនមួយថ្ងៃស៊ីឈ្នួលពី១០ ទៅ១៣ដុល្លារ ចំណែកកម្មករខ្មែររយៈពេលដូចគ្នានេះបានត្រឹមតែ៥ទៅ៦ដុល្លារប៉ុណ្ណោះ ។

អ្នកម៉ៅការរូបនេះបានបន្តថា ចំនួនកម្មករយួនថយចុះនេះក៏អាចថាបាន ហើយបើវាកើនឡើងក៏ថា ពីព្រោះសព្វថ្ងៃវិស័យសំណង់រីកព្រោងព្រាត ។ ដូច្នេះគេពិបាកវាយតំលៃថាកម្មករយួនថយចុះក្នុងវិស័យនេះណាស់ ។

សំរាប់លោក យ៉ុង មេជាងយួនដែលមានបទពិសោធន៍ផ្នែកសំណង់ប្រមាណជាង២០ឆ្នាំ សព្វថ្ងៃរស់នៅភូមិសែនសុខ១ សង្កាត់ឃ្មួញ ខណ្ឌឫស្សីកែវ ក្រុងភ្នំពេញ បានឱ្យដឹងថា កាលពីប៉ុន្មានឆ្នាំមុនកម្មករសំណង់ភាគច្រើនជាជនជាតិយួនមែន ពីព្រោះពួកយើងមានជំនាញនេះស្ទើរគ្រប់ៗគ្នា ដែលរៀនតាមរយៈពួកបារាំងចិន ជាច្រើនជំនាន់មកហើយ ។

មេការសំណង់យួនបានបន្តថា មូលហេតុដែលកម្មករយួនមើលទៅតិច ហើយខ្មែរកើនឡើងនេះ ដោយសារតែពីមុនខ្មែររវល់ធ្វើស្រែចំការ រកត្រីនៅតាមខេត្ត-ក្រុងដែលខ្លួនរស់នៅ។ ប៉ុន្តែសព្វថ្ងៃនេះបងប្អូនខ្មែរភាគច្រើនបានលក់ដីស្រែអស់ហើយ គ្មានអ្វីទីពឹងក៏រត់មកទីក្រុងភ្នំពេញ ដើម្បីធ្វើសំណង់ចិញ្ចឹមជីវិតដែរ ។

មេការសំណង់រូបនេះបន្តថា កម្មករខ្មែរដែលមកធ្វើការដំបូងគ្មានធ្វើអ្វីក្រៅពីសែងថ្មលាយស៊ីម៉ងត៍ ចងដែក ដែលជាការងារធ្ងន់ធ្ងរនោះទេ ។ ប៉ុន្តែក្រោយមកទើបពួកគេហាត់រៀនជាបណ្តើរៗបានចំពោះអ្នកក្លាយជាមេការនៅតាមការដ្ឋាននានា ។

ចំពោះលោក ប៉ុល ចាន់ធី ម្ចាស់ភូមិគ្រឹះនៅភូមិបឹងបាយ៉ាប សង្កាត់ភ្នំពេញថ្មី ខណ្ឌឫស្សី-កែវ ក្រុងភ្នំពេញ និយាយថា កម្មករខ្មែរមានជំនាញផ្នែកវិស័យសំណង់កាន់តែច្រើន សំរាប់គាត់បានជួលកម្មករខ្មែរធ្វើផ្ទះ ពីព្រោះកម្មករខ្មែរ ក៏ធ្វើការងារលឿនស្អាតល្អគួរឱ្យពេញចិត្តដូចកម្មករយួនដែរ ។

លោក ប៉ុល ចាន់ធី បន្តថា មូលហេតុដែលគាត់ជួលកម្មករខ្មែរដោយសារបញ្ហាម្យ៉ាងទៀតគឺពួកខ្មែរយើងក៏មានបទពិសោធន៍លើវិស័យសំណង់នេះដែរ ។

លោក ប៉ុល ចាន់ធី បញ្ជាក់ថា កម្មករខ្មែរក្នុងរយៈពេលខាងមុខនឹងមានសមត្ថភាពអាចប្រកួតប្រជែងលើវិស័យសំណង់នេះកាន់តែ ខ្លាំង ហើយលោកសូមកោតសរសើរចំពោះការព្យាយាមរបស់កម្មករដែលអាចដណ្តើមការងារពីវិស័យនេះកាន់តែច្រើនគួរជាទីមោទនៈខ្លាំងណាស់ ។

អ្នកស្រី យឹម សុគន្ធ ប្រពន្ធអ្នកម៉ៅការសំណង់នៅបូរីភ្នំពេញ បានឱ្យដឹងថា សំរាប់ការដ្ឋានរបស់គាត់ កម្មករខ្មែរនិងយួន គឺគាត់ឱ្យតម្លៃដូចគ្នា ។ អ្នកស្រី បានបញ្ជាក់ថា កម្មករខ្មែរឥឡូវមានជំនាញនិងទឹកដៃខ្ពស់ដូចកម្មករយួនដែរ ដូច្នេះគាត់ត្រូវតែឱ្យតម្លៃស្មើគ្នា ។

អ្នកស្រី មិត្ត សុខទី ម្ចាស់គ្រឿងសង្ហារិម (តុ ទូ កៅអី) នៅមុំផ្សារដេប៉ូ ខណ្ឌ៧មករា ក្រុងភ្នំពេញ បានទទួលស្គាល់ថា កម្មករយួនពិតជាមានការថយចុះលើវិស័យសំណង់មែន ប៉ុន្តែអ្នកស្រី បានអះអាងថា កម្មករយួនបានកើនឡើងផ្នែកគ្រឿងចំលាក់ឈើ តុទូ គ្រឿងសង្ហារិម នៅពាសពេញស្រុកខ្មែរ ។

អ្នកស្រីបន្តថា មិនថាតែការ ច្នៃគ្រឿងសង្ហារិមទេ ផ្នែកចំលាក់មាសប្រាក់ ការងារជាងទង(ធ្វើខ្សែដៃ ក្រវិល ចិញ្ចៀន...) កម្មករយួនច្រើនណាស់ ហើយពួកគេមានទឹកដៃខ្ពស់ មានការទទួលស្គាល់ពីអ្នកប្រើប្រាស់គ្រប់ៗគ្នា ។ មិនថាផ្ទះគាត់ទេ សូម្បីតែផ្ទះអ្នកលក់គ្រឿងសង្ហារិមភាគច្រើន គឺសុទ្ធតែកម្មករយួន ទោះបីជាពួកគេស៊ីថ្លៃបន្តិចក៏ដោយ ។

មន្ត្រីអង្គការពលកម្មអន្តរជាតិ (ILO) មួយរូបបានឱ្យដឹងថា កម្មករជំនាញខ្មែរបានធ្វើការបណ្តុះបណ្តាលជាបន្តបន្ទាប់ជារៀងរាល់ឆ្នាំ ហើយ កម្មករខ្មែរបានក្លាយទៅជាអ្នកជំនាញលើវិស័យសំណង់កាន់តែច្រើន គឺភាគច្រើនបានក្លាយទៅជាអ្នកមើលការងារនៅតាមការដ្ឋានសំណង់ ស្ទើរគ្រប់ទីកន្លែងទូទាំងប្រទេស ។

ប្រភពខាងលើបញ្ជាក់ថា នេះជារឿងមួយមានមោទនភាពណាស់សំរាប់កម្មករជំនាញខ្មែរដែលមានសមត្ថភាពប្រកួតប្រជែងលើទីផ្សារសេរី ហើយរកប្រាក់ចំណូលបានច្រើនជាងមុនទៀតផង ។

គួរបញ្ជាក់ថា នៅប្រទេសកម្ពុជាមានជនជាតិយួនប្រមាណ២លាននាក់ ដែលកំពុងរស់នៅលើទឹកដីកម្ពុជា ដែលភាគច្រើនខុសច្បាប់ ហើយពួកគេដណ្តើមការងារពីប្រជាជនខ្មែរយើង ៕


ភោជនីយដ្ឋាន ណាម វ៉ាង (ភ្នំពេញ)
Nam Vang Restaurant
571 Unit # 1 Adams Avenue. Philadelphia, Pa 19120
(inside Hong Kong Market)
(215) 742-9488
Open 7 days a week from 9 a.m. – 9 p.m.
បើក 7 ថ្ងៃក្នុងមួយអាទិត្យពីម៉ោង 9 ព្រឹក ដល់ 9 ល្ងាច

១_មុខជំនាញខាងម្ហូបខ្មែរយ៉ាងចំណាន ដូចជា:
☞គុយទាវភ្នំពេញ
☞គុយទាវ ឬមី-ខគោ
☞មីកន្ត្លាំង ឆារសាច់គោ
☞មីកន្ត្លាំងឆារគ្រឿងសមុទ្រ
☞បាយឆារគ្រប់មុខ
☞សាច់គោអាំង ចង្កាក់ ជាមួយជ្រក់ល្ហុង

២_មុខជំនាញម្ហូបវៀតណាមឈ្ងុយឆ្ងាញ់ ដូចជា:
☞នំបញ្ចុកទឹកត្រីពិសេស
☞នំបុ័ងបាតេ ឬសាច់គោអាំង
☞ខគោ នំបុ័ង ឬមី និងគុយទាវ
☞បាយសរសាច់ជ្រូកអាំង ឬសាច់មាន់អាំង



រៀងរាល់ថ្ងៃលោកអ្នកអាចពិសាទឹកក្រឡុកគ្រប់រស់ជាតិផ្លែឈើ ដូចជា :
ទុរេន ឬ អាវ៉ូកាដូ ហើយជាពិសេស មានទឹកអំពៅកិនស្រស់ៗ

# ប្រាសាទកោះកេរ្តិ៍អតីតរាជធានីខ្មែរ សម័យមហានគរ

***ព្រះវិហារ, ខ្មែរប៉ុស្តិ៍ : គឹម សារឿន***

•••ចាប់តាំងពីមានជំលោះព្រំដែននៅតំបន់ប្រាសាទព្រះវិហារលើជួរភ្នំដងរែកមក ទាហានសៀមបានព្យាយាមចល័តចុះឡើងតាមខ្សែក្រវាត់ព្រំដែនតាមទំនើងចិត្តនោះ ។ ពួកសៀមលោភលន់ខុសពីការពិតនោះ និងខ្លាចខ្មែរធ្វើការទាមទារប្រាសាទដែលបាត់ក្នុងសម័យសង្គ្រាមស៊ីវិល ហើយសង្ស័យខ្មែរប្រើប្រាស់ផែនទីមាត្រដ្ឋាន ១/២០០.០០០ ទទួលស្គាល់ដោយអន្តរជាតិមានប្រទេសអង់គ្លេស អាមេរិក និង បេរ៉ូ ។



ប្រាសាទកោះកេរ្តិ៍អតីតរាជធានីខ្មែរ

ក៏បានឆ្លៀតឱកាសនេះចូលមកកាន់កាប់ប្រាសាទតាមាន់តូច និងប្រាសាទតាមាន់ធំ ហើយចរចាឱ្យខ្មែរយើងដកកងទ័ពចេញទើបគេដកកងទ័ពដែរ ទោះបីជាមានការសន្យាគ្នាថា ដកកងទ័ពចេញកន្លងមកយ៉ាងណាក៏ដោយ ។

ក្នុងពេលកំពុងតែមានភាពតានតឹងនោះ អ្នកប្រវត្តិសាស្ត្រសៀមជ្រុលនិយមម្នាក់ឈ្មោះ លោក ថេប មុនទ្រី លិបប៉ាក់យ៉ូម ក៏បានអំពាវនាវឱ្យរដ្ឋាភិបាលគេដាក់ពង្រាយកងទ័ពតាមព្រំដែនឱ្យបានច្រើន និងការពារប្រាសាទបុរាណខ្មែរទាំងឡាយណាដែលសៀមដណ្តើមបានកាលពីសម័យសង្គ្រាមស៊ីវិល កុំឱ្យខ្មែរចូលទៅជាដាច់ខាត ។

ប្រាសាទបុរាណដែលពួកសៀមប៉ុនប៉ងយាយីនោះ គឺប្រាសាទព្រះវិហារ ប្រាសាទតាមាន់តូច ប្រាសាទតាមាន់ធំ និងប្រាសាទស្តុកកក់ (បច្ចុប្បន្នសៀមយកបាត់ហើយ) និងប្រាសាទកោះកេរ្តិ៍ ស្ថិតនៅលើទឹកដីខេត្តព្រះវិហារ ជាអតីតរាជធានីសម័យមហានគរ និងត្រូវបញ្ចូលជាបញ្ជីបេតិកភណ្ឌពិភពលោកនៅពេលខាងមុខ ។

ប្រាសាទកេរ្តិ៍ មានឈ្មោះដើមថា "ឆកគតី" ស្ថិតនៅក្នុងភូមិស្រយ៉ង់ជើង ឃុំស្រយ៉ង់ ស្រុកគូលែន ដែលកសាងក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៤ គ.ស៩២១-៩៤១ សម័យមហានគរមានកំពស់៣៥ម៉ែត្រ មាន៧ជាន់ រាងដូចពីរ៉ាមីត ដើម្បីឧទ្ទិសថ្វាយ ចំពោះលទ្ធិព្រហ្មញ្ញសាសនា ។

នៅបរិវេណអតីតរាជធានីកោះកេរ្តិ៍ មានប្រាសាទបុរាណតូចធំ ភាគច្រើនខូចខាតទ្រង់ទ្រាយដើម ដែលបុព្វបុរសយើងកសាងឡើងដើម្បីឧទ្ទិសថ្វាយចំពោះសាសនា ព្រលឹងបុព្វការីជន និងជាដំណាក់របស់ព្រះរាជា ។ កេរដំណែលទាំងនេះ ត្រូវបានអាជ្ញាធរជំនាញអភិរក្សជារមណីយដ្ឋានសំរាប់ទាក់ទាញភ្ញៀវទេសចរឱ្យទៅទស្សនាជាហូរហែ ។

លោក មុនទ្រី លិបប៉ាក់យ៉ូម ដែលមានចិត្តអ្នកប្រវត្តិសាស្ត្រនោះដឹងច្បាស់ថា ផែនទីនេះតុលាការយុត្តិធម៌អន្តរជាតិបានសំរេចប្រគល់ប្រាសាទព្រះវិហារនៅថ្ងៃទី១៥ ខែមិថុនា ១៩៦២ ស្ថិតនៅក្រោមអធិបតេយ្យរបស់ខ្មែរ ហើយប្រាសាទតាមាន់តូច និងប្រាសាទតាមាន់ធំនៅស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យជារបស់ខ្មែរ ។ ចំណែកប្រាសាទស្តុកកក់ធំដែលសៀមយកក្នុងខេត្តស្រះកែវ ជាប់ខេត្តបន្ទាយមានជ័យ បើផ្អែកតាមមាត្រដ្ឋានផែនទី ១/២០០.០០០ ក៏ជារបស់ខ្មែរដែរ ។

បើតាមឯកសារស្ថាននាមវិទ្យារបស់លោកបណ្ឌិត ឡុង សៀម អតីតសាស្ត្រាចារ្យនៅរាជបណ្ឌិតសភាកម្ពុជាបានឱ្យដឹងថា ប្រាសាទស្តុកកក់ធំ មានចារឹកជាអក្សរខ្មែរបុរាណនៅខ្លោងទ្វារ និងជញ្ជាំងប្រាសាទយ៉ាងច្បាស់ ប៉ុន្តែសៀមបានរំលោភយកយ៉ាងកំរោលនៅទសវត្សឆ្នាំ៨០ ។

ចាប់តាំងពីអង្គការយូណេស្កូដាក់បញ្ចូលប្រាសាទព្រះវិហារជាសម្បត្តិបេតិកភណ្ឌពិភពលោក កាលពីថ្ងៃទី៧ ខែសីហា ឆ្នាំ២០០៨ មកពួកសៀមដែលមានគំនិតឈ្នានីស មិនចង់ឱ្យខ្មែរមានឈ្មោះខ្ទរខ្ទ័រលើឆាកអន្តរជាតិនោះ បានប្រើល្បិចកលផ្សេងៗឈ្លានពានមកលើខ្មែរ និងលើកកងទ័ពមកឡោមព័ទ្ធប្រាសាទបុរាណខ្មែរ គ្មានការអៀនខ្មាស ។

ចំណែកប្រាសាទកោះកេរ្តិ៍ដែលស្ថិតនៅក្នុងទឹកដីនៃខេត្តព្រះវិហារ ចូលជ្រៅពីខ្សែបន្ទាត់ព្រំដែន ហើយត្រូវបានអង្គការយូណេស្កូសំឡឹងឃើញថា មានលក្ខណៈសម្បត្តិអាចចុះបញ្ជីបេតិកភណ្ឌនៅពេលខាងមុខ ពួកសៀមមិនអាចឈ្លានពានដូចប្រាសាទព្រះវិហារបានទេ គឺបានត្រឹមតែបំផុសឱ្យប្រជាពលរដ្ឋខ្លួនទៅទស្សនាប៉ុណ្ណោះ ។

សិលាចារឹកនៅប្រាសាទស្តុកកក់ធំ បានបញ្ជាក់ថា

(តទៅទំព័រទ១៤)

(តមានពីទំព័រ០៣) **បទសម្ភាសន៍លោក ខៀវ សំផន...**

ដើម្បីនឹងបាញ់គ្នាវិញ" ដើម្បីដកឃ្លាក់ទេចកំលាំងជាតិ ! ចាញ់ហើយប្រើរដ្ឋ អំណាចប្រើកាំភ្លើងដែលយួនកុម្មុយនីស្តវានៅ រក្សានៅកម្ពុជា ដើម្បីរំលោភការបោះឆ្នោត រំលាយការឈប់បាញ់គ្នាហើយបកមកវិញសម្លាប់ អ្នកកាសែតខ្មែរ, សម្លាប់សមាជិកហ្វ៊ុនស៊ិនប៊ិច, សម្លាប់ប្រជាជនបាតុករថ្ងៃទី៣០ មិនា នៅសភា, មកដល់ធ្វើរដ្ឋប្រហារថ្ងៃទី៥-៦ កក្កដា តើអ្នកណាធ្វើ ? និយាយឱ្យច្បាស់ទៅមិនមែន ហ៊ុន សែន ទេ គឺយួនកុម្មុយនីស្ត គឺកំលាំងយួន ដែលវាបង្កប់នៅក្នុងមនុស្សយួនកម្លាំងនេះដែលដើរឱ្យធ្វើរដ្ឋប្រហារ មានន័យថាម៉េចអាហ្នឹងហើយ ដែលមានន័យថា បន្តសង្គ្រាមឡើងវិញ បាញ់ឡើងវិញ ! បាញ់ ឬមិនបាញ់? សម្តេចក្រុមព្រះរត់ចេញចង់មិនទាន់ផង លោក ញឹក ប៊ុនឆៃ រត់ចេញនៅ សល់តែខោខ្លី អាហ្នឹងបាញ់ឡើងវិញ ឬឈប់បាញ់ ដើម្បីសន្តិភាព ដើម្បីផ្សះផ្សាជាតិហើយឈប់បាញ់ ដើម្បីឱ្យយួនកុម្មុយនីស្ត រក្សារដ្ឋអំណាចអាយ៉ងរបស់ខ្លួន ហើយលក់ទឹកដីកម្ពុជា បែងជាក្រឡាលក់ឱ្យឈ្មួញបរទេសទុច្ចរិតតាមចិត្ត អាគករសម្លាប់ប្រជាជនកម្ពុជាដែលជាម្ចាស់ទឹកដី ធ្វើឱ្យប្រជាជនកម្ពុជា ខ្ចាត់ព្រាតចេញពីផ្ទះសម្បែងរបស់ខ្លួន ចេញពីភូមិចំការរបស់ខ្លួនរសាត់អណ្តែត ទៅជាដើរសុំទានគេពាសពេញភ្នំពេញ ពាសពេញតាមខេត្ត និងពាសពេញផ្ទៃប្រទេសទៅកាយធុងសំរាមដើម្បីរើរកកាកសំណល់រលួយខ្ទក់របស់គេ ដើម្បីយកមកហូបដើម្បីកុំឱ្យស្លាប់ឆាប់ ឈប់បាញ់របៀបហ្នឹងតើប្រជាជនកម្ពុជាទទួលបានទេ ច្បាស់ហើយទទួលមិនបានទេ! មិនមែនតែខ្ញុំទេ! ខ្ញុំអ្នកថា ប្រជាជនកម្ពុជាទទួលមិនបានទេ! ព្រះមហាក្សត្រពេលដែលលោកយាងមកសៀមរាប លោកបានមានបន្ទូលហើយថា បើរៀបចំរបៀបហ្នឹង ច្បាស់ជាបដិវត្តន៍ កសិករមួយទៀតហើយ។ ខ្ញុំក៏មិនត្រូវការអីជាអ្នកបដិវត្តន៍អីដែរ ដូចលោកជ្រាបហើយខ្ញុំជាបញ្ញាជនមួយដែលធ្លាប់រៀន នៅលោកខាងលិចមិនមែនជាអ្នកបដិវត្តន៍អីនោះទេ គ្រាន់តែខ្ញុំនិយាយនេះ ដោយខ្ញុំឃើញអញ្ចឹង បើតែដោះស្រាយរបៀបហ្នឹងវាអត់បញ្ចប់សង្គ្រាម ទេខ្ញុំចង់និយាយអញ្ចឹង ! ហើយនេះមិនមែនខ្ញុំជាអ្នកនិយាយទេ ព្រះមហាក្សត្រក៏លោកមានបន្ទូលនេះហើយបញ្ជាក់នូវភាពជាក់ស្តែងវាអញ្ចឹង ហើយប្រជាកសិករឱ្យប្រជាជនដែលអស់ដីធ្លី ផ្ទះសម្បែងអស់គោក្របី ទៅដេកអោបដៃស្លាប់ ម្តេចបានគេច្បាស់ជារកផ្លូវរស់ ហើយបើគេរកផ្លូវរស់ដោយសេរីភាពនោះវាមិនបានផ្លូវរស់ ដោយតស៊ូតាមរូបភាពផ្សេងៗ ហើយបើអញ្ចឹង កុំចោទអ្នកតស៊ូថាជាអ្នកស្វែងរកសង្គ្រាម កុំចោទថា ប្រឆាំងការផ្សះផ្សាជាតិបន្តសង្គ្រាម បញ្ឆេះសង្គ្រាម អានេះទើបវាត្រូវជាងទើបរកបុគ្គលនៃបញ្ហាវាឃើញ បើវាមិនអញ្ចឹងទេវារក មិនឃើញទេ។

**សំនួរ** : លោកមានតួនាទី ជាអ្វីដែរនាពេលនេះ? ជាប្រមុខរដ្ឋដូចមុនដែរ មែនឬទេ?

**ចំលើយ** : ខ្ញុំមិនមែនប្រមុខរដ្ឋអីទៀតទេ ហើយខ្ញុំជាអ្នកហត្ថលេខាលើកិច្ចព្រមព្រៀងក្រុងប៉ារីស ម្យ៉ាងទៀត ចុះហត្ថលេខាក្នុងនាមខ្ញុំ ខៀវ សំផន ដែលត្រូវការបញ្ឈប់សង្គ្រាមយួនកុម្មុយនិស្តឈ្លានពាន ដោយសន្តិភាពឱ្យបានរហ័ស ដើម្បីឱ្យមានការផ្សះផ្សាជាតិរវាងទំនាស់នៅក្នុងសង្គមកម្ពុជា រវាងខ្មែរគ្នាឯង។ យើងដោះស្រាយតាមរបបប្រជាធិបតេយ្យបោះឆ្នោតសេរី របបសភាមានគណបក្សច្រើន ខ្ញុំក៏បានត្រៀមរៀបចំជាមួយនិងមិត្តភាពរបស់ខ្ញុំមួយចំនួនទៀត ដើម្បីបង្កើត "គណបក្សសាមគ្គីជាតិ" ទាំងជាតិ និងប្រជាជនកម្ពុជាទាំងមូលជ្រាបហើយ សកលលោកក៏ជ្រាបហើយដែរ យើងខ្ញុំបានត្រៀមរៀបចំយ៉ាងនេះដោយមានជំនឿផង ដោយចង់បានជាជម្រៅចិត្តរបស់ខ្ញុំ មិត្តភក្តិ និងសហការីរបស់ខ្ញុំ ចង់ឱ្យមានការបញ្ឈប់សង្គ្រាម ដើម្បីថ្ងៃក្រោយ គណបក្សសាមគ្គីជាតិចូលរួមក្នុងនយោបាយរបស់ជាតិ នៅក្នុងក្របខណ្ឌសន្តិភាព និងក្របខណ្ឌផ្សះផ្សាជាតិតែប៉ុណ្ណោះ ។ ទាំងហ្នឹងវាបញ្ជាក់អ្វី ? វាបញ្ជាក់ថា ខ្មែរក្រហមមិនទៅស្វែងរកអំណាចលោភលន់អំណាច ឬលាភសក្ការៈអីទេ ចង់បានតែបញ្ចប់សង្គ្រាម ហើយចង់បានតែការផ្សះផ្សាជាតិ ហើយមិនត្រូវការរំលោភលួចអំណាចអីទេ គ្រាន់តែមានតួនាទីមួយក្នុងជីវិតនយោបាយរបស់ជាតិ រួមការពារពូជសាសន៍ថ្ងៃក្រោយ និងរួមចំណែកកសាងប្រទេសជាតិទៅថ្ងៃក្រោយ តាមការបញ្ចេញមតិក្នុងឋានៈជាគណបក្សនយោបាយមួយតែប៉ុណ្ណោះ ។

**សំនួរ** : អន្លង់វែង ឬខ្មែរក្រហម នៅតែក្រហម ជាពណ៌កុម្មុយនីស្តដូចមុនដដែល ឬក៏ផ្លាស់ប្តូរទៅហើយ ?

**ចំលើយ** : ក្រហមសំរាប់តែអ្នកគេហៅទេ (...ផ្ទុះសំណើច...) មិនមែនក្រហមទេ... ខ្ញុំបាននិយាយរួចហើយ ! កម្មវិធីរបស់យើងខ្ញុំ ដែលជាសំណូមពររបស់យើងខ្ញុំ ខ្ញុំបានជំរាបអម្បាញ់មិញហើយ គឺនៅក្នុងក្របខណ្ឌផ្សះផ្សាជាតិ បញ្ចប់សង្គ្រាម ហើយដោះស្រាយបញ្ហា ដែលត្រូវការដោះស្រាយរវាងខ្មែរ និងខ្មែរក្នុងក្របខណ្ឌរបបប្រជាធិបតេយ្យសេរី របបសភាបោះឆ្នោត ដែលប្រជាជនមានជំនឿលើ ឃើញថា មតិយោបល់របស់គណបក្សណាត្រឹមត្រូវជាងគេប្រជាជនបោះឆ្នោតឱ្យ សូម្បីអញ្ចឹងក៏ដោយ ក៏យើងខ្ញុំមិនត្រូវការអ្វី ដណ្តើមយកសម្លេងភាគច្រើនផ្តាច់មុខនៅក្នុងសភានោះទេ និងសូមជំរាប ឱ្យច្បាស់អញ្ចឹងគ្រាន់តែជាផ្នែកមួយឱ្យមានសិទ្ធិ មានមតិតាមការយល់ដឹងរបស់ខ្លួន ហើយដែលខ្លួនធ្លាប់ជាប់ជាមួយជាតិ និងប្រជាជនកម្ពុជា ៣០ឆ្នាំមកហើយ តែប៉ុណ្ណោះ ។

អត្ថបទផ្សាយដោយព្រឹត្តប័ត្តពលរដ្ឋសេរី
នៅទីក្រុងបាងកក ឆ្នាំ១៩៩៨

**រៀបរៀងដោយ :**
កំព្យូទ័រ : ថាន់ គុណ
ជំនួយការ : ទូត ចានីរ៉ា
ជំនួយការ : ពុត រ៉ារី
ជំនួយការ : យិន គីមសួរ
បច្ចេកទេស : រនា ថារដ្ឋ
**នាយកគ្រប់គ្រង :**
និពន្ធនាយក : ពិន សំខុន ៕




# វិធីថែស្បែកដោយរបៀបសាមញ្ញតែស្រស់ស្អាត

មិត្តនារីទាំងឡាយគ្រប់រូបតែងតែចង់បានផ្ទៃស្បែកស្រស់ថ្លា រាងកាយមាំមួន ឥឡូវនេះយើងខ្ញុំសូមរំលឹកប្រាប់មិត្តនារីទាំងឡាយថា គួរតែផ្ញើរជើងឱ្យបានច្រើន ហើយម្តងម្កាលអ្នកគួរផ្ញើរជើងទទេលើស្មៅដែលមានទឹកសន្សើមនៅពេលព្រឹកព្រលឹម បាតជើងយើងនឹងបឺតបានថាមពលរបស់ដី ។ ក្រោយមកអង្គុយលើកៅអីបិទភ្នែកវិញ ដើម្បីបន្ធូរអារម្មណ៍ ហើយត្រាំជើងទាំងពីរចូលកាធុនទឹកត្រជាក់ អ្នកនឹងមានអារម្មណ៍ថា មានចំហាយក្តៅភាយចេញពីបាតជើងឡើងដល់ក្បាល ។ ប្រសិទ្ធិភាពរបស់ការផ្ញើរជើង និងត្រាំជើង គឺការពង្រឹងរាងកាយស្វារតីឱ្យនឹងនរ ខ្លួនប្រាណមានកម្លាំងមាំមួន ។ ក្រោយពីប៉ុន្មានម៉ោងធ្វើការហេវហត់ មិត្តនារីទាំងឡាយគួរតែថែទាំស្បែកមុខដោយប្រភេទរបាំងមុខដោយច្នៃខ្លួនឯងរួមមាន :



- សាច់ស្វាយទុំ២ស្លាបព្រាកិនឱ្យម៉ដ្ឋ ។
- ទឹកក្រូចឆ្មារ២ស្លាបព្រាកាហ្វេលាយរបស់ទាំងនេះឱ្យសព្វ រួចបិទលើផ្ទៃមុខរង់ចាំឱ្យស្ងួត ហើយយកកន្សែងសើមជូតឱ្យស្អាត ។ ប្រភេទរបាំងមុខនេះមានប្រសិទ្ធិភាពធ្វើឱ្យរន្ធញើសតូចចំពោះមនុស្សទាំងឡាយមានអាយុច្រើនជាង៣០ឆ្នាំ ស្តារភាពស្រស់ថ្លារបស់ស្បែកឡើងវិញ ។
- នៅពេលនោះយើងគេងលក់ស្រួលបំផុត ។ មុនពេលឡើងលើគ្រែ អ្នកគួរឈ្លីចំណុចក្រហួងនៅកញ្ចឹងកតាមទិសម្ជុលនាឡិការហូតដល់វាក្តៅឧណ្ហៗ វានឹងធ្វើឱ្យអ្នកគេងលក់មួយរំពេច ។

***•បើចង់ថែទាំស្បែកខ្លួនយើងគួរប្រើប្រាស់វិធីមួយចំនួនដូចខាងក្រោមនេះ ÷***

- ស្លឹកផ្កាកុលាបស្រស់ពាគីឡូក្រាមដាក់ចូលផ្ទូដី ឬថ្ម (មិនប្រើផ្ទូលោហធាតុ ឬកែវ) ។ ចាក់ទឹកក្តៅចូលផ្ទូផ្អាប់ក្នុងរយៈកាល៣០នាទី (ដូចឆុងតែ) ច្រោះឱ្យស្អាតដោយស្បៃមុង ។ ចាក់ទឹកទាំងអស់នោះចូលអាងងូតទឹក ឬឈ្លីនៅលើទូទាំងខ្លួន បើសិនជាអ្នកងូតទឹកដោយផ្កាឈូក ។
- ទឹកដោះគោសម្បូរទៅដោយកាល់ស្យូមជួយប៉ូវឱ្យសុខភាពរឹងមាំ និងលើកសម្រស់ស្ត្រីឱ្យកាន់តែស្អាត ។ ក្រៅពីការប្រើសម្រាប់បរិភោគ ហើយទឹកដោះគោដែលបានពីធម្មជាតិនៅប្រើសម្រាប់ត្រាំខ្លួនឱ្យស្បែកស្រស់ស្អាតក្មេងខ្ចីទៀតផង ។ នៅក្នុងទឹកដោះគោមានលាយផ្សំទៅដោយអាស៊ីត "លេកជីក" និងប្រូតេអ៊ីនច្រើនមុខ ។ សារជាតិទាំងនេះជួយបង្កើតឱ្យស្បែករបស់យើងទន់ល្មើយ និងឡើងស្រស់ស្អាត ។

## ផលប្រយោជន៍របស់អំបិលសមុទ្រក្នុងការថែរក្សាសម្ផស្ស

អំបិលសមុទ្រទាំងឡាយ ពិសេស គឺអំបិលបានមកពីការធ្វើអាជីវកម្មពីសមុទ្រនោះ ត្រូវបានឃោសនាថា មានប្រសិទ្ធភាពព្យាបាលជម្ងឺផ្សេងៗអំពីសក់ និងស្បែក ។

**Spa ជាមួយអំបិល :** លាយអំបិលសមុទ្រទៅក្នុងទឹកនៅលក្ខណៈខាប់ៗ រួចយកជក់ជ្រលក់លាបខ្លួនប្រាណ លើកលែងតែកន្លែងស្បែកខ្ចី និងស្នាមរបួសមិនទាន់ជា ។ គេងសម្រួលអារម្មណ៍រយៈពេល១៥នាទី បន្ទាប់មកងូតសម្អាតក្រោយចំពួយទឹកផ្កាឈូកក្តៅឧណ្ហៗ ជាមួយនឹងការម៉ាស្សាស្រាលៗលើដងខ្លួន ។

**ការពារសក់ :** ប្រើអំបិលមួយក្តាប់តូច សាច់ជូរមួយច្បុចលាយជាមួយទឹកក្តៅឧណ្ហៗឱ្យរលាយ រួចចាក់លើស្បែកក្បាលម៉ាស្សារយៈពេល២ទៅ៣នាទី ។ យកកន្សែងស្អាតរុំសក់ផ្អាប់ទុករយៈពេលប្រមាណ១០នាទី បន្ទាប់មកលាងទឹកក្តៅឧណ្ហៗ ។ ស្បែកក្បាលនឹងអស់រមាស់ ហើយអង្គែបាត់បន្តិចម្តងៗ ក្រោយការអនុវត្តមួយលើកៗ ។ អ្នកអាចប្រើវិធីនេះមួយខែ២ដងសំរាប់សក់ធម្មតា ចំពោះសក់បែកចុង ឬអង្គែត្រូវអនុវត្តបន្តបន្ទាប់រហូតដល់ពេលបាត់ទាំងស្រុង ។

**សម្រួលអារម្មណ៍ជាមួយអំបិល :** ក្រោយបំពេញការងារនឿយហត់១ថ្ងៃ ចូរអ្នកចាក់អំបិលសមុទ្រកន្លះគីឡូក្រាមទៅក្នុងអាងមុជទឹកក្តៅឧណ្ហៗ ដើម្បីត្រាំខ្លួនសម្រួលអារម្មណ៍ក្រោយពេលបានងូតទឹកសម្អាត ដោយវិធីធម្មតា ។ ត្រាំខ្លួនបណ្តើរ ម៉ាស្សាស្រាលៗសព្វសារពាង្គកាយបណ្តើរ ។ បន្ទាប់មកជូតខ្លួនឱ្យស្ងួត ដោយមិនបាច់ងូតទឹកឡើងវិញ ។ ១សប្តាហ៍គួរអនុវត្តឱ្យបានម្តង ។

**ព្យាបាលមុន :** អំបិលមានប្រសិទ្ធភាពបំផុតក្នុងការព្យាបាលមុនគ្រប់ប្រភេទ ។ ក្រោយពេលសម្អាតស្បែក ប្រើអំបិលម៉ដ្ឋលាយទឹកបន្តិច ដើម្បីលាបសព្វផ្ទៃមុខ ។ ទុករយៈពេល៥នាទី រួចចាប់ផ្តើមម៉ាស្សាសន្សឹមៗឱ្យអំបិលជ្រុះចេញ បន្ទាប់មកលាងលសម្អាតទឹកក្តៅឧណ្ហៗ ។

# សហរដ្ឋអាមេរិក មានគូរប្រជែងក្នុង...

Of all the countries in the world, he mentioned only one in need of help. Why not Mauritania,

whose democratically elected leaders were recently ousted by a military coup? Why not Zimbabwe, where Robert Mugabe has made a total mockery of democracy by killing and jailing his opposition. No he chose Georgia, where Cindy McCain went the week before, along with Joe Lieberman and Sen. Lindsay Graham. You know she wasn't there to set up a beer distributorship. Georgia is the next big Iraq for the Republicans who need an international crisis to divert attention from the stagnant economy. Iraq had the world's second largest oil reserves. Georgia has the Baku-Tiblisi-Ceyhan pipeline. It's about oil again and driven by McCain's top foreign policy advisor, none other than the former registered lobbyist Randy Sheunemann whose lobbying firm received $800,000 from Georgia to assure its admission to NATO. Why NATO? Because if Russia attacks, NATO troops respond in kind. For what? For 850,000 barrels of oil a day, 1% of world oil consumption to start. McCain and Palin may not know anything about economics, but they sure know the Oil lobby's agenda. Exxon Mobile and Conoco Phillips want to drill in the Caspian Sea and feed their oil through the same pipeline. There is no limit to how McCain Palin will feed our addiction to oil and draw us into another conflict. Without enough troops to fight Russia for oil in Georgia, McCain & Palin will re-introduce the draft. He has admitted as much when asked how he would hunt down Osama Bin Laden, when our military is stretched so thin already. The Bush administration has been feeding money for weapons and a military build up in Georgia for years in return for Georgia being a member of the Coalition of the willing in Iraq. Yesterday, Bush promised another $1 billion to Georgia and even sent Dick Cheney to seal the deal. Democrats need to oppose the Sheunemann policy of engaging the U.S. in another war. It's enough that he contributed to the Neo-con policy paper that got us into war in Iraq. Now is the time to say "enough." We need Barack Obama and Joe Biden in the White House. Tsiwen Law, Philadelphia, Pa

# VP choices.

One of the important ways to judge a presidential candidate is by the company he (or she) keeps. This is why a candidate's choice of Vice President is critical. Just prior to the Democratic National Convention, Sen. Obama chose fellow Senator Joseph Biden of Delaware as his running mate. Biden is one of the most experienced Senators in foreign policy, which is an area of perceived weakness in Obama. Biden also has strong ties to Pennsylvania, a key battleground state. Biden was meant bring experience to the ticket without all of the baggage that would be brought by Sen. Clinton.




However, Biden has several serious drawbacks as a running mate. The choice of Biden belies the notion that Obama's campaign is really about change. Biden is an old hand; he has been in the Senate since 1973. His reputation on a national level has been mixed. He has run for president on two occasions and had several scandals, none of which were serious to end his career. His most recent presidential bid was cut short when he called Obama "the first mainstream African-American who is articulate and bright and clean and a nice-looking guy" which was widely viewes as a racially insensitive comment. As the current campaign continues, there may be more focus on Biden's relationship with the credit card companies located in Delaware. Specifically since the 1990 election, Delaware-based credit card company MBNA has given $214,100 to the senator, according to the nonpartisan Center for Responsive Politics. Such donations are believed to have influenced his vote on key legislation in the area of bankruptcy. So much for "new" politics.

Sen. McCain on the other hand shocked the country by choosing the unknown Governor of Alaska, Sarah Palin. McCain is a gambler; and he moved all of his chips to the center of the table in making this choice. Palin is something new to the political landscape of America. She is a cultural and fiscal conservative. The words "cultural and fiscal conservative" has usually meant: old, upper class and male. Palin is emphatically none of these. In addition she has shown that the Republican party can be the party of change and can, in fact, advance women to positions of power if the Democrats are not so inclined. What will happen? Who knows. All indications are that with Palin, McCain is holding an ace.

នាទី ប្រវត្តិសាស្ត្រ

# ទំព័រហ្វីឡាដែលហ្វីយ៉ា

# ពីរដ្ឋបាលកុលសម្ព័ន្ធមករដ្ឋាភិបាលសម័យ

**ដោយ : ពិនសំខុន** ***តពីលេខមុន***

. រដ្ឋមន្ត្រីពាណិជ្ជកម្ម-ឧស្សាហកម្ម និងទូរគមនាគមន៍ : វ៉ាយ លុត

. រដ្ឋមន្ត្រីយុត្តិធម៌ : ជួន សាត

. រដ្ឋលេខាធិការសង្គមកិច្ច និងកិច្ចការ កសិករ : ម៉ៅ ចយ

. រដ្ឋលេខាធិការសាធារណការ : មិនធុច

. រដ្ឋលេខាធិការអប់រំជាតិ : ជា អួម

. រដ្ឋលេខាធិការសាធារណសុខាភិបាល : មាស យ៉ង់

**ថ្ងៃទី១៤ មករា** : ធ្វើកម្រោងច្បាប់កែទំរង់រដ្ឋធម្មនុញ្ញ ឱ្យស្ត្រីមានសិទ្ធិបោះឆ្នោត បង្កើតសភា នៅខេត្តនីមួយៗ និងនៅក្រុង បង្កើតរបបរបជាធិបតេយ្យ ដោយមានការបោះឆ្នោតពាក់កណ្ដាលដោយចំពោះ ។

**ថ្ងៃទី២៧ មករា** : ច្បាប់មួយបានកំណត់ចំនួនសមាជិកសភាខេត្ត ដែលជាប់ឈ្មោះដោយការបោះឆ្នោតដោយចំពោ ការបោះឆ្នោតនឹងត្រូវធ្វើនៅក្នុងអំឡុងឆ្នាំដដែល សភានេះ បានពង្រីកការមិនសប្បាយម្ដងបន្តិចៗ ចំពោះនយោបាយអំណាចកណ្ដាល ។

**ថ្ងៃទី១១ កុម្ភៈ** : បង្កើតសាភូមិន្ទរដ្ឋបាល ។

**ថ្ងៃទី១៣-២១ កុម្ភៈ** : ទស្សនៈកិច្ចរបស់សម្ដេចនរោត្តម សីហនុ ទៅប្រទេសចិន-ប្រទេសរូស៊ី ។

**២-រដ្ឋាភិបាល អ៊ុម ឈាងស៊ុន (៥.១. ១៩៥៦)**

.នាយករដ្ឋមន្ត្រី-មន្ត្រីមហាផ្ទៃនិងបោសសម្អាត : អ៊ុម ឈាងស៊ុន

.រដ្ឋមន្ត្រីការពារជាតិនិងការពារលើផ្ទៃប្រទេស : ស៊ីសុវត្ថិ ស៊ីរិមមៈ

.រដ្ឋមន្ត្រីការបរទេស : ខៀវ វ៉ាន

.រដ្ឋមន្ត្រីហិរញ្ញវត្ថុ : ប្រាក់ សារិន

.រដ្ឋមន្ត្រីផែនការ-កសិកម្ម និងចិញ្ចឹមសត្វ : ផ្លែក ភីន

.រដ្ឋមន្ត្រីពាណិជ្ជកម្ម-ឧស្សាហកម្មនិងទូរគមនាគមន៍ : វ៉ាយ លុត

.រដ្ឋមន្ត្រីយុត្តិធម៌ : ជួន សាត

.រដ្ឋលេខាធិការសង្គមកិច្ចនិងកិច្ចការកសិករ : ម៉ៅ ចយ

.រដ្ឋលេខាធិការសាធារណការ : មិន ធុច

.រដ្ឋលេខាធិការអប់រំជាតិ : ជា អួម

.រដ្ឋលេខាធិការសាធារណសុខាភិបាល : មាស យ៉ង់

.រដ្ឋលេខាធិការព័ត៌មាន និងធម្មការ : ទ្រិញ វ៉ាញ

នៅក្នុងរដ្ឋាភិបាល លោក អ៊ុម ឈាង ស៊ុន នាដើមឆ្នាំ១៩៥៦-១៤

**មករា ឆ្នាំ១៩៥៦** អនុម័តច្បាប់ដ៏សំខាន់មួយផ្ដល់សិទ្ធិបោះឆ្នោតឱ្យស្ត្រីភេទ បង្កើតសភាតាមខេត្ត និងរាជធានី បង្កើតឱ្យមានលទ្ធិប្រជាធិតេយ្យពាក់កណ្ដាលចំពោះ ។

**២៧មករា** ច្បាប់បានកំណត់សហសភាពនៃសភាខេត្ត បោះឆ្នោតដោយពលរដ្ឋក្នុងខេត្ត...។ សភានោះ បានក្លាយនៅពេលប្រមូលផ្ដុំអំណាចនៅតែអង្គការកណ្ដាល ។

**១១កុម្ភៈ** បើកសាលារដ្ឋបាលជាលើកដំបូងបង្អស់ ។

**១៣-១២កុម្ភៈ** ទស្សនៈកិច្ចរបស់សម្ដេចនរោត្តម ស៊ីហនុ ទៅប្រទេសចិនប្រជាមានិតទៅសហភាពសូវៀត ទៅឆេកូស្លូវ៉ាគី ។ សេចក្ដីថ្លែងការណ៍រួមខ្មែរ-ចិន និងការផ្ដល់ជំនួយមកកម្ពុជា ដែលជាប្រទេសដំបូងបង្អស់ដែលចិន ជួយដល់ប្រទេសមិនមែនកុម្មុយនិស្ដ ។

**៣-រដ្ឋាភិបាល នរោត្តម សីហនុ (១.៣. ១៩៥៦ - ៣.៤.១៩៥៦)**

.នាយករដ្ឋមន្ត្រី-រដ្ឋមន្ត្រីការបរទេស និងមហាផ្ទៃ : នរោត្តម សីហនុ

.ឧបនាយករដ្ឋមន្ត្រី-រដ្ឋមន្ត្រីសន្តិសុខជាតិ-រដ្ឋមន្ត្រីទទួលបន្ទុកដឹកនាំប្រទេសនៃការិយាល័យ និងសេវាកម្មអមទីស្ដីការគណៈរដ្ឋមន្ត្រី : ឃីម ទិត

.រដ្ឋមន្ត្រីការពារជាតិ និងអប់រំជាតិ : ស៊ីសុវត្ថិ ស៊ីរិមតៈ

.រដ្ឋមន្ត្រីយុត្តិធម៌ : ជួប សំឡុត

.រដ្ឋមន្ត្រីហិរញ្ញវត្ថុ កិច្ចការនយោបាយ និងសេដ្ឋកិច្ច : ម៉ៅ សាយ

.រដ្ឋមន្ត្រីសាធារណការ-ទូរគមនាគមន៍ និងផែនការ : ហួត សំអាត

.រដ្ឋមន្ត្រីសាធារណសុខាភិបាល : ជា ជិនកុក

.រដ្ឋលេខាធិការកសិកម្ម-កិច្ចការកសិករសង្គមកិច្ច និងតាំងទីលំនៅ : ហួត សម្បត្តិ

.រដ្ឋលេខាធិការធម្មការ និងព័ត៌មាន : ទ្រិញ វ៉ាញ

**១មិនា** រដ្ឋាភិបាលសង្គមរាស្ត្រនិយមទី៣ ដឹកនាំដោយសម្ដេច នរោត្តម សីហនុ តែ១ខែប៉ុណ្ណោះ រដ្ឋាភិបាលនេះ ត្រូវប្ដូរ ។

**៣ ខែមេសា** រដ្ឋាភិបាលលោក ឃីម ទិត តែ៧ខែប៉ុណ្ណោះ សង្គមរាស្ត្រនិយមប្ដូររដ្ឋាភិបាលដល់ទៅបួន ។

**៤-រដ្ឋាភិបាល ឃីម ទិត (៣.៤.១៩៥៦-១៥.៩.១៩៥៦)**

.នាយករដ្ឋមន្ត្រី-រដ្ឋមន្ត្រីផែនការ និងបោសសម្អាត : ឃីម ទិត

.ឧបនាយករដ្ឋមន្ត្រី-រដ្ឋមន្ត្រីការបរទេស : នង គីមនី

.រដ្ឋមន្ត្រីការពារជាតិ : ស៊ីសុវត្ថិ ស៊ីរិមតៈ

.រដ្ឋមន្ត្រីមហាផ្ទៃនិងការពារលើផ្ទៃប្រទេស : ជា ជិនកុក

.រដ្ឋមន្ត្រីយុត្តិធម៌-អប់រំជាតិ-វិចិត្រសិល្បៈយុវជននិងកីឡា : ជួប សំឡុត

.រដ្ឋមន្ត្រីហិរញ្ញវត្ថុនិងកិច្ចការសេដ្ឋកិច្ច : ម៉ៅ សាយ

.រដ្ឋមន្ត្រីសាធារណការនិងទូរគមនាគមន៍ : ហួត សំអាត

.រដ្ឋមន្ត្រីសាធារណសុខាភិបាល : គូ រុន

.រដ្ឋលេខាធិការ អមទីស្ដីការគណៈរដ្ឋមន្ត្រីទទួលបន្ទុកផែនការ និងដឹកនាំកិច្ចការទូទៅនៃទីស្ដីគណៈរដ្ឋមន្ត្រី : ផ្លែក ភីន

.រដ្ឋលេខាធិការកសិកម្ម-សង្គមកិច្ច និងការងារ : ហឿ ឡាយអ៊ីន

.រដ្ឋលេខាធិការអប់រំជាតិ-វិចិត្រសិល្បៈយុវជន និងកីឡា : ហួត សម្បត្តិ

.រដ្ឋលេខាធិការធម្មការ និងព័ត៌មាន : ទ្រិញ វ៉ាញ ។

**តទៅលេខក្រោយ**

នាទី ព្រះពុទ្ធសាសនា

# សមាធិវិបស្សនា

**ធម្មកថា**

**យោគា វេ ជាយតី ភូរិ អយោគា ភូរិសង្ខយោ ឯតំ ទ្វេធាបថញ្ញ ត្វា ភវាយ វិភវាយច តថត្តានំ និវេសេយ្យ យថាភូរិ ចវឌ្ឍតិ ឲ** មែនហើយ ! បញ្ញាញាណកើតមានឡើង ដោយសារការចំណេញកម្មដ្ឋាន ។ គ្មានការចំរើនកម្មដ្ឋាន បញ្ញាញាណរលាយបាត់អស់ ។ ដោយបានស្គាល់ផ្លូវទាំងពីរយ៉ាង ដែលនាំទៅរកសេចក្ដីចំរើន និងសេចក្ដីវិនាសនោះហើយ គេត្រូវប្រព្រឹត្តយ៉ាងណា ដើម្បីឱ្យបញ្ញាញាណរីកចំរើនឡើង ។

**(គាថាធម្មបទ២៨២)**

## ការពិសោធន៍ផ្ទាល់ខ្លួនអំពីវិបស្សនាកម្មដ្ឋាន

**ដោយ វេជ្ជបណ្ឌិត ប៉ូល-រ-ហ្វៃសម៉ាន់**

**(Paul R. Fleichmann)**

ការចំរើនកម្មដ្ឋានផ្អែកលើការចំអក ឬទស្សនវិស័យច្រើនបែបច្រើនយ៉ាង ។ គឺថាកាលណាយើងចង់សំរេចសេចក្ដីពិតសាកលកាន់តែខ្លាំងឡើង យើងក៏កាន់តែលិចជ្រៅទៅៗ ទៅក្នុងអន្លង់កម្ម របស់យើងដែរ ក្នុងចរិតលក្ខណៈពិសេសរបស់យើងរាល់គ្នា ។ រាប់ម៉ឺនម៉ោង ជារៀងរាល់ថ្ងៃរាល់អាទិត្យ ឬជូនកាលក្នុងមួយខែពេញ ខ្ញុំបានគិតពិចារណាដោយខ្លួនឯងនៅសំនួរនេះថា :

តើអ្វីធ្វើឱ្យខ្ញុំធូរស្បើយ អ្វីធ្វើឱ្យខ្ញុំមានសន្តិភាព ?

ការចំរើនកម្មដ្ឋានពិតប្រាកដ គឺគ្រាន់តែជាការសិក្សា រៀនសូត្រផ្សំកែសំរួលសេចក្ដីខ្វល់ខ្វាយឱ្យមានភាពស្ងប់ មានតុល្យភាពតែប៉ុណ្ណោះ ។ កាលពីដើម ក្នុងវេជ្ជវិទ្យាខាងផ្នែកវិកលចរិតគេបាន ឱ្យតម្លៃទៅលើការយល់លើខ្លួនឯង ដែលជាកត្តា មួយសំរាប់ពង្រឹងការអត់ទ្រាំទប់ទល់លើបញ្ហាខាងក្នុង ហើយដែលគេសង្ឃឹមថាវេជ្ជបណ្ឌិតខាងផ្នែកនេះនឹងចំណាយពេលសំរាប់ការពិចារណា ការថ្លឹងរកតុល្យភាពនៃភាពធន់ធាប់បានស្រួលឡើងវិញ ។ ផ្ទុយទៅវិញ សព្វថ្ងៃនេះ វេជ្ជបណ្ឌិតខាងផ្នែកវិកលចរិតជាច្រើន មានការយល់ស្របគ្នា ក្នុងការអនុញ្ញាតិឱ្យប្រើថ្នាំសក្ដិសិទ្ធរាល់រយៈពេល ១៥នាទី ហើយគេក៏សប្បាយពេញចិត្តនឹងការយល់ស្របគ្នានេះណាស់ ។ ពិនមែនហើយ ខ្ញុំក៏បានអនុញ្ញាតិឱ្យប្រើថ្នាំដើម្បីបន្ធូរការឈឺចាប់ដែរ ហើយដឹងអំពីជម្ងឺផ្លូវចិត្តខ្លះដែលមានឫសគល់ពីខ្សែស្រឡាយវង្សត្រកូល (Biogenetic ) ប៉ុន្តែ មនុស្សក៏រងទុក្ខ ឬធំធាត់ស្របតាមច្បាប់មូលដ្ឋានធម្មតានៃចិត្តវិទ្យា គឺអ្វីដែលនាំមកនូវការស្រុះស្រួលគ្នា និងសេចក្ដីសប្បាយរីករាយ ហើយធ្វើឱ្យអ្នកឯទៀតរួបរួមគ្នា និងនាំមកនូវសន្តិភាពក្នុងចិត្តរបស់លោកអ្នក។ សន្តិភាពដែលយើងចង់បានយ៉ាងខ្លាំង មាននៅក្នុងខ្លួនយើងស្រេចទៅហើយ ដូចជាហទ័យកោស (បណ្ដាញស្ពើងតែមានអនុភាពដែលព័ន្ធជុំវិញបេះដូង) ។ បេះដូងរបស់មនុស្សគ្រប់រូប មានសមត្ថភាស្រាប់ ដើម្បីពិសោធន៍ឃើញសន្តិភាពដែលលទ្ធផលផ្ទាល់នៃមេត្តា ករុណា និងសច្ចធម៌ ។

ខ្ញុំមិនបានរួចចាកផុតពីសេចក្ដីអន្ទះអន្ទែង និងអារម្មណ៍ប្រែប្រួលធម្មតាទេ ។ ចំពោះខ្ញុំ សកលលោកហាក់ដូចជាមានសភាពកាន់តែស្រងូតស្រងាត់ខ្លាំងឡើងៗ មិនមែនធូរថយទេ ។ មធ្យោបាយតែមួយគត់ ដែលយើងអាចដើរទៅមុខបានតាមធម្មតា គឺពាក់របាំងភ្នែកដូចជាសេះចាស់អូសរទេះតាមផ្លូវចរាចរពោរពេញដោយរថយន្ត :



-គេសម្លាប់មនុស្សអស់រាប់លាន នៅប្រទេសអៀរ៉ាក់

-មនុស្សរាប់លាននាក់លង់ទឹកស្លាប់នៅប្រទេសបង់ក្លាដែល ។

-ចម្បាំងគ្មានទីបំផុតនៅប្រទេសម៉ូសំប៊ិច. រវណ្ដា និងអេត្យូពី ។

-គំនរគ្រឿងអាវុធបរមាណូផ្សេងៗ ។

-ទីក្រុងធំៗនៃសហរដ្ឋអាមេរិក គ្មានសន្តិភាពនៅពេលយប់ ពោរពេញដោយគ្រឿងញៀន ។

-ការប្រណាំងប្រជែងសង្គ្រាមបច្ចុប្បន្ននៃបទឧក្រិដ្ឋ និងអំពើឃោរឃៅ ។

ប៉ុន្តែ ការរីកចំរើនកម្មដ្ឋាន បានផ្លាស់ប្ដូរជីវិតរបស់ខ្ញុំពីភាពអស់សង្ឃឹម( ឬអស់សង្ឃឹមដោយងងឹតងងល់)ទៅរកសេចក្ដីសង្ឃឹមបរិសុទ្ធ ។ រាល់ពេលដែលខ្ញុំចំរើនកម្មដ្ឋាន ខ្ញុំពិសោធន៍ឃើញថាអាចរៀបចំខ្លួនប្រាណបានស្រួល មានសេរីភាពបានមួយ ឬពីររយៈកាល អាចយល់ថា សេចក្ដីខ្លាច ឬសេចក្ដីទុក្ខព្រួយទាំងអស់ គ្រាន់តែជាសេចក្ដីអាណិតផ្ទាល់ខ្លួនរបស់ខ្ញុំតែប៉ុណ្ណោះ ។ កាលណាខ្ញុំមិនឱបក្រសោបខ្លួនខ្ញុំទេ ដំណើរប្រព្រឹត្តទៅទាំងអស់ សុទ្ធតែអាចធ្វើបាន ។ នរណាអាចនិយាយបានថា សកលលោកដែលពោរពេញទៅដោយមរណភាពនេះ មានន័យថាយ៉ាងណានោះ ? កាលណាខ្ញុំសន្និដ្ឋានអំពីរឿងនេះ ការសន្និដ្ឋានហ្នឹងគ្រាន់តែជាចំណាយនៃអវិជ្ជា និងភាពក្រអើតក្រទមផ្ទាល់ខ្លួនរបស់ខ្ញុំតែប៉ុណ្ណោះ ។ ជាញឹកញយណាស់ ខ្ញុំដឹងថា ខ្ញុំអាចជួបប្រទះនឹងខណៈបរិសុទ្ធនៅក្នុងខ្លួនខ្ញុំ នៅពេលណាដែលគ្មានភាណអកុសលកើតឡើង ហើយខ្ញុំដឹងថា ខ្ញុំជាកាំរស្មីមួយឆ្លងកាត់សកលលោកឆ្ពោះទៅរកទីបរមសុខ ដែលនឹងទាក់យ៉ាងហោចណាស់មនុស្សមួយចំនួនតាមក្រោយខ្ញុំ ។ ចំពោះសេចក្ដីទុក្ខរបស់លោក វាហាក់ដូចជាធំមហិមា លើសពេលណាៗទាំងអស់ តែច្រកចេញនៅចន្លោះពពកទាំងឡាយក៏ធំធេងណាស់ដែរ កាលណាខ្ញុំយល់អំពីភាពដ៏ធំធេងនៃអវិជ្ជាកាន់តែច្បាស់ឡើង ខ្ញុំក៏ឃើញមាគ៌ាចេញចាកពីអវិជ្ជាកាន់តែច្បាស់ឡើងដែរ ហើយការដឹងហេតុផលក្នុងការព្យាយាមចំរើនកម្មដ្ឋានរបស់ខ្ញុំ ក៏កាន់តែមានកំលាំងខ្លាំងឡើងផងដែរ ។

ខ្ញុំតែងតែនឹកគិតអំពីព្រះនិព្វាន ។ តើខ្ញុំនឹងបានសំរេចព្រះនិព្វាន ឬមិនបានសំរេចទេ ? ដោយ ភ័ព្វវាសនាល្អខ្ញុំងាចបំភ្លេចរឿងនេះបាន ។ សិស្ស វេជ្ជវិទ្យាគ្រប់គ្នាសួរខ្លួនឯងថា :

តើថ្ងៃណាខ្ញុំនឹងបានទទួលរង្វាន់ណូបែល ? ប៉ុន្តែបន្តិចក្រោយមក គេត្រូវតែបំភ្លេចវាចោល ។ លោកអ្នកមិនអាចធ្វើការស្រាវជ្រាវជាមួយជីវិតរបស់លោកអ្នកទេ ។ ហើយលោកអ្នកមិនអាចគិតយ៉ាងនេះបានទេថា : ល្ពឹកណាតែខ្ញុំរកឃើញរបៀបព្យាបាលរោគមហារីកឱ្យបានជាសះស្បើយទើបជីវិតខ្ញុំមានតម្លៃ ។ ( **តទៅទំព័រទី១៨** )

# ទីក្រុងដែលសំបូរដោយអំពើហិង្សា

**ដោយ : អ៊ុម លឿម**

•••ហ្វីឡាដែលហ្វីយ៉ា ជាទីក្រុងដ៏ចំណាស់មួយ ដែលពោរពេញទៅដោយភាពអាប់អួរផ្នែកបរិស្ថាន អនាម័យ ហើយជាទីក្រុង ដែលសំបូរទៅដោយក្រុមមនុស្សប្រើអំពើហិង្សាដាក់គ្នាទៅវិញទៅមក ព្រមទាំងពោរពេញទៅដោយការជួញដូរគ្រឿងញៀនស្រវឹងខុសច្បាប់យ៉ាងគឃ្លើនបំផុត ។

ទោះជាសាលាក្រុងហ្វីឡាដែលហ្វីយ៉ា បានចាត់វិធានការយ៉ាងតឹងតែង ព្រមទាំងបានបង្កើតកំលាំងប៉ូលីស ដោយការយាមល្បាត ដោយរថយន្តចល័ត ស្ទើគ្រប់ច្រកល្ហកក្តី ក៏អត្រានៃអំពើឃាតកម្ម, ចោរកម្ម និងការជួយដូរគ្រឿងញៀនស្រវឹងនៅលើទីផ្សារងងឹត ហាក់នៅមានកំណើនយ៉ាងខ្ពស់ដដែល ។ ចំណែកឯតួលេខនៃអ្នកស្លាប់ដោយសារការបាញ់ប្រហារគ្នាកាន់តែកើនឡើងជាលំដាប់ ។ ដូច្នេះហើយទើបទីក្រុងដ៏ចំណាស់មួយនេះ បានចាប់ចំណាប់ថ្នាក់ក្រៅផ្លូវការថាជាទីក្រុងនៃពិភពកាប់ចាក់, បាញ់ប្រហារព្រោះដោយសារតែសំបូរទៅដោយក្រុមជនអន្ធពាល (Gangster) ជាច្រើនបក្សក្រុម ។

សូមជម្រាបថា កុំថាឡើយពេលយប់ ឬថ្ងៃ យើងតែងឮសម្លេងស៊ីរ៉ែន យ៉ាងខ្សៀវខ្សារ ចេញពីរថយន្តសង្គ្រោះបន្ទាន់, និងពីថយន្តប៉ូលីស ស្ទើតែពុំដាច់សូរ ដោយសម្លេងទាំងនោះជាសញ្ញាប្រាប់អំពីបេសកម្មជាបន្ទាន់របស់សមត្ថកិច្ចប៉ូលីស ក្នុងការប្រញាប់ជួយសង្គ្រោះដល់ជនរងគ្រោះ ដោយបាតុភាពផ្សេងៗ ។

ក៏ប៉ុន្តែមានប្រការវិជ្ជមានមួយគួរគត់សំគាល់ ថា ទោះជាហ្វីឡាដែលហ្វីយ៉ា ពោរពេញទៅដោយពហុជាតិសាសន៍ និងមានអ្នកគោរពលើជំនឿសាសនាជាច្រើនស្អេកស្កះផ្សេងៗពីគ្នាមែន តែហាក់នៅពុំទាន់មានបាតុភាព ឬការបង្កជម្លោះណាមួយផ្តើមចេញពីបញ្ហាជាតិសាសន៍ នោះឡើយ ។

អ្នកនាង ផាន់ណា អាយុ ២៥ឆ្នាំ ទើបបានមករស់នៅលើទឹកដីហ្វីឡាដែលហ្វីយ៉ា ជាលើកដំបូង ដោយការធានាពីស្វាមីរបស់នាង កាលពីឆ្នាំមុខ បានសំដែងនូវអារម្មណ៍ផ្ទាល់ខ្លួនរបស់នាងប្រាប់ខ្មែរប៉ុស្តិ៍ ថា : នាងខ្ញុំហាក់មានការភ្ញាក់ផ្អើល និងខកចិត្តជាខ្លាំង ចំពោះទិដ្ឋភាពដ៏គួរឱ្យខ្លាចរអែង នៃទីក្រុងនេះ, នាងខ្ញុំធ្លាប់បានគិតថា សហរដ្ឋអាមេរិក ជាប្រទេសស៊ីវិល្ស៍ មានអរិយធម៌ល្អខ្ពង់ខ្ពស់, មានមនុស្សចេះដឹងច្រើន, ដូច្នេះពិតជាគ្មានការបាញ់ប្រហារ ឬសម្លាប់មនុស្សក្រៅប្រព័ន្ធដូចនៅស្រុកខ្មែរ ឡើយ, តែផ្ទុយទៅវិញ ការគិតរបស់នាងខ្ញុំ ផ្ទុយគ្នាយ៉ាងស្រឡះ ទៅនឹងស្ថានភាពជាក់ស្តែង នៅទីក្រុងនេះ (ហ្វីឡាដែលហ្វីយ៉ា) ។

នាង ផាន់ណា បានបន្តថា : សូម្បីតែពេលថ្ងៃ ក៏ពុំដែលហ៊ានចេញក្រៅផ្ទះម្នាក់ឯងឡើយ ព្រោះពុំសូវមានសុវត្ថិភាព, ហើយសូម្បីតែពេលគេងយប់ក៏ពុំហ៊ានបើកបង្អួច ដើម្បីឱ្យខ្យល់ចូល និងពេលថ្ងៃសូម្បីតែផ្ទះផ្ទាល់ខ្លួនក៏ពុំហ៊ានបើកចំហរទ្វារមួយនាទីណាឡើយ ។ ក៏ប៉ុន្តែ នាង ផាន់ណា បានទទួលស្គាល់ថា : "ទីនេះសំបូរការងារធ្វើ ហើយទោះជាយ៉ាងណាក៏ដោយ ក៏គ្រាន់បើជាងនៅស្រុកខ្មែរដែរ ព្រោះប្រាក់កំរៃដែលនាងបានទទួល គឺសមរម្យទៅនឹងកម្លាំងពលកម្ម ដែលនាងបានបញ្ចេញ " ។

គួររំលឹកថា សមាសភាពនៃក្រុមជនអន្ធពាលដែលមនុស្សភាគច្រើនស្គាល់ថា (Gangster) ក៏មានមួយចំនួនជាក្រុមយុវជនខ្មែរផងដែរ, ហើយយូរៗម្តង នៅពេលដែលមានពិធីបុណ្យប្រពៃណីជាតិផ្សេងៗ ក្រុមជនទាំងនោះ តែងតែបញ្ចេញនូវអនុភាពរបស់ខ្លួន ដោយការបាញ់ប្រហារគ្នា ។

ទោះជាយ៉ាងណានោះក្តី "ផ្ទះមានមនុស្ស, ប្រទេសមានច្បាប់" ជនដែលប្រព្រឹត្តនូវបទឧក្រិដ្ឋផ្សេងៗ ទីបំផុតពួកគេនឹងតបស្នងមកវិញនូវទោសទណ្ឌតាមផ្លូវច្បាប់ ទៅតាមទំហំដែលខ្លួនបានប្រព្រឹត្ត ។ ហើយនៅដើមខែសីហា កន្លងមកនេះ រដ្ឋាភិបាលអាមេរិក បានផ្តើមបញ្ជូនយុវជនខ្មែរប្រមាណជាង ១០នាក់ ជាថ្មីម្តងទៀតឱ្យត្រលប់ទៅកាន់ប្រទេសកំណើតវិញ បន្ទាប់ពីបានជាប់ពន្ធនាគារអស់មួយរយៈ នៅឯសហរដ្ឋអាមេរិក ដោយភាគច្រើនជាក្រុមយុវជនមានអាយុចន្លោះពី ២៥-៣០ឆ្នាំ និងមានមួយចំនួនក្នុងចំណោមជនទាំងនោះ ពុំអាចនិយាយភាសាខ្មែរបានឡើយ ។

គួររំលឹកថា ក្រុងហ្វីឡាដែលហ្វី ជាទីក្រុងទីបីដែលសំបូរខ្មែររស់នៅ (២៥០០០នាក់) បន្ទាប់ពីទីក្រុងឡុងប៊ិច និងឡូវែល មក ។ ជាទីក្រុងចាស់ ដែលសំបូរដោយប្រវត្តិសាស្ត្រ ផ្តើមកសាងសហរដ្ឋអាមេរិក ហើយស្ថិតនៅចន្លោះ ទីក្រុងវ៉ាស៊ិនតុន និងញូយ៉ក ដែលជាទីក្រុងជោគជ័យបំផុតនៃសហរដ្ឋអាមេរិកនេះ ។ បើទោះបីជាសំបូរដោយអំពើហិង្សាក៏ដោយក្តី ក៏បណ្តាញច្បាប់នៅតែរឹងមាំឥតខ្ចោះដដែល រដ្ឋ "ផែនស៊ីវេនា" ទាំងមូល ក៏ពុំមានគ្រោះថ្នាក់ដូច ទីក្រុងហ្វីឡា-ដែលហ្វីយ៉ា តែមួយនោះទេ រចនាសម្ព័ន្ធនៃទីក្រុងសម័យថ្មីប្រកបដោយសន្តិសុខគ្រប់គ្រាន់ កំពុងតែរីកទៅកិនឡើងក្រុងចាស់ ដែលសំបូរភាពក្រីក្រ និងអំពើហិង្សាជាបន្តៗ ទៅហើយដែរ ៕

## (តមកពីទំព័រទី០៧) ខ្មែរចុះទឹកជួបសត្វក្រពើ...

ចេញបញ្ជាឱ្យកងនគរបាលរក្សាសន្តិសុខក្រុងភ្នំពេញឱ្យទៅវាយបង្ក្រាបបំបែកហ្វូងសកម្មជនខ្មែរនាថ្ងៃអាទិត្យនេះ ឃើញថា រាជរដ្ឋាភិបាលពេញចិត្តណាស់ ទៅលើការតាមសង្កត់ធ្វើបាបសង្កតសង្កិន រំលោភបំពានទៅលើសិទ្ធិសេរីភាពរបស់ជនជាតិខ្មែរ ស្នេហាជាតិពិតប្រាកដ ដែលអាចចាត់ទុកបានថាជាវប្បធម៌ ។

ដ៏ល្អពិសេសរបស់រាជរដ្ឋាភិបាលជួយនេះ ដែលធ្លាប់តែបានធ្វើជាច្រើនលើកច្រើនសារ តាំងតែពីពេលបានឡើងកាន់អំណាចនាឆ្នាំ១៩៧៩ មកហើយ ការបង្ក្រាបម្តងៗមានភាពសាហាវឃោឃៅព្រៃផ្សៃខ្លាំងក្លាណាស់ រហូតដល់មានការបង្ហូរឈាមស្លាប់បាត់បង់ជីវិតសកម្មជនស្នេហាជាតិ អស់យ៉ាងច្រើនទៀតផង ។

ដរាបណានៅក្នុងប្រទេសខ្មែរ នៅតែស្ថិតនៅក្នុងអំណាចរាជរដ្ឋាភិបាលដែលប្រកាន់យកច្បាប់ព្រៃ និងផ្តាច់ការដូច្នេះដរាបនោះ ប្រទេសកម្ពុជាមានឈ្មោះនៅលើផែនទីពិភពលោកទេ ប៉ុន្តែការគ្រប់គ្រងដឹកនាំ នៅក្នុងប្រទេសកម្ពុជា ពុំមែនស្ថិតនៅក្នុងកណ្តាប់ដៃ ក្រោមអំណាចរបស់មេដឹកនាំមានសញ្ជាតិជាខ្មែរពិតប្រាកដទេ ។

ដូច្នេះជីវិតប្រទេស និងជាតិសាសន៍ខ្មែរ នឹងត្រូវតែរលាយសាបសូន្យទៅបន្តិចម្តងៗ រហូតដល់ថ្ងៃចុងបំផុត ទៅតាមផែនការពង្រីក និងលេបទឹកដីខ្មែរ នៃប្រជាជាតិធំៗពី តាំងនៅទឹកខាងកើត គឺ ក្រពើយួន ហើយនិងទិសខាងលិច គឺខ្លាធំថៃ ដែលកំពុងខាំត្របាក់ស៊ីប្រជាពលរដ្ឋជាតិខ្មែរ ជារៀងរាល់ថ្ងៃ ហើយនិងស៊ីជារៀងរហូតលុះត្រឡប់ចុងបញ្ចប់ ៕

## (តមកពីទំព័រទី១១) ប្រាសាទកោះកេរ្តិ៍អតីតរាជធានី...

នៅគ.ស៩២១ ព្រះបាទជ័យវរ្ម័នទី៤ ដែលជាបងប្អូនថ្លៃរបស់ព្រះបាទយសោវរ្ម័នបានយាងចាកចេញពីទីក្រុងអង្គរ មានចំងាយប្រមាណ ៧០គីឡូម៉ែត្រពីរាជធានី ។

ក្រុមទីពីរគ្រប់គ្រងដោយអាជ្ញាធរអប្សរា មានគ្នាចំនួន ១០នាក់ ដែលមានតួនាទីសំអាតបរិវេណប្រាសាទ និងឃ្លាំមើលភ្ញៀវគូសវាសលើជញ្ជាំងប្រាសាទ ។



ប្រាសាទចិន និង ប្រាសាទនាងខ្មៅ នៅរមណីយដ្ឋានកោះកេរ្តិ៍

ការចាកចេញរបស់ព្រះបាទជ័យវរ្ម័នទី៤នេះ ដោយសារតែអន់ព្រះទ័យជាមួយបងថ្លៃ ដែលតែងតាំងក្មួយក្មេងពេកឱ្យឡើងគ្រងរាជសម្បត្តិ នៅពេលប្រមូលកងទ័ពច្បាំងឈ្នះក្មួយហើយ ព្រះអង្គក៏លើករាជធានីទៅប្រាសាទកោះកេរ្តិ៍ នៅឆ្នាំ៩២៨ ។

ព្រះបាទជ័យវរ្ម័នទី៤ ដែលចង់បង្ហាញពីមហិទ្ធិឫទ្ធិដល់នាម៉ឺនសព្វមន្ត្រី និងប្រជារាស្ត្រ ។

ព្រះអង្គបានកសាងប្រាសាទកោះកេរ្តិ៍ មានលក្ខណៈជាប្រាសាទភ្នំ បែរមុខទៅទិសខាងលិច ឆ្ពោះទៅរាជធានីអង្គរ ដើម្បីឧទ្ទិសថ្វាយដល់អាទិទេពឈ្មោះ "ត្រីភូវនេស្វរៈ" ក្នុងលទ្ធិ-ព្រហ្មញ្ញសាសនា ។

ប្រាសាទដែលមានកំពស់៣៥ម៉ែត្រ និងខឿន៥ជាន់នេះ មានអាយុជាង១០០០ឆ្នាំហើយ ដែលសព្វថ្ងៃបានក្លាយទៅជារមណីយដ្ឋានទេសចរណ៍ជាតិប្រវត្តិសាស្ត្រដ៏ល្បីល្បាញពីសំណាក់ភ្ញៀវទេសចរចំរុះជាតិសាសន៍ ។

នៅបរិវេណអតីតរាជធានីសម័យមហានគរ អ្នកស្រាវជ្រាវប្រវត្តិសាស្ត្របានរកឃើញមានប្រាសាទមួយចំនួននៅក្បែរប្រាសាទកោះកេរ្តិ៍ ចំនួន ៩៨ ក្នុងនោះមាន : ប្រាសាទដារ នាងខ្មៅ រំលិច បឹងវែង ត្រពាំងព្រៃ ដីឆ្នាំង ស្រុងស្រឡៅ លិង្គ គុកស្រគំ ត្រពាំងតា សុភី ក្រហម អណ្តូងអង្គខ្នា ទឹកក្រហម ដំរីស ក្រវាប់ បន្ទាយពីរជាន់ គុក ខ្មៅ ថ្មីង ធំបល្ល័ង្គ រហាល សំពេច ត្រពាំង-ស្វាយ ខ្នាចិន ឃ្មុំច្រាប ដងទង់... ។

ប្រាសាទទាំងនេះ ត្រូវបានអាជ្ញាធរធ្វើការអភិរក្ស និងជួសជុលមួយចំនួនឡើងវិញ ហើយមួយចំនួនទៀតនៅសល់តែស្នាមគ្រឹះតែប៉ុណ្ណោះ ។ កេរដំណែលរបស់បុព្វបុរសខ្មែរនេះស្ថិតនៅចំងាយពីគ្នាមួយគីឡូម៉ែត្រ, ពីរគីឡូម៉ែត្រ ឬបីគីឡូម៉ែត្រ ។

លោក អ៊ុច វិកុក មេប៉ូលិសការពារបេតិក-ភណ្ឌក្រសួងមហាផ្ទៃ ប្រចាំការនៅតំបន់ប្រាសាទកោះកេរ្តិ៍ បានឱ្យដឹងថា សមត្ថកិច្ចដែលការពារចែកចេញជាពីរក្រុម គឺក្រុមប៉ូលិសក្រសួងមហា-ផ្ទៃ ចំនួន៤៤នាក់ ជាអ្នកបង្ក្រាបបទល្មើស និង

លោក អ៊ុច វិកុក បានបន្តថា សន្តិសុខសណ្តាប់ធ្នាប់នៅទីនោះល្អណាស់ ដោយបង្កលក្ខណៈងាយស្រួលឱ្យភ្ញៀវបានដើរកំសាន្តគ្រប់ទីកន្លែង ពីព្រោះបរិវេណនោះធំណាស់ ដែលប្រាសាទនីមួយៗ ឃ្លាតពីគ្នារាប់គីឡូម៉ែត្រ ។

ទាក់ទិននឹងភ្ញៀវទេសចរដែលមកទស្សនាប្រាសាទកោះកេរ្តិ៍ក្នុងរដូវប្រាំង ឬរដូវវស្សានោះ លោក គិត ច័ន្ទធី អនុប្រធានមន្ទីរទេសចរណ៍ខេត្តព្រះវិហារ បានឱ្យដឹងថា នៅរដូវវស្សាមានភ្ញៀវធ្លាក់ច្រើន ធ្វើឱ្យប៉ះពាល់ដល់ដំណើរកំសាន្តរបស់ភ្ញៀវទេសចរខ្លះដែរ ហើយបើតាមការសង្កេតក្នុងមួយខែមានភ្ញៀវប្រមាណពី៥០០-១០០០នាក់ ។ ចំណែកនៅរដូវប្រាំង ឬថ្ងៃបុណ្យប្រពៃណីជាតិ គឺភ្ញៀវទៅទស្សនាច្រើន ពីព្រោះអាកាសធាតុល្អ ផ្លូវគមនាគមន៍ក៏ស្រួល សន្តិសុខល្អ ។

មន្ត្រីអភិរក្សនៅតំបន់ប្រាសាទកោះកេរ្តិ៍ បាន ឱ្យដឹងថា ភ្ញៀវទេសចរភាគច្រើនមានជំនឿចំពោះផ្នូរស្តេចដំរីស ដែលគេកប់ក្បែរនោះ ហើយនាំគ្នាបន់ស្រន់មិនដែលខកខាននោះទេ ។ ជាពិសេសនោះ នៅពេលរដូវរាំងស្ងួតធ្វើស្រែមិនបានផល ពួកគាត់នាំគ្នាមកបួងសួងសុំទឹកភ្លៀង ហើយច្រើនសមប្រកបទៀតផង ។

អតីតរាជធានីសម័យមហានគរ អាយុជាង ១០០០ឆ្នាំនេះ មានធម្មជាតិស្រស់បំព្រង លាយឡំនឹងសំលេងបក្សាបក្សីយំលាយឡំគ្នា បានបង្កើតជាបរិយាកាសមួយឱ្យរិតតែប្រសើរសំរាប់អ្នកទេសចរដែលកំពុងតែគយគន់មើលក្បាច់ចំលាក់នៃប្រាង្គប្រាសាទ ។

ប្រាសាទដ៏ចំណាស់នេះ បានបង្ហាញពីអរិយ-ធម៌ដ៏រុងរឿងរបស់ជាតិសាសន៍ពីអតីតកាលនៅតំបន់អាស៊ីអាគ្នេយ៍ ហើយកេរដំណែលនេះបានរួមចំណែកដ៏សំខាន់សំរាប់ខ្មែរជំនាន់ក្រោយ បញ្ជាក់ពីអត្តសញ្ញាណរបស់ខ្លួន ។ គេសង្ឃឹមថា បើ អង្គការយូណេស្កូបញ្ចូលប្រាសាទនេះជាសម្បត្តិបេតិកភណ្ឌ សៀមមិនអាចធ្វើការយាយី និងឈ្លានពានដូចប្រាសាទព្រះវិហារនោះទេ ៕

## (តមកពីទំព័រទី០៤) សង្គមស៊ីវិលជំរុញឱ្យកែទំរង់ច្បាប់...

លោកស្រី ពុង ឈីវកេក នាយិកាអង្គការសិទ្ធិមនុស្សលីកាដូ បានធ្វើការស្តីបន្ទោសចំពោះ គ.ជ.ប ដែលជាស្ថាប័នរៀបចំដំណើរការនេះ គឺចាប់តាំងពីឆ្នាំ១៩៩៨ រហូតដល់ឆ្នាំ២០០៨ មានបញ្ហាប្តឹងប្តល់មិនចេះចប់ ទាំងប្រជាពលរដ្ឋ និងគណបក្សនយោបាយដែលជាប់ឆ្នោតក្នុងរដ្ឋសភា ។ ការដែលមានទំនាស់ដោះស្រាយមិនចេះចប់នេះ បណ្តាលមកពី គ.ជ.ប មិនបានធ្វើការដោះស្រាយបណ្តឹងឱ្យមានលក្ខណៈយុត្តិធម៌ មិនមានភាពឯករាជ្យ និងអាព្យាក្រឹត្យក្នុងកិច្ចរបស់ខ្លួន ។



លោកស្រី ពុង ឈីវកេក បានបន្តថា គ.ជ.ប គួរតែធ្វើខ្លួនឱ្យមានឯករាជ្យ និងអព្យាក្រឹត្យ ដើម្បីឱ្យម្ចាស់ឆ្នោតជឿទុកចិត្ត ។ ប្រសិនបើ គ.ជ.ប មិនធ្វើការកែសំរួលស្ថាប័នរបស់ខ្លួនទេ ការបោះឆ្នោតនៅលើកក្រោយៗទៀតនៅតែមានបញ្ហាប្តឹងប្តល់ ការតវ៉ាមិនចេះឈប់ឈរ នោះទេ ។

ចំណែកលោក សុក សំអឿន អនុប្រធានគណៈកម្មាធិការខុមប្រែល និងជានាយកប្រតិបត្តិក្រុមអ្នកច្បាប់ការពារសិទ្ធិមនុស្សកម្ពុជា ក៏បានបញ្ជាក់ស្រដៀងនឹងនាយិកាអង្គការសិទ្ធិមនុស្សលីកាដូ ថា ការកែទំរង់ស្ថាប័ន គ.ជ.ប វាពិតជាមានសារសំខាន់ខ្លាំងណាស់សំរាប់ដំណើរការបោះឆ្នោតលើកក្រោយៗទៀត ។ ជាពិសេសនោះ ការដោះស្រាយទំនាស់ និងបណ្តឹងរបស់ប្រជាពលរដ្ឋ និងគណបក្សនយោបាយប្រកបដោយគតិយុត្តិធម៌ ពិតជាផ្តល់នូវការជឿទុកចិត្តសំរាប់ដំណើរការលទ្ធិប្រជាធិតេយ្យនៅពេលបោះឆ្នោត ។

ក្នុងសេចក្តីថ្លែងការណ៍របស់សម្ព័ន្ធអង្គការសង្គមស៊ីវិលបានផ្តល់ជាអនុសាសន៍ថា ភាគីពាក់ព័ន្ធបោះឆ្នោតត្រូវពិភាក្សាគ្នាពីកំណែទំរង់ ការចុះឈ្មោះអ្នកបោះឆ្នោត បញ្ជីឈ្មោះអ្នកបោះឆ្នោត ការលប់ឈ្មោះចេញពីបញ្ជី និងការចេញទំរង់១០១៨ ។ ត្រូវធ្វើកំណែទំរង់ គ.ជ.ប ពីរបៀបដោះស្រាយទំនាស់ និងបណ្តឹងឱ្យមានប្រសិទ្ធភាព ។

អនុសាសន៍របស់សង្គមស៊ីវិលបានបញ្ជាក់ថា ត្រូវបង្កើតច្បាប់ថវិកាសំរាប់គណបក្សនយោបាយហាមប្រាមការប្រើប្រាស់ថវិការដ្ឋសំរាប់គណបក្សនយោបាយ និងបង្កើតតម្លាភាពនៃការប្រើប្រាស់ថវិកាពេលឃោសនាបោះឆ្នោត និងអនុវត្តច្បាប់ដល់មន្ត្រីរាជការគ្រប់ស្ថាប័នឱ្យអព្យាក្រឹត្យ មិនត្រូវចូលរួមឃោសនាគាំទ្រគណបក្សនយោបាយណាមួយឡើយ ទោះបីជា ក្រៅម៉ោងធ្វើការក៏ដោយ និងច្បាប់ប្រព័ន្ធផ្សព្វផ្សាយតាមបែបសមធម៌ ។

លោក ទេព នីថា អគ្គលេខាធិការគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានប្រាប់ក្រុមអ្នកកាសែតថា សេចក្តីថ្លែងការណ៍របស់សង្គមស៊ីវិលនេះជាឆន្ទៈរបស់គេ ដែលបានចូលរួមសង្កេតការណ៍បោះឆ្នោត ហើយលោកថា ចង់កែប្រែច្បាប់បោះឆ្នោត ប្រហែលជាមិនអាចទៅរួចទេ លុះត្រាតែកែប្រែរដ្ឋធម្មនុញ្ញជាមុនសិន ។

លោកអគ្គលេខាធិការរូបនេះ បាននិយាយទាំងអំណួតថា ការបោះឆ្នោតនៅឆ្នាំ២០០៨នេះ ទាំងអ្នកចូលរួមសង្កេតការណ៍ជាតិ និងអន្តរជាតិ និងគណបក្សនយោបាយមួយចំនួនដែលចូលរួមប្រកួតប្រជែងការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ សុទ្ធតែវាយតំលៃថា មានលក្ខណៈល្អប្រសើរជាងលើកមុនៗឆ្ងាយណាស់ ។

បន្ទាប់ពីបោះឆ្នោតរួចនៅថ្ងៃទី២៨ ខែកក្កដា ប្រជាពលរដ្ឋជាច្រើនបានធ្វើការតវ៉ាពីភាពមិនប្រក្រតីនៃការបាត់ឈ្មោះរបស់ខ្លួន និងការរារាំងមិនឱ្យបោះឆ្នោត អ្នកខ្លះទៀតត្រូវបានគេទិញទឹកចិត្តជាថ្នូរនឹងលុយកាក់ ។ អ្នកមួយចំនួនទៀតត្រូវគេបង្ខំឱ្យបោះឆ្នោតឱ្យគណបក្សកាន់អំណាច តាមរយៈការបំភិតបំភ័យពីសុវត្ថិភាព ឬមិនព្រមសំរួលកិច្ចការឱ្យនៅថ្ងៃក្រោយ ។

ជាពិសេស នៅថ្ងៃទី២៨ ខែកក្កដា គណបក្សហ្វ៊ុនស៊ិនប៉ិច ដែលមានទ្រង់ ស៊ីសុវត្ថិសេរីវ័ត្ត អនុប្រធានទី២, លោក មុត ចន្ថា អ្នកនាំពាក្យគណបក្សនរោត្តម រណឫទ្ធិ, លោក កឹម សុខា ប្រធានគណបក្សសិទ្ធិមនុស្ស និងលោក សម រង្ស៊ី ប្រធានគណបក្ស សម រង្ស៊ី បានចុះហត្ថលេខាចេញសេចក្តីថ្លែងការណ៍បដិសេធលទ្ធផលបោះឆ្នោតថា មិនសេរី មិនយុត្តិធម៌ មិនអាចទទួលយកបានទេ គឺមានភាពមិនប្រក្រតីនៅមុនថ្ងៃបោះឆ្នោត ថ្ងៃបោះឆ្នោត និងក្រោយថ្ងៃបោះឆ្នោត ។

ប៉ុន្តែមិនបានប៉ុន្មានថ្ងៃផង គណបក្សហ៊្វុនស៊ិនប៉ិច និងគណបក្ស នរោត្តម រណឫទ្ធិ បានចេញសេចក្តីថ្លែងការណ៍ថា ការបោះឆ្នោតសេរី យុត្តិធម៌ ជាថ្នូរនឹងការផ្តល់តួនាទី អំណាចក្នុងជួររដ្ឋាភិបាល ជាមួយគណបក្សប្រជាជនកម្ពុជា ។

ក្នុងសន្និសីទកាសែតរួមគ្នារវាងគណបក្ស សម រង្ស៊ី និងគណបក្សសិទ្ធិមនុស្ស បានច្រានចោលលទ្ធផលនៃការបោះឆ្នោត និងការធ្វើ

(តទៅទំព័រទី១៦)

## (តមកពីទំព័រទី១០) ពលរដ្ឋខ្មែរប្រមាណ១០លាននាក់...

គឺមាន៤៧%មានបង្គន់ប្រើប្រាស់ ។

លោករដ្ឋមន្ត្រីបន្តថា ជារៀងរាល់ឆ្នាំនៅជនបទបានធ្វើបង្គន់ប្រមាណ៦ម៉ឺនសំរាប់អ្នកស្រុក ហើយនៅឆ្នាំ២០១៥ និងមានបង្គន់ដល់ ៥០០.០០០ សំរាប់អ្នកស្រុកនៅជនបទ ។

អ្នកស្រី ឈុន សាក់ អាយុ៤៨ឆ្នាំ នៅភូមិរលំជ្រៃ ឃុំជ្រៃ ស្រុកថ្មគោល ខេត្តបាត់ដំបង បានឱ្យដឹងថា អ្នកភូមិគាត់ភាគច្រើនមិនទំលាប់ធ្វើបង្គន់សំរាប់បន្ទោរបង់នោះទេ គឺពួកយើងទាំងក្មេងចាស់ ច្រើនទៅរកគុម្ពសង្កែ ឬព្រៃឫស្សីសំរាប់បិទបាំង ។

ភាពសំណល់សំរាមដែលប្រជាពលរដ្ឋចោលនៅទីសាធារណៈ



អ្នកស្រី ឈុន សាក់ បន្តថា នៅពេលបន្ទោរបង់ម្តងៗត្រូវធ្វើដំណើរឆ្ងាយពីផ្ទះរកព្រៃ និងកន្លែងស្ងាត់ បន្ទាប់ពីបត់ជើងរួច រកស្លឹកឈើ ឬដុំដីកិតជាការស្រេច ។ ក្នុងពេលជាមួយគ្នានេះដែរ ពេលធ្លាក់ខ្យល់ម្តងៗ គឺជះក្លិនមកអាក្រក់ណាស់ ។ ប៉ុន្តែនៅពេល ថ្មីៗនេះ ខាងអង្គការ បានមកជួយធ្វើបង្គន់ឱ្យនៅក្បែរផ្ទះសំរាប់បន្ទោរបង់ហាក់ដូចជាងាយស្រួលជាងមុនបន្តិច ។

លោក ផេង សុជាតិ អាយុ៣៥ឆ្នាំ រស់នៅតាមបណ្តោយស្ទឹងមង្គលបុរី ខេត្តបន្ទាយមានជ័យ បានឱ្យដឹងថា ដោយសារតែការរស់នៅគ្មានអនាម័យ និងគ្មានបង្គន់សំរាប់បន្ទោរបង់នោះ ពេលភ្លៀងម្តងៗ កាកសំណល់លាមកមនុស្សសត្វ និងសំរាម បានហូរចូលទឹកស្ទឹង បង្កភាពកខ្វក់ និងមេរោគយ៉ាងខ្លាំងដល់អ្នកស្រុកដែលដងទឹកយកទៅប្រើប្រាស់នោះ ។

លោក ផេង សុជាតិ បានបន្តថា កុមារភាគច្រើនមានជំងឺរាករុះ និងសុខភាពមិនសូវល្អ ដោយសារតែទឹកស្ទឹងពោរពេញទៅដោយមេរោគ និងភាពកខ្វក់ក្នុងទឹកនោះ ។

បើតាមមន្ត្រីជំនាញបានអះអាងថា ក្នុងមួយឆ្នាំរដ្ឋាភិបាលត្រូវចំណាយលុយប្រមាណ១លានដុល្លារ ដើម្បីសង់បង្គន់នៅតាមបណ្តាខេត្ត-ក្រុង សំរាប់អ្នកស្រុកបន្ទោរបង់ ។ ការរស់នៅខ្វះអនាម័យជាហេតុធ្វើឱ្យប្រជាពលរដ្ឋមានជំងឺសុខភាពមិនសូវល្អ, ខាតបង់ថវិកា និងពេលវេលា និងពេលខ្លះស្លាប់បាត់បង់ជីវិតថែមទៀត ។

ដូច្នេះដើម្បីកាត់បន្ថយគ្រោះថ្នាក់នៃការរស់នៅខ្វះអនាម័យ និងការចំណាយនេះ រដ្ឋាភិបាលគួរតែធ្វើការអប់រំប្រជាពលរដ្ឋឱ្យមានការយល់ដឹង រស់នៅស្អាតគ្រប់ពេលវេលា មានចំណេះដឹងពីសុខភាព អនាម័យ និងបរិស្ថានទើបប្រសើរ ។




Get Connect...Stay inform.

....Subscribe to the Khmer Post!

Please send me 1 year subscription of the Khmer Post newspaper 24 issues for $60.00

Name:______________________

Address:____________________

____________________________

Payment method:

Money order Check Bill me

Please send your payment to US-Asia Media Group.
5730 Rising Sun Ave. Philadelphia, Pa 19120



## បណ្ណបញ្ជាកាសែតខ្មែរប៉ុស្តិ៍

ខ្ញុំចង់ឱ្យ " ខ្មែរប៉ុស្តិ៍ " ផ្ញើរកាសែតជាភាសាខ្មែរ ដែលសំបូរដោយព័ត៌មានក្នុងសហគមន៍ខ្មែរនៅបរទេស មកឱ្យខ្ញុំជាប្រចាំ រៀងរាល់ពេល ដែលកាសែតនេះចេញផ្សាយ មួយខែពីរដង ។

ឈ្មោះ និងអាសយដ្ឋានរបស់ខ្ញុំ :

ឈ្មោះ :............................................................................

អាសយដ្ឋាន :.....................................................................

.............................................................................U.S.A.

ទូរស័ព្ទ :..........................................................................

អ៊ីមែល :..........................................................................

ខ្ញុំផ្ញើរភ្ជាប់ជាមួយនូវ សែក ឬ មានីអដ័រ មក U.A.M.G ចំនួនមួយខែតម្លៃ ៥ ដុល្លារ ×........(ចំនួនមួយខែ)=..................

U.A.M.G 5730Rising Sun Avenue Philadelphia,PA 19120

**Phone : (215) 722-2226**


## (តមកទំព័រទី១៥) សង្គមស៊ីវិលជំរុញឱ្យកែទំរង់ច្បាប់...



លោក សម រង្ស៊ី ប្រធានគណបក្ស សម រង្ស៊ី

ពហិការមិនព្រមចូលរួមប្រជុំរដ្ឋសភានៅថ្ងៃខាងមុខ ល្គិកណាការដោះស្រាយពាក្យបណ្តឹងមិនទាន់ត្រូវបានបញ្ចប់នោះ ។

លោក សម រង្ស៊ី ប្រធានគណបក្ស សម រង្ស៊ី បានបញ្ជាក់ក្នុងកម្មវិធីភ្លើងទៀនថា មេឃុំ-ចៅសង្កាត់ និងស្មៀនឃុំនៅទូទាំងប្រទេសរបស់គណបក្សប្រជាជនកម្ពុជា និងប្រឈមមុខការផ្តន្ទាទោសចំពោះមុខច្បាប់ពីបទចេញទំរង់ ១០១៨ ឱ្យអ្នកគ្មានឈ្មោះក្នុងបញ្ជីបានបោះឆ្នោត ដោយក្លែងបន្លំ ។ បើតាមមាត្រា ទី៤៩ ពួកគេត្រូវជាប់គុក និងពិន័យជាប្រាក់ទៀតផង ។

លោក សម រង្ស៊ី បានបន្តថា ពេលនេះ គណបក្ស សម រង្ស៊ី បានទទួលពាក្យបណ្តឹងពីជនរងគ្រោះ ទំរង់១០១៨ រាប់សិប ដែលមេភូមិ-មេឃុំ ស្មៀនឃុំ បានឃុបឃិតជាមួយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត តាមឃុំ-សង្កាត់នៅថ្ងៃបោះឆ្នោត (២៧ ខែកក្កដា ២០០៨) យកទៅប្តឹង គ.ជ.ប ក្រុមប្រឹក្សាធម្មនុញ្ញ និងសហគមន៍ជាតិ-អន្តរជាតិ ទាំងក្នុង និងក្រៅប្រទេស ដើម្បីស្វែងរកយុត្តិធម៌ ជូនប្រជាពលរដ្ឋឱ្យមានសិទ្ធិបោះឆ្នោត និងសើរើការបោះឆ្នោតឡើងវិញតាមខេត្ត-ក្រុង ណាដែលមានភាពមិនប្រក្រតីច្រើននោះ ។

លោក សម រង្ស៊ី បានបញ្ជាក់ថា ស្មៀនឃុំ មេភូមិ និងមេឃុំ-ចៅសង្កាត់របស់គណបក្សប្រជាជនកម្ពុជាមួយចំនួនបានផ្តល់របាយការណ៍ និងសារភាពថា ខ្លួនបានប្រព្រឹត្តមែន ហើយលោកបានផ្តល់ប្រាក់ជាការលើកទឹកចិត្តពី៥០០ ទៅ១០០០ដុល្លារ តាមទំហំនៃសាច់រឿង ។ ភស្តុតាងទាំងនេះ វាគ្រប់គ្រាន់សំរាប់ការតវ៉ាទៅសហគមន៍អន្តរជាតិហើយ ។

ភាពមិនប្រក្រតីដែលគណបក្សប្រឆាំងរកឃើញសំរាប់ធ្វើការតវ៉ានេះ សង្គមស៊ីវិល មតិជាតិភាគច្រើនមិនសង្ឃឹមថា ទទួលបានយុត្តិធម៌នោះទេ ពីព្រោះស្ថាប័ន គ.ជ.ប មិនឯករាជ្យ លំអៀងទៅរកគណបក្សប្រជាជនកម្ពុជា និងស្ថាប័នផ្សេងៗទៀត ស្ថិតនៅក្រោមឥទ្ធិពលនយោបាយដែរ ។

ដូច្នេះ ដើម្បីឱ្យមានឯករាជ្យ បោះឆ្នោតដោយសេរី និងយុត្តិធម៌ ត្រូវតែកែប្រែស្ថាប័ន គ.ជ.ប ប្រព័ន្ធតុលាការ និងទទួលយកអនុសាសន៍របស់សម្ព័ន្ធអង្គការសង្គមស៊ីវិល ទើបពលរដ្ឋទទួលបានយុត្តិធម៌ និងអ្នកដឹកនាំដែលចេះគិតគូរពីប្រយោជន៍ជាតិពិតប្រាកដ ៕


**FreeLife**

*The Himalayan Goji Company®*




# the World's Most Powerful Anti-Aging Food

**ចំណីដែលទប់ទល់ជរាភាពដ៏ខ្លាំងជាងគេក្នុងលោក**

**គឺទឹកផ្លែឈើ "គោជី " នៃព្រៃហេមពាន្ត**

HIMALYAN GOJI
Juice



ការសម្ងាត់នៃសុខភាពល្អរបស់ពួកអាស៊ីបានត្រូវរកឃើញ នារជ្ជកាលស្តេចតាំងឆ្នាំ ៨០០ គ.ស ពលរដ្ឋនៃតំបន់មួយនៅព្រៃហេមពាន្តមិនព្រមចាស់-សក់ក៏មិនស-ធ្មេញក៏មិនបាក់-គេថា អ្នកស្រុកបានផឹកទឹកអណ្តូងមួយដែលមានដើម "គោជី "ដុះជុំវិញ គេស្មានថា មានវត្ថុសក្តិសិទ្ធអ្វីមួយជួយថែរក្សាពួកគេ ។ ទើបឥឡូវនេះ គេដឹកថា "គោជី " មានជីវជាតិពិសេសមួយឈ្មោះ POLYSACHARIDES ដែលពុំមាននៅផ្លែឈើឯណាទៀតសោះ ដែលជួយដល់ប្រព័ន្ធការពារខ្លួនរបស់មនុស្សបាន ។

បើចង់បាន Goji មកពិសារសូមជាវតាម www.forever.freelife.com

ឬក៏ទូរស័ព្ទលេខ : **(267) 253-3947**

SHARE THE SECRET

**TIME Magazine wrote :**

*" this year's breakout (Superfruit ) was the Himalayan Goji Berry, said to be a source of energy and longevity ".* To order, please visit the website at : **www.forever.freelife.com**

**Or please call (267) 253-3947 to order**

## (តមកពីទំព័រទី០១) អតីតមេគុកទួលស្លែងនឹងត្រូវឡើង...

ធ្វើការពិនិត្យជំនុំជំរះទោស ។

ការវិវត្តនៃសំនុំរឿងរបស់អតីតមេគុកទួលស្លែងនេះ វាជាដំណើរឆ្ពោះទៅរកយុត្តិធម៌សំរាប់



លោក ប្រាថ៏ន កុមារ អ្នកទេសចរណ៍ជនជាតិឥណ្ឌា កំពុងមើលគស្ពុតាងនៃជនរងគ្រោះ នៅគុកទួលស្លែងក្នុងរបបខ្មែរក្រហម



ជនរងគ្រោះ និងក្រុមគ្រួសារក្នុងរបបវាលពិឃាត ហើយអ្នកស្រាវជ្រាវរឿងខ្មែរក្រហម ក៏ដូចជាប្រជាពលរដ្ឋខ្មែរជំរុញឱ្យមានការកាត់ទោសមេដឹកនាំខ្មែរក្រហមឱ្យបានឆាប់ ។

លើសពីនេះ ពួកគេបានធ្វើការគាំទ្រឱ្យមានការកាត់ទោសមេដឹកនាំក្នុងរបបវាលខ្មែរក្រហមឱ្យបានឆាប់ ហើយសង្ឃឹមថា ពន្លឺយុត្តិធម៌នឹងផ្តល់ជូនជនរងគ្រោះជិតរកឃើញហើយ ដែលពួកគាត់ទន្ទឹងរង់ចាំរយៈពេលជិត៣០ឆ្នាំ ។

យោងតាមឯកសារនៅលើគេហទំព័រដែលសហចៅក្រម ម៉ាសែល ឡឺម៉ុង និងលោក យូ ប៊ុនឡេង បានបញ្ជាក់ថា កាំង ហ្កេចអ៊ាវ ហៅ ឌុច នេះជាអតីតអនុ ឬលេខាបក្សកុម្មុយនិស្តនៅមន្ទីរស.២១ ក្នុងរបបខ្មែរកម្ពុជាប្រជាធិប-តេយ្យ មានភស្តុតាងជាច្រើនដែលបានរៀបចំផែនការញុះញង់ឱ្យប្រព្រឹត្តិអំពើឧក្រិដ្ឋ គឺបានជួយ និងជំរុញដល់ចារីនៃបទឧក្រិដ្ឋទាំងនេះ ឬជាអ្នកទទួលទោស ក្នុងនាមជាមេកើយពីបទប្រឆាំងនឹងមនុស្សជាតិ និងបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ ។

ប្រភពឯកសារនោះបានបញ្ជាក់ថា យោងតាមវិធាន៧៦ និង៦៨នៃវិធានផ្ទៃក្នុងអ.វ.ត.ក សំរេចឱ្យចោទប្រកាន់ កាំង ហ្កេចអ៊ាវ ហៅ ឌុច និងបញ្ជូនទៅអង្គជំនុំជំរះសាលាដំបូង និងបន្តឃុំខ្លួនរហូតដល់បង្ហាញខ្លួននៅថ្ងៃបើកសវនការ ។ ក្នុងឯកសារនោះ គេបានរកឃើញមានជនរងគ្រោះប្រមាណជាងមួយម៉ឺននាក់ ដែលត្រូវបានធ្វើទារុណកម្ម និងសំលាប់នៅគុកទួលស្លែង ហើយកុមារមួយចំនួនដែលសំលាប់ ឌុច បានសារភាពថា មិនបានចុះឈ្មោះក្នុងបញ្ជីនោះទេ ។

លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា បានឱ្យអ្នកកាសែតដឹងថា ការដែលសហចៅក្រម សាលាក្តីខ្មែរក្រហមបញ្ជូនសំនុំរឿងរបស់ ឌុច ទៅសហចៅក្រមសាលាដំបូងនេះ វាជាដំណើរការមួយឆ្ពោះទៅក្តីសង្ឃឹមដែលពលរដ្ឋទន្ទឹងរង់ចាំជាយូរឆ្នាំមកហើយ ។

លោក ឆាំង យុ បានបន្តថា តាមរយៈការស៊ើបអង្កេតកន្លងមកវាបានឆ្លងកាត់នូវការលំបាកច្រើនណាស់ ទំរាំឈានទៅដល់ចំណុចត្រង់នេះ ហើយក្នុងនាមខ្ញុំសូមសំដែងនូវការគាំទ្រចំពោះការវិវត្តនេះ ។ ជាពិសេស លោកសូមស្នើដល់សហចៅក្រមទាំងខ្មែរ និងអន្តរជាតិ មេត្តាប្រឹងប្រែងរកយុត្តិធម៌ជូនជនរងគ្រោះឱ្យបានឆាប់ ។

លោក អ៊ុក សុន អាយុ៦៨ឆ្នាំ រស់នៅក្រុងភ្នំពេញ ដែលមានសាច់ញាតិស្លាប់ក្នុងរបបវាលពិឃាតនោះ បានសំដែងនូវការសាទរចំពោះដំណើរការកាត់ទោសរបស់មេដឹកនាំខ្មែរក្រហមដែលអង្គជំនុំជំរះវិសាមញ្ញក្នុងតុលាការកម្ពុជាកំពុងតែស្រាវជ្រាវស៊ើបអង្កេតនោះ ។

លោក អ៊ុក សុន បានបន្តថា លោកក៏មិនខុសប្លែកពីបងប្អូនខ្មែរទូទាំងប្រទេសនោះទេ គឺបានទន្ទឹងរង់ចាំយុត្តិធម៌អស់រយៈពេលជិត៣០ឆ្នាំមកហើយ ។ ចំណែកឯសាលាក្តីខ្មែរក្រហមក៏បានបង្កើតឡើងច្រើនឆ្នាំមកដែរ ប៉ុន្តែហាក់ដូចជាមានលក្ខណៈយឺតយូរ មិនមានការសង្ឃឹមទុកសោះ ។ (តទៅទំព័រទី១៨)

## (តមកពីទំព័រទី០៥) វង្វេងព្រោះស្នេហាជាតិ...

កាន់អំណាច "ប្រជាជនកម្ពុជា" ឆ្នោតលើសពីរភាគបី គឺជាសម្លេងសភាដ៏មានមហិទ្ធិឫទ្ធិ អាចឱ្យគណបក្ស នេះប្តូរស្ថាប័នទាំងអស់បាន ដោយស្របច្បាប់ ខែសីហា សៀមដកទ័ពនៅប្រាសាទព្រះវិហារ ដែលសៀមធ្លាប់ចាញ់ខ្មែរកាលពីឆ្នាំ ១៩៦២ ដោយតុលាការក្រុងឡាអេ តែពុំបានដកនៅតំបន់ផ្សេងៗទេ ហើយកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រី នឹងធ្វើទៅនៅថ្ងៃទី២៩ ខែសីហា នេះ ដើម្បីទាមទារឱ្យសៀមដកទ័ពជាបន្តទៅទៀត ។

ខ្មែរមានប្រៀបលើសៀម ក្នុងគោលការណ៍ដែលថា សៀមបានទទួលស្គាល់ដែនដីកម្ពុជាឆ្នាំ២០០៨ រួចហើយ គឺពុំមែនកំពូលភ្នំទេ ដែលចែកកម្ពុជា និងសៀមជាប្រទេសពីរនោះទេ ។ ការតវ៉ាដ៏គួរឱ្យសរសើរនេះ ក៏គួរតែកើតឡើងនៅផ្នែកខាងកើតនៃកម្ពុជាដែរ ជាមួយនិងយួន ។ តែក្រោយពីរជ្ជកាលលោក ប៉ែន សុវណ្ណ មក ពុំដែលលេចឮថា យួនយកដីខ្មែរពីរដ្ឋាភិបាលខ្មែរម្តងណាទេ ។ បន្ថែមពីលើនេះទៀត ពលរដ្ឋ ខ្មែរគ្រប់ស្រទាប់បានក្រោកឈរឆ្លើយតបនឹងទ័ពសៀម ជាមួយរដ្ឋាភិបាលខ្មែរ បង្ហាញពីទឹកចិត្តស្នេហាជាតិរបស់ខ្លួន ទាំងបក្សប្រឆាំង ក៏ដូចជាបក្សកាន់អំណាច ព្រឹត្តិការណ៍នេះបានសណ្តោសឱ្យទាហាន ប៉ូលិសកាន់កាំភ្លើងឱ្យស្ល៊ៀកពាក់ឯកសណ្ឋាន ហើយអាចគំរាមកំហែងដល់អ្នក បោះឆ្នោតប្រឆាំងនឹងបក្សកាន់អំណាចយ៉ាងឥត លាក់លៀម ។ ទឹកចិត្តស្នេហាជាតិរបស់ប្រជាជាតិ ផ្តាប់ទៅនឹងអ្នកការពារជាតិដែលគេពុំធ្លាប់ កោតសរសើរពីស្នាដៃរបស់ខ្លួន និងបង្កើតការខក ចិត្តដូចសព្វមួយដង តាំងពីជំនាន់រាជានិយមមុនគេ ។

ខ្មែរប៉ុស្តិ៍ នឹងតាមដានជាមួយលោក-អ្នកអាននៅលើផ្លូវដ៏វែង នៃដំណើររំដោះ "អធិប-តេយ្យ និងឯករាជ្យ" ភាពនៃកម្ពុជាថា ជាមួយឬគ្មានរដ្ឋាភិបាល "ការស្នេហាជាតិរហូតដល់វង្វេង គឺជាគ្រោះថ្នាក់មួយសំរាប់បុដ្ឋាកម្ពុជា ដែលគ្រប់ថ្នាក់ដឹកនាំតែងបំពុលប្រជាជាតិ ដើម្បីអំណាច បើទោះជាបានដោយថោកទាបក៏ដោយ ។

នៅសហរដ្ឋអាមេរិក គេតែងយកការកត់ត្រាគេហៅថា "វីឃើត" មកសំគាល់បុគ្គលថា មានដែលធ្វើអ្វីអាក្រក់ដែរឬទេ ដូច្នេះជាថ្មីម្តងទៀតដំណើរតាមអ្នកស្នេហាជាតិណាម្នាក់ ដែលពុំដែលមាន "វីឃើត" នៅឡើយទេ គឺយើងហ៊ានសរសើរដល់ទេពកោសល្យដ៏ខ្ពង់ខ្ពស់ នៃម្ចាស់ព្រឹត្តិការណ៍ដែលចេះប្រើ "ភាពវង្វេង" ចេះប្រើ "ពេលវេលា" និងប្រតិកម្មទាំងអស់ ឱ្យក្លាយជាប្រយោជន៍បក្សរបស់ខ្លួនឱ្យខាងតែបាននោះ គ្មានអ្វីខុសដោយចិត្តសប្បុរសទេ តែអ្នកនយោបាយពុំគួរប្រើប្រាស់មនោសញ្ចេតនាមហាជនឡើយ ៕


**New Golden Palace Restaurant**



801-21 Washington Ave
Phone: 215-627-2822

Open Daily from 10am-10pm
Dim Sum Every Day from 10am - 3pm

NEW GOLDEN PALACE RESTAURANT

**Authentic Chinese & Vietnamese Cuisine**
**Very Delicious and Nutritious**

-ហាងយើងមានម្ហូបចិន នឹងម្ហូបវៀតណាមពិតប្រាកដ មានរសជាតិឈ្ងុយឆ្ងាញ់ ហើយជីវជាតិប្រសើរ
**ពិសេសនៅពេលរាត្រី :** ចាប់ពីម៉ោង ៦ ល្ងាច ដល់បិតហាង ជូនភេសជ្ជៈពិសារដោយឥតគិតថ្លៃ (ពិសារយ៉ាងតិច **$20**)
**ពិសេសដោយម្ចាស់ហាង:** មានចុះតម្លៃ **10%** លើម្ហូបអាហារថ្ងៃត្រង់ ឬល្ងាច បើលោកអ្នកបង្ហាញប័ណ្ណពាណិជ្ជកម្មយើងដល់អ្នកគិតលុយ

**Nightly Special:** 6pm 'til Closing: FREE drinks with every meal ($20 minimum order)

**Manager Special:**
Take 10% off meal (Lunch & Dinner) when your present this advertisement

NEW GOLDEN PALACE
-10% OFF REAL
WITH PRESENTATION THIS ADVERTISEMENT

# ស្ពានអូរជីកជាទ្វារទឹកនៃការងារកសិកម្ម និងជាប្រព័ន្ធគមនាគមន៍ តាំងពីសម័យនគរ

***ឧត្តរមានជ័យ, ខ្មែរប៉ុស្តិ៍ : ម៉ី សម្ផស្ស***

●●●នៅសម័យមហានគរដ៏រុងរឿងព្រះមហាក្សត្របានអនុវត្តនយោបាយទឹក ដើម្បីលើកកំពស់ជីវភាពប្រជាពលរដ្ឋ និងធ្វើឱ្យប្រទេសជាតិមានការរីកចំរើនរុងរឿងដល់កំរិតកំពូលទៀតផង សូម្បីតែនៅបរិវេណសំណង់ប្រាសាទក៏មានតួទឹកស្រះ ឬកស្សិណដែរ ។

ក្នុងនោះគេសង្កេតឃើញស្ពានអូរជីកដែលមានប្រវែងប្រមាណ៣០០ម៉ែត្រ និងកំពស់ប្រមាណ១០ម៉ែត្រ ជីកតាំងពីសម័យបុរាណរហូតដល់បច្ចុប្បន្នក្លាយជាទ្វារទឹកសំរាប់តភ្ជាប់បណ្តាញប្រព័ន្ធធារាសាស្ត្រពី បឹង ទន្លេ ព្រែក អូរ ល្បើក បារាយណ៍ ដើម្បីជាប្រយោជន៍ដល់ការងារកសិកម្ម និងតភ្ជាប់ទៅប្រព័ន្ធគមនាគមន៍ ព្រមទាំងជាសំណង់ប្រវត្តិសាស្ត្រដ៏ធំអស្ចារ្យសំរាប់ទាក់ទាញភ្ញៀវទេសចរទៀតផង ។

ស្ពានអូរជីក ឬព្រៃជីកស្ថិតនៅឃុំជើងទាន ស្រុកចុងកាល់ ខេត្តឧត្តរមានជ័យ កសាងពីថ្មបាយក្រៀម នាសម័យមហានគរដ៏រុងរឿងនៅរឹងមាំដល់សព្វថ្ងៃ បើយើងធ្វើដំណើរមិនចាប់អារម្មណ៍ប្រាកដជាមិនដឹងថា ស្ពាននោះស្ថិតនៅត្រង់ណានោះទេ ។

ប៉ុន្តែតាមឯកសារខ្លះបញ្ជាក់ថា ស្ពានអូរជីកនោះកសាងក្នុងសម័យមហានគរ គឺមុនរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧ ដែលតំបន់នោះមានទឹកភ្លៀងជោគជាំខ្លាំងនារដូវវស្សា ធ្វើឱ្យលិចផ្លូវពិបាកក្នុងការធ្វើដំណើរឆ្លងកាត់លិចភូមិឋានដំណាំ កសិកម្មជាញឹកញាប់ ទើបកសាងស្ពាននេះឡើង ដើម្បីជាប្រយោជន៍កុំឱ្យស្ទះទឹកផង និងជាមធ្យោបាយតភ្ជាប់នៃប្រព័ន្ធគមនាគមន៍ទៅកាន់តំបន់នានាផង ។

បើយើងពិនិត្យតាមលក្ខខណ្ឌធម្មជាតិ តាមបណ្តោយព្រែកអូរជីកមានទឹកហូរធ្លាក់មកពីតំបន់ផ្សេងៗ ដូចជាតំបន់ភ្នំគូលែន ភូមិសាស្ត្រ ខេត្តសៀមរាប, ឧត្តរមានជ័យ បានហូរមកចាក់បំពេញព្រែកអូរជីក រួចហូរឆ្ពោះទៅបឹងទន្លេសាបដ៏ធំល្វឹងល្វើយ ដែលធ្វើឱ្យព្រែកនេះមានទឹកយ៉ាងច្រើនសន្ធឹកសន្ធាប់ សំរាប់ការងារស្រែចំការរបស់ប្រជាពលរដ្ឋ និងជួយឱ្យមានជីវភាពខ្ពស់ទៀតផង ។

ទាក់ទិននឹងព្រែកអូរជីកនេះ តាមអត្ថបទស្រាវជ្រាវរបស់លោក រុន សម្បត្តិ បានបញ្ជាក់ថា ព្រែកជីកនេះកសាងឡើងនៅមុនរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧ ព្រោះនៅក្នុងរាជរបស់ព្រះអង្គទ្រង់បានកសាងផ្លូវមួយខ្សែកាត់តាមខ្លោងទ្វារខាងត្បូងក្រុងអង្គរធំ ទៅទិសខាងកើតឆៀងខាងត្បូង សំដៅទៅខេត្តកំពង់ធំ មានបណ្តោយប្រវែង១៥០គីឡូម៉ែត្រ ដោយកាត់ទំនប់ ព្រៃជីកនេះជាពីរកំណាត់ នៅត្រង់ចំណុចថ្មល់ចែកនៃឃុំដំដែក ស្រុកសូត្រនិគមសព្វថ្ងៃ (បច្ចុប្បន្ននេះគឺជាកំណាត់មួយនៃផ្លូវជាតិលេខ៦) ។

ជាក់ស្តែងយើងឃើញមានបន្សល់ទុកនូវស្ពានបុរាណចំនួន១០ នៅតាមបណ្តោយកំណាត់ផ្លូវចាប់ពីកំពង់ក្តី (ព្រំប្រទល់ខេត្តកំពង់ធំ) មកខេត្តសៀមរាប ។ ប៉ុន្តែកាលពីទសវត្សរ៍ឆ្នាំ៧០ មានស្ពានដល់ទៅ២២ឯណោះ ហើយបាត់បង់ដោយសារតែការកសាង និងជួលជុលផ្លូវ ។ កាល



ស្ពានអូរជីកដែលកសាងពីថ្មបាយក្រៀមនៅសម័យមហានគរ

ដែលព្រះបាទជ័យវរ្ម័នទី៧ ទ្រង់សម្រេចព្រះទ័យបញ្ជាឱ្យគេកសាងផ្លូវ ដោយពុះកាត់ទទឹងព្រែកជីកនេះ ប្រហែលជាពេលនោះព្រែកជីកបានកកស្ទះ ឬក៏ឈប់ដំណើរការមិនអាចប្រើប្រាស់ទៀតកើត និងយល់ថា វាលែងមានសារប្រយោជន៍ក្នុងការប្រើប្រាស់ ទើបព្រះអង្គសម្រេចព្រះទ័យកសាងផ្លូវនេះឡើង ។

សព្វថ្ងៃនេះនៅមានទស្សនៈជាច្រើនដែលទាក់ទងទៅនឹងសារសំខាន់របស់ព្រែកជីកនេះ ដោយបានចោទសួរថា តើវាមានតួនាទីសំខាន់អ្វីខ្លះបានជាប្រជាជននៅសម័យបុរាណនាំគ្នាជីកព្រែកមានទំហំដល់ថ្នាក់នេះ ? ហើយគេប្រើប្រាស់វាសំរាប់ធ្វើអ្វី ?

អ្នកសិក្សាខ្លះបានបញ្ចេញគំនិតថា ព្រែកជីកនេះមានតួនាទីមិនត្រឹមតែបង្ហូរទឹកនៅរដូវវស្សាប៉ុណ្ណោះទេ គឺគេកសាងសំរាប់ដឹកជញ្ជូនថ្មពីអូរថ្មដាប់ (នៅបាតអូរនេះ យើងឃើញមានបន្សល់ទុកនូវស្លាកស្នាម ដែលអាចឱ្យយើងយល់បានថា កន្លែងនេះគឺជាការដ្ឋានសំរាប់យកថ្មមួយក្នុងចំណោមការដ្ឋានយកថ្មជាច្រើនកន្លែងទៀត នៅភ្នំគូលែន មានឈ្មោះថា អូរថ្មដាប់) ចុះមកក្រោមបណ្តោយព្រែកជីកនេះបន្តរហូតដល់បឹងទន្លេសាប ហើយបន្តមកកាន់តំបន់អង្គរ តាមដងស្ទឹងសៀមរាប ដើម្បីយកថ្មទាំងអស់នោះមកកសាងប្រាសាទ ។

ដោយហេតុថា ការដឹកជញ្ជូនតាមផ្លូវទឹកបែបនេះ វាមានភាពងាយស្រួលជាងការដឹកជញ្ជូនតាមមធ្យោបាយផ្សេងៗទៀត ណាមួយវាធូរកំលាំងច្រើនទៀតផង ។ ការដឹកជញ្ជូននេះ ប្រហែលជាធ្វើឡើងតាមរយៈក្បូន ឬតាមទូកនេះអាស្រ័យដោយពោះនៃព្រែកជីកនេះ មានទំហំធំសមល្មមនឹងធ្វើជាផ្លូវសំរាប់ដឹកជញ្ជូនបានផង ។

ទោះជាយ៉ាងណាក៏ដោយ ក៏សម្មតិកម្មនេះ គឺជាគំនិតមួយក្នុងការពិចារណារកហេតុផលដែរ ។ ប៉ុន្តែចំណុចដែលជាការកំណត់ជាក់ច្បាស់នេះ គឺវាមានតួនាទីមួយក្នុងការបង្ហូរទឹកនៅរដូវវស្សាពីតំបន់លើភ្នំគូលែនទៅបឹងទន្លេសាប ព្រោះបើយើងពិនិត្យមើលអំពីទីតាំងភូមិសាស្ត្រនៃតំបន់ភ្នំគូលែនឃើញថា វាមានកំពស់យ៉ាងខ្ពស់ ហើយសម្បូរទៅដោយព្រៃឈើក្រាស់ៗ ដែលនេះជារបាំងទឹកភ្លៀង និងជាប្រភពទាក់ទាញទឹកភ្លៀង ។

ចំណែកចាស់ទុំដែលចេះចាំពីប្រវត្តិសាស្ត្រអូរជីកនេះ បញ្ជាក់ថា ព្រែក និងស្ពាននេះមិនត្រឹមតែជាទ្វារសំរាប់បញ្ចេញបញ្ចូលទឹកក្នុងការងារកសិកម្មប៉ុណ្ណោះទេ តែក្នុងព្រែកនេះ មានថ្មល្អប្រណីតៗសំរាប់យកទៅកសាងសំណង់ប្រាសាទនានានៅតំបន់អង្គរ ក៏ដូចជាទូទាំងខេត្ត-ក្រុងកាលពីសម័យមុនមនុស្ស នាំគ្នាទៅជីកថ្មនៅទីនោះជញ្ជូនទៅកាន់ភូមិសាស្ត្រផ្សេងៗ ហើយវាជាប្រព័ន្ធផ្លូវទឹកដ៏សំខាន់ ទៀតផង ។

ក្រៅពីនេះទៀត នៅសម័យអាណានិគមបារាំង ក៏ដូចជាសម័យ ក្រោយៗដែរ ពួកអ្នកមានអំណាចមួយចំនួនបានសហការជាមួយឈ្មួញបានកាប់ឈើបណ្តែតនៅភូមិសាស្ត្រក្បែរៗនោះ តាមព្រែកជីកឆ្ពោះទៅតំបន់បឹងទន្លេសាប រួចបង្ហូសទៅប្រទេសជិតខាង ដើម្បីលក់បំរើផលប្រយោជន៍បុគ្គល ឬបក្ខពួករបស់ខ្លួន បណ្តាលឱ្យព្រៃឈើមួយភាគធំរងការបំផ្លិចបំផ្លាញយ៉ាងរង្គាល ។

នៅសម័យមហានគររុងរឿងគេសង្កេតឃើញមានសេសសល់ស្ពានបុរាណធំពីរ គឺស្ពានកំពង់ក្តីជាប់ព្រំប្រទល់ខេត្តកំពង់ធំ និងខេត្តសៀមរាប ស្ពាន អូរជីក ខេត្តឧត្តរមានជ័យ ដែលកំពុងតែទាក់ទាញភ្ញៀវទេសចរពីគ្រប់មជ្ឈដ្ឋាន ព្រមទាំងស្ពានតូចៗជាច្រើនទៀត នៅពាសពេញផ្ទៃប្រទេស ។



ទិដ្ឋភាពស្ពានអូរជីកមើលពីចម្ងាយដែលមានលក្ខណៈរឹងមាំនៅឡើយ

ចំណែកផ្លូវបុរាណមួយចំនួនគេសង្កេតឃើញប្រសព្វគ្នា នៅបរិវេណប្រាសាទបន្ទាយឆ្មារ ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ គឺផ្លូវមួយខ្សែឆ្ពោះទៅតំបន់ក្បាលទន្សោងជួរភ្នំដងរែក ឆ្លងកាត់ទៅប្រទេសថៃ មួយខ្សែទៀតឆ្ពោះមកទិសខាងកើតឆ្លងកាត់ភូមិសាស្ត្រស្រុកភ្នំស្រុក កាត់តាមខ្នងទំនប់អាងត្រពាំងថ្មឆ្ពោះទៅស្រុកចុងកាល់ ខេត្តឧតរមានជ័យ និងស្ពានអូរជីកឆ្ពោះទៅស្ពានកំពង់ក្តី ខេត្តកំពង់ធំ ។

ក្រៅពីស្ពាន និងផ្លូវថ្មល់ គេសង្កេតឃើញមានបារាយណ៍ ព្រែក ស្រះទឹក អណ្តូង ប្រព័ន្ធធារាសាស្ត្រជាច្រើនទៀត សំរាប់បំរើប្រយោជន៍ការងារកសិកម្ម ស្របតាមលក្ខខណ្ឌធម្មជាតិ ធ្វើឱ្យប្រទេសជាតិមានការរីកចំរើនរុងរឿងដល់កំពូលនាសម័យមហានគរ ៕


## ការិយាល័យមេធាវី លិនសេ្យ ដ៏រេង
## LAW OFFICE OF LINDSAY DOERING

**ទទួលការពារផលប្រយោជន៍លោកអ្នកករណីនានាតាមផ្លូវច្បាប់ដូចជា :**

- ករណីបើករបរពាណិជ្ជកម្ម នឹងផ្ទេរប្រាក់ក្នុងមុខជំនួញ
- ករណីទិញលក់អចលនវត្ថុ ដូចជា: ផ្ទះសំបែង ដីធ្លីជាដើម ។
- ករណីគ្រោះថ្នាក់រថយន្ត ឬគ្រោះថ្នាក់នៅកន្លែងធ្វើការ
- ករណីអន្តោប្រវេសន៍
- ឬករណីឧក្រិដ្ឋកម្ម ។ល។



**ធ្លាប់មានបទពិសោធន៍ខ្ពស់ ផ្តល់សេវាជូនតាមវិជ្ជាជីវៈ ហើយតម្លៃក៏សមរម្យទៀតផង យើងអាចមានអ្នកបកប្រែភាសាជូនលោកអ្នកបាន ៕**

General practice law office handling matters in :

Corporations and business transations
Read estate
Car Accidents
Work place injury
Immigration
Criminal fefense
Experienced, professional service and reasonable rate. translator available.

Office: (215) 667-8118 2301 Delancey place, Philadelphia PA 19103
Cell : (215) 840-1364 Email : lindsaydoering@yahoo.com

## (តមកពីទំព័រទី០៤) សិទ្ធិនៃការបញ្ចេញមតិរបស់...

ការពិតរិតតែផុះចេញ រិតតែឱ្យក្តៅក្រហាយ... ក៏ត្រឡប់ឱ្យឃើញមាន

ភាពភិរុទ្ធ គួរឱ្យសង្ស័យឡើងមកជាបន្តបន្ទាប់...

តែមុននឹងទៅដល់ក៏រិតថា តើអ្នកណានឹងត្រូវបានផលប្រយោជន៍ពីសម្បទានប្រេងឥន្ធនៈ និងឧស្ម័នធម្មជាតិនេះដែរឬអត់នោះ ក៏ត្រូវមកនិយាយគ្នាពីដើមហេតុដែលនាំឱ្យសៀម និងកម្ពុជា ម្នាក់ៗអាងសិទ្ធិលើផ្ទៃដីតែមួយក្នុងសមុទ្រថា មានប្រវត្តិមកយ៉ាងដូចម្តេច និងថា តើហេតុ


ប្រាសាទព្រះវិហារ និងប្រាសាទតាមាន់ ដែលសៀមឈ្លានពាន

អ្វីបានជាការចរចាគ្នាមិនបានទាល់តែសោះ ។

តើប្រវត្តិនៃការប្រកាសកម្មសិទ្ធិលើតំបន់មាត់សមុទ្រកើតឡើងក្រោយករណីភ្នំព្រះវិហារ ១០ឆ្នាំ ដោយកម្ពុជាប្រកាសតំបន់ខាងមាត់សមុទ្ររបស់ខ្លួននៅឆ្នាំ១៩៧២ និងសៀមក៏ប្រ-កាសទាញខ្សែបន្ទាត់ព្រំដែនសមុទ្ររបស់ខ្លួននៅឆ្នាំ១៩៧៣ ។

ការប្រកាសខ្សែបន្ទាត់ព្រំដែនសមុទ្រ បើប្រកាន់យកគោលការសាកល លើមូលដ្ឋានដូចគ្នា ក៏គ្មានរឿងរ៉ាវលំបាកតាមមកខាងក្រោយទេ តែនិយាយរឿងនេះក៏វែងឆ្ងាយស្រដៀងនឹងរឿងភ្នំព្រះវិហារ ព្រោះសៀម និងកម្ពុជា យកផែនទីម្នាក់ម្យ៉ាងមកអាង ដោយគ្មានអ្នកណាសុខចិត្តអ្នកណាទៀតផង ។ លទ្ធផល គឺទាំងសៀម និងកម្ពុជា ហាក់ដូចជានិយាយគ្នាបែបម្នាក់មួយរឿងជាមួយគ្នា អស់រយៈពេលជាង ៣០ឆ្នាំមកហើយ... ។

ចាប់ផ្តើមពីកម្ពុជា ដែលអាងផែនទីភ្ជាប់ចុងសន្ធិសញ្ញាស្តីពីការបោះព្រំដែនរវាង "ស្យាម" និង "ឥណ្ឌូចិន ឆ្នាំ១៩០៧ ដោយអូសខ្សែចេញពីគោលសីមាទី៧៣ ដែលនៅមាត់សមុទ្រចេញទៅប្រមាណ២៦៦អង្សា កាត់កំពូលខ្ពស់បំផុតរបស់កោះគូត ហើយចេញតទៅសមុទ្រ ។

កម្ពុជាអាងថា ផែនទីសង្ខេបភ្ជាប់នៅក្រោយសន្ធិសញ្ញា បញ្ជាក់នូវភាពត្រឹមត្រូវនៃខ្សែបន្ទាត់រវាងទឹកដីសៀម និងកម្ពុជា ។

ដោយហេតុនេះ ទើបកម្ពុជាវាយសេចក្តីថា ក្រោមខ្សែបន្ទាត់ដូចពោលមកនេះ ក្នុងសមុទ្រ គឺដែនដីខាងសមុទ្ររបស់កម្ពុជាក្នុងឈូងសមុទ្រសៀម ។

សូម្បីភាពពិតតាមផែនទីសង្ខេបដែលភ្ជាប់នៅចុងសន្ធិសញ្ញាប្រាប់ត្រឹមតែថា ខ្សែបន្ទាត់ដែលនិយាយមកនោះនឹងប្រើសំរាប់បញ្ជាក់ជាចំណុចដែនដីគោករវាងសៀម និងកម្ពុជាក៏ដោយ តែកម្ពុជាត្រឡប់ជាយល់ឃើញថា ខ្សែបន្ទាត់នេះអាចនាំមកប្រើសម្រួលគ្នាជាមួយនឹងការកំណត់ដែនទឹកសមុទ្របានភ្លាម ។

ពេលនេះសៀមចាប់ផ្តើមប្រកាសគូសកំណត់ដែនទឹកសមុទ្ររបស់ខ្លួន ក្រោយពីចូលជាភាគីអនុសញ្ញាក្រុងហ្សឺណែវ ស្តីពីច្បាប់សមុទ្រ កាលពីឆ្នាំ១៩៥៨ ដោយផ្តើមពីការប្រកាសព្រំដែនឈូងសមុទ្រសៀម ចាប់ផ្តើមតាំងពីបរិវេណភូមិឆង់សែមសារ រហូតដល់បរិវេណខាងជើងហួហ៊ិន កាលពីឆ្នាំ១៩៥៩ ។

ចំណែកឯខ្សែបន្ទាត់ដែលរត់តាមបណ្តោយឆ្នេរសមុទ្រដែលជាន់គ្នានឹងកម្ពុជា សៀមចាប់ផ្តើមត្រង់ព្រំដែនដីគោកត្រង់ចំណុចក្រោយបំផុតរវាងសៀម និងកម្ពុជា ត្រង់បរិវេណបង្គោលលេខ៧៣ តាមប្រកាសកំណត់ព្រំដែនសមុទ្រ កាលពីឆ្នាំ១៩៧៣ ។

ដោយចាប់យកចំណុចត្រង់ខ្សែបន្ទាត់បញ្ឈរលេខ១១.៣៩ និងខ្សែបន្ទាត់ផ្តេកលេខ១០២.៥៥ ជាចំណុចទី១ ហើយអូសបន្ទាត់ត្រង់ចេញពីចំណុចនេះទៅទិសខាងលិចឆៀងខាងត្បូង ក្នុងបែរិង២១១អង្សា ចេញទៅសមុទ្រទៅកាត់ជួបគ្នានឹងខ្សែមធ្យៈ ដែលអូសមកពីខាងត្បូងត្រង់ចំណុចទី២ បរិវេណឈូងសមុទ្រសៀម ។

ការប្រកាសខ្សែបន្ទាត់រត់តាមបណ្តោយទ្វីបរបស់សៀមក្នុងឈូងសមុទ្រ ជាផលចេញមកពីការប្រមូលរូបរួមទិន្នន័យ ពីសភាពភូមិសាស្ត្ររបស់ឈូងសមុទ្រសៀម ច្បាប់ក្នុងប្រទេស និងអនុសញ្ញាច្បាប់ស្តីពីសមុទ្រ ទើបចេញមកជាខ្សែបន្ទាត់រត់តាមបណ្តោយទ្វីបនេះបាន ។

ដែលគួរសង្កេតនោះ គឺសៀមក៏នៅមិនទាន់យល់ព្រមទទួលបង្គោលព្រំសីមាលេខ៧៣ ដែលជាផ្ទៃដីជាន់គ្នារវាងសៀម-កម្ពុជា ប្រមាណ ១០០ រ៉ៃ ព្រោះនៅមានបញ្ហាការបោះបង្គោល ព្រំសីមាដែលបាត់ទៅ ទើបប្រើច្បាប់អន្តរជាតិ ស្តីពីការបែងចែកព្រំដែនសមុទ្រ និងភូមិសាស្ត្រ ដែលមានចែងទុកជារង្វាស់ច្បាស់លាស់ជំនួសវិញ ។

តាមហេតុផលដូចពោលខាងលើ ទាំងសៀម និងខ្មែរ ម្នាក់ៗអាងសិទ្ធិដោយខ្លួន នឹងធ្វើឱ្យកើត ទៅជាផ្ទៃដីជាន់គ្នាប្រមាណ២៧,៩៦០ គីឡូម៉ែត្រក្រឡា ។

ឈ្មួនរបស់បញ្ហាដែល មិន អាចសម្របសម្រួលគ្នាបាននេះ បណ្តាលមកពីការប្រកាន់យកតាមគោលការណ៍នៃផែនទីម្នាក់ទៀត ។

ពោល គឺខាងកម្ពុជាប្រកាន់យកផែនទីដែលព្រះរាជាណាចក្រស្យាម-ឥណ្ឌូចិនរបស់បារាំងសែស ដែលធ្វើឡើងក្នុងយុគអាណានិគម និងនាំមកធ្វើជាព្រំដែនដោយតឹងរឹង។

នៅពេលដែលខាងសៀមវិញ ប្រកាន់យកគោលជំហរសាកល នៃអនុសញ្ញាសមុទ្រ ដែលមានវិជ្ជាការយោលដល់ និងវឌ្ឍនាការរហូតដល់មានការទទួលស្គាល់ជាសាកលច្រើនជាងផែនទី


ទាហានខ្មែរ និងទាហានសៀមកំពុងផ្តល់បទសម្ភាសន៍ជាមួយអ្នកសារព័ត៌មាន

របស់បារាំង ដែលធ្វើឡើងកាលពី១០០ ឆ្នាំមុន ដើម្បីជាកិច្ចព្រមព្រៀងគ្នាចំពោះតែព្រំដែនគោកប៉ុណ្ណោះ ។

ដូច្នេះហើយបានជាសៀម និងកម្ពុជាធ្លាក់នៅក្នុងគំនួចនៃការប្រទាញប្រទង់គ្នាដណ្តើមយករណ្តៅកំណប់ទ្រព្យក្នុងសមុទ្រតំបន់នោះ អស់រយៈពេល៣៦ឆ្នាំ មកហើយ ។

យ៉ាងណាក៏ដោយ ជាទីគួរឱ្យសង្កេតថា ពីដើមផ្ទៃដីជាន់គ្នានេះមានទំហំប្រមាណ៣៤,០៣៤ គីឡូម៉ែត្រក្រឡា ដែលផ្ទៃដីមួយភាគបានជាន់គ្នានឹងដែនដីសមុទ្ររបស់យួនផងដែរ ដោយផ្ទៃដីជាន់គ្នានោះមានទំហំប្រមាណ៦,០៥៧គីឡូ-ម៉ែត្រក្រឡា ។ តែក៏ឃើញថា ការចរចាបោះបង្គោលព្រំប្រទល់សីមានេះ បានឈានទៅមុខយ៉ាងឆាប់រហ័ស និងបានស្ងប់ស្ងាត់នៅចុងឆ្នាំ ១៩៩៤ ។

ការបែងចែកព្រំដែន បានយកកោះក្រចកសេះ (ពូលូវៃ) និង កោះប៉ានចាង (Panjang) ជាគោល ដោយអូសខ្សែចាប់តាំងពីចំណុចពាក់កណ្តាលខ្សែបន្ទាត់រវាងកោះទាំងពីរ ទៅកាត់ផ្ទៃដីដែលជាន់គ្នារបស់សៀម-កម្ពុជា-យួន រហូតធ្វើឱ្យផ្ទៃដីជាន់គ្នាជាមួយយួន លែងមានតទៅទៀតនៅទីបំផុត ។

រឿងដែលគួរឱ្យសង្កេតម្យ៉ាងទៀតនោះ គឺថាការបែងចែកផ្ទៃទឹកដែលជាន់គ្នារវាងប្រទេសទាំងបីបានប្រកាន់យក "គោលច្បាប់សាកល" ក្នុងការគូសខ្សែបន្ទាត់ព្រំដែនសមុទ្រមកប្រើគ្រប់ជ្រុងជ្រោយ ដោយគ្មានការចាប់យកផែនទីពីអតីតមកអាងសិទ្ធិរវាងគ្នានឹងគ្នាបានឡើយ ។

ផ្សេងគ្នាពីសៀម-កម្ពុជា ដែលនៅជាប់ស្ទះក្នុងរង្វង់នៃការប្រទាញប្រទង់ដណ្តើមគ្នាក្នុងអតីត ។

តែក្នុងរយៈពេល១០ឆ្នាំកន្លងមកនេះ ខាងកម្ពុជាចាប់ផ្តើមរមិលយល់ដល់គោលការណ៍ច្បាប់អន្តរជាតិច្រើនឡើងៗ និងអំពាវនាវឱ្យទាញខ្សែព្រំដែនសមុទ្រចេញពីកោះកណ្តាលសមុទ្រ ដើម្បីកំណត់ព្រំដែនជំនួស តែខាងសៀមក៏មើលឃើញថា យើងនឹងចាញ់ប្រៀប ព្រោះកោះរបស់កម្ពុជានៅឆ្ងាយពីច្រាំងសមុទ្រខ្លាំងជាសៀម ។

នេះ គឺគំនួចនៃការប្រទាញប្រទ ង់ដណ្តើមទាញខ្សែព្រំដែនសមុទ្ររវាងសៀម និងកម្ពុជា ដែលមានដើមហេតុមកពីមរតកបាប របស់មហាអំណាចបារាំងសែស ដែលបានមកកាន់ប្រទេសឥណ្ឌូចិន ដើម្បីស្វែងរកប្រទេសជាចំណុះ នឹងចាប់ផ្តើមមានការគូសខ្សែបន្ទាត់ព្រំដែន ដែលពីដើមមកមានការរស់នៅជារបៀបបងប្អូនមកជាយូរអង្វែង ។

១០០ឆ្នាំកន្លងមកនេះ មរតកបាបនៅតែមាន និងចេះតែខ្លាំងក្លាឡើងជាលំដាប់ រហូតអាចនឹងកើតជាសង្គ្រាមដណ្តើមសម្បត្តិធម្មជាតិគ្នាក្នុងអនាគតខាងមុខដ៏ខ្លីនេះ ៕

New World Travel II
ញូវលត្រាវែលធូ
Specialized in Selling Flight Tickets
For National and International
ជំនាញខាងលក់សំបុត្រយន្តហោះសំរាប់ក្នុង
ប្រទេស និងអន្តរជាតិ យើងតំណាងឱ្យក្រុមហ៊ុន ចិន កូរ៉េ កាថៃ ។ល។
ធ្វើលិខិត Re-Entry Permit ប្រញាប់ជូនបាន ទិញសំបុត្រជិះនាវាសមុទ្រ-
សណ្ឋាគារ ឬជួលឡាន សំបុត្រយន្តហោះទៅច្រើនប្រទេសក្នុងតម្លៃទាបបំផុត ។
Represented Several of Company such as China, Korea, Cathay etc.,
Offer Rush Re-Entry Permit
Reserve Cruise, Hotels and Car Rentals
Best Price Air Ticket for Many Destinations
600 Washington Ave Suite #8
Philadelphia, Pa 19147
Tel: (215) 463-1257
Fax: (215) 463-2036



# ហោរាសាស្ត្រប្រចាំខែ កញ្ញា ថ្ងៃទី ០៩_២៣



### ឆ្នាំជូត : (ពពួកទេព្តាប្រុស ធាតុទឹក)

រាសីលោកអ្នកខ្ពស់ត្រដែត ។ រាល់កិច្ចការងាររកស៊ីជួញដូរមានការរីកចម្រើនលូតលាស់ទៅមុខជាលំដាប់ ។ ក្នុងរយៈពេលនេះ ទោះជាលោកអ្នកបានប្រកបកិច្ចការងារអ្វីក៏ដោយ ក៏មានអ្នកជួយជ្រោមជ្រែងយ៉ាងពេញទំហឹងដែរ ។ ចំពោះស្ត្រីភេទនៅលីវ និងត្រូវបានកម្លោះៗចោមរោមស្រលាញ់ រហូតអាចឈានដល់ការស្តីដណ្តឹងយកធ្វើជាគូអនាគតទៀតផង ៕



### ឆ្នាំឆ្លូវ : ( ពពួកមនុស្សប្រុស ធាតុដី )

រាសីលោកអ្នកល្អមធ្យម ។ រាល់កិច្ចការងាររកស៊ីជួញដូរបានកាក់កបល្អគ្រាន់បើ ។ ក្នុងរយៈពេលនេះរាល់ឧបទ្រពចង្រៃ និងរាល់ឧបសគ្គត្រូវបានសាបរលាបជាបណ្តើរៗ ដូច្នេះលោកអ្នកអាចប្រកបកិច្ចការងាររកស៊ីបានពេញដៃពេញជើង ។ ចំពោះអ្នកជំនួញជួញដូរ បើមានប្រគល់ ឬទទួលនូវមុខទំនិញសព្វសារពើ ចូរចេះពិនិត្យគុណភាព និងរាប់ចំនួនឱ្យបានច្បាស់លាស់ ទើបពុំមានរឿងឆបោកកើតឡើង ៕



### ឆ្នាំខាល : ( ពពួកយក្សស្រី ធាតុឈើ )

រាសីលោកអ្នកស្រុតចុះខ្លាំង ។ រាល់កិច្ចការងាររកស៊ីជួញដូរជួបរឿងរកាំរកូសច្រើន ។ ក្នុងរយៈពេលនេះ បើមានរឿងឈ្លោះប្រកែកកើតឡើង ចូរចេះអត់ធ្មត់ និងរម្ងាប់ចិត្តឱ្យបានត្រជាក់ ដាច់ខាតមិនត្រូវតបតទាំងកំហឹងទល់នឹងកំហល់ឡើយ ទើបរឿងតូចមិនអាចក្លាយជារឿងធំបាន ។ ក្នុងរយៈពេលនេះ បើមានដំណើរទៅណាមកណា ចូរប្រយ័ត្នប្រយែងក្រែងជួបគ្រោះថ្នាក់ចរាចរ ៕



### ឆ្នាំថោះ : ( ពពួកមនុស្សស្រី ធាតុឈើ )

រាសីលោកអ្នកល្អជាមធ្យម ។ រាល់កិច្ចការងាររកស៊ីជួញដូរបានកាក់កបល្អគ្រាន់បើ ក្នុងរយៈពេលនេះ អ្វីដែលលោកអ្នកត្រូវយកចិត្តទុកដាក់នោះ គឺនៅតែមានមនុស្សខិលខូចខ្លះប៉ងបំផ្លិចបំផ្លាញរាល់កិច្ចការងារ ដូច្នេះមុននឹងធ្វើអ្វីមួយ ឬមុននឹងធ្វើដំណើរទៅណាមកណា ចូរមានស្មារតីប្រុងប្រយ័ត្នជាប់ជានិច្ច ។ ចំពោះគូស្នេហ៍ក្នុង រយៈពេលនេះមានការយល់ចិត្តគ្នាល្អ គ្មានបញ្ហាអ្វីកើតឡើងធំដុំទេ ៕



### ឆ្នាំរោង : (ពពួកទេព្តាប្រុស ធាតុមាស)

រាសីលោកអ្នកស្រុតចុះខ្លាំង ។ រាល់កិច្ចការងាររកស៊ីជួញដូរជួបរឿង រកាំរកូសច្រើន ។ ក្នុងរយៈពេលនេះ លោកអ្នកអាចផ្អាករាល់កិច្ចការងារសំខាន់ៗមួយរយៈពេលសិន ព្រោះបើហ៊ានតែមានចិត្តមានះរឹងរូស គឺពិតជាស៊ិយធំអាចបង់ខាតទ្រព្យជាក់ជាមិនខាន ។ ចំពោះស្ត្រីភេទក្នុងរយៈពេលនេះ មិនត្រូវដើរផ្លូវឆ្ងាយដាច់សង្វែងតែម្នាក់ឯងឡើយ ប្រយ័ត្នបានជួបគ្រោះភ័យ ៕



### ឆ្នាំម្សាញ់ : (ពពួកមនុស្សប្រុស ធាតុភ្លើង)

រាសីលោកអ្នកល្អជាមធ្យម ។ រាល់កិច្ចការងាររកស៊ីជួញដូរមានការរីកចម្រើនលូតលាស់ទៅមុខដោយសន្សឹមៗ ។ ក្នុងរយៈពេលនេះ ថ្វីត្បិតតែមានផលចំណូលហូរចូលបានច្រើនក្រាស់ក្រែលគួរសមក្តី តែពុំមានសល់អ្វីជាដុំកំភួនឡើយ ព្រោះចាយវាយខ្ជះខ្ជាយខ្លាំងពេក ។ ចំពោះគូស្នេហ៍ក្នុងរយៈពេលនេះ បើស្រលាញ់កុំទៅញឹក បើរពួកកុំទៅញយ ទើបចំណងស្នេហាអាចគង់វង្សបានយូរអង្វែង ៕



### ឆ្នាំមមី : (ពពួកទេព្តាស្រី ធាតុភ្លើង)

រាសីលោកអ្នកស្រុតចុះខ្លាំង ។ រាល់កិច្ចការងាររកស៊ីជួញដូរជួបនឹងបញ្ហាលំបាកៗច្រើន ។ ក្នុងរយៈពេលនេះ ទោះជាលោកអ្នកបានប្រកបកិច្ចការងារអ្វីក៏ដោយ ចូរកុំមានការធ្វេសប្រហែសឱ្យសោះ ជាពិសេសចំពោះអាជីវករអ្នករកស៊ីប្តូរប្រាក់ ឬលក់គ្រឿងអលង្ការមានតម្លៃផ្សេងៗ ត្រូវប្រយ័ត្នប្រយែងមានជនខិលខូចលួចបន្លំ ឬឆក់ប្លន់ ៕



### ឆ្នាំមមែ : (ពពួកទេព្តាស្រី ធាតុមាស)

រាសីលោកអ្នកឡើងខ្ពស់ត្រដែត ។ រាល់កិច្ចការងាររកស៊ីជួញដូរបានកាក់កបល្អណាស់ ។ ក្នុងរយៈពេលនេះ ទោះជាលោកអ្នកបានប្រកបកិច្ចការងារអ្វីក៏ដោយ ក៏អាចទទួលបានផលសម្រេចសមតាមបំណងប្រាថ្នាទាំងអស់ ។ បើជាអាជីវករ អ្នករកស៊ីជួញដូរ នឹងមានទំនិញលក់ចេញទិញចូលឥតទំនេរដៃ ព្រមទាំងមានទ្រព្យហូរចូលជាហូរហែទៀតផង ៕



### ឆ្នាំវក : (ពពួកយក្សប្រុស ធាតុដែក)

រាសីលោកអ្នកល្អជាមធ្យម ។ រាល់កិច្ចការងាររកស៊ីជួញដូរមានការរីកចម្រើនលូតលាស់ទៅមុខដោយសន្សឹមៗ ។ ក្នុងរយៈពេលនេះ ទោះជាលោកអ្នកបានប្រកបកិច្ចការងារអ្វីក៏ដោយ ត្រូវមានស្មារតីប្រុងប្រយ័ត្នជាប់ជានិច្ច ជាពិសេសមុននឹងចុះហត្ថលេខា ឬផ្តិតស្នាមមេដៃផ្សេងៗ ចូរចេះពិនិត្យពិច័យឱ្យបានល្អិតល្អន់ ព្រោះកាលបើមានការភ្លាំងភ្លាត់តែបន្តិច អាចបង់ខាតផលប្រយោជន៍ច្រើន ៕



### ឆ្នាំរកា : (ពពួកយក្សប្រុស ធាតុដែក)

រាសីលោកអ្នកខ្ពស់ត្រដែត ។ រាល់កិច្ចការងាររកស៊ីជួញដូរមានការរីកចម្រើនលូតលាស់ទៅមុខជាលំដាប់ ។ ក្នុងរយៈពេលនេះ ឱកាសល្អៗបានមកដល់ហើយ ដូច្នេះលោកអ្នកត្រូវតែរវៀសរវៃញាប់ជើងញាប់ដៃបន្តិច ព្រោះពេលវេលាជាមាសប្រាក់ធ្វើច្រើនបានច្រើន ។ ចំពោះគូស្នេហ៍ក្នុងរយៈខែនេះ មានភាពស្និទ្ធស្នាលដូចប្រក្រតី ៕



### ឆ្នាំច : ( ពពួកយក្សស្រី ធាតុដី )

រាសីលោកអ្នកឡើងខ្ពស់ត្រដែត ។ រាល់កិច្ចការងាររកស៊ីជួញដូរបានកាក់កបល្អណាស់ ។ ក្នុងរយៈពេលនេះ លោកអ្នកមានអារម្មណ៍ភ្លឺថ្លា គំនិត ប្រាជ្ញាឈ្លាសវៃ ទោះប្រកបកិច្ចការងារអ្វីៗក៏ដោយ ក៏អាចទទួលបានផលសម្រេចសមតាមបំណងប្រាថ្នាទាំងអស់ ។ ចំពោះស្វាមីភរិយាវិញ មានភាពល្អកល្អឺនគ្នាណាស់ ហើយពិសេស នោះស្រលាញ់គ្នាលើសមុនទៅទៀត ៕



### ឆ្នាំកុរ : (ពពួកមនុស្សស្រី ធាតុទឹក)

រាសីលោកអ្នកល្អជាមធ្យម ។ រាល់កិច្ចការងាររកស៊ីជួញដូរមានការរីកចម្រើនលូតលាស់ទៅមុខដោយសន្សឹមៗ ។ ក្នុងរយៈពេលនេះ បើជាបុគ្គលិក កម្មករដែលបំរើការងារនៅតាមក្រុមហ៊ុន ឬរោងចក្រនានា ចូរចេះដាក់ខ្លួនដាក់កាយ និងចេះធ្វើទំនាក់ទំនងល្អជាមួយនឹងចៅហ្វាយនាយ ឬចៅកែ ព្រមទាំងអ្នករួមការងារជាមួយ ទើបកិច្ចការងារអាចដំណើរការបានស្រួល ៕


## Buy something... Sell something...Announce something...advertise on the Khmer Post Classifieds!

**រកផ្ទះជួល**

យើងត្រូវការផ្ទះមានពីរ ឬបីបន្ទប់គេង នៅតំបន់ខាងជើងហ្វីឡាដែលហ្វៀ សូមទំនាក់ទំនងមកសុបិន : **(267) 253-3947**

**Your Advertisement Is Here For Less than $10 for two weeks!**

South Philadelphia Library, 1700 S. Broad St.
**ESL classes,** Tuesdays & Thursdays 12:30-3:00 p.m.

**Books and DVDs in Khmer language**
South Philadelphia Branch, 1700 S .Broad St.
Whitman Branch, 200 Snyder Ave.
Greater Olney Branch, 5501 N. 5th St.
Wyoming Branch, 231 E. Wyoming Ave.

**Service**
C.C. Building Services
Metropolitan Area



C.C. BUILDING SERVICES
COMMERCIAL & RESIDENTIAL CLEANING
CHEA CHHAY
PRESIDENT
50 NUGENT DRIVE
STAFFORD, VIRGINIA 22554
PHONE: (540) 720-4696
FAX: (540) 720-4697
CELL: (703) 606-9010

**រដ្ឋសង $500-650 តាក់ លើសម្បត្តិ**

ចំពោះម្ចាស់ផ្ទះ ឬអ្នកជួលផ្ទះ ដែលមានអាយុ +៦៥ -មេម៉ាយ ឬពោះម៉ាយ +៥០ -មនុស្សពិការ +១៨ ឆ្នាំ ហើយមានប្រាក់ចំណូលចន្លោះ ១៥.០០០-៣៥.០០០-អាចទាមទារប្រាក់នោះបាន រហូតដល់ថ្ងៃ ៣១ធ្នូ ០៨.

សូមហៅទៅ **(215) 467-0690** SEAMAAC

**រកមនុស្សធ្វើការច្រើនគ្នា**

ធ្វើជាអ្នកជំនួយដល់មនុស្សពិការនៅជុំវិញ Philadelphia

THIG ទូរស័ព្ទ : **215 320 2040** WEBSITE : www.taigine.org

ការងារល្អត្រឹមត្រូវ មាន BENEFIC មានសវិស្សមកាល...

## Clip & Fax This Classified Coupon

Classified Advertising
Name your category: Sales, Services, Fund Raisers…etc.
Our rates: $5.00 for up to 21 words
15 cents each additional words
Send us your ad in one of the following ways:
1. by Fax to (215) 722-2226
2-by mail to the Khmer Post 5730 Rising Sun Avenue. Philadelphia, Pa 19120 3-By phone (267) 253-3947
Payments methods: cash or checks.
Name:________ Address: ________
City____________
State ________ Zip__________
Phone: ______ Fax__________
Your Advertisement Message:
______________________
______________________
______________________


LOVE
JOY
PARDON
NEW YEAR BABY
Buy now on DVD
award winning film about a Cambodian American family's story
www.NewYearBaby.net
Phone Order: 877-345-6222
Find out more about Socheata Poeuv's organization Khmer Legacies:
www.KhmerLegacies.org
www.NewYearBaby.net (877) 345-6222
www.KhmerLegacies.org


PKAY PREK VIDEO
(215) 455-2762
4935 OLD YORK RD. PHILADELPHIA, PA 19141
MOVIE RENTAL
DVD & CD SALES
CAMBODIAN FORMAL DRESSES
WOMEN & BABY CASUAL WEARS


Since 1997
LOW FARE TRAVEL, INC.
Domestic & International
OFFICE IN THE UNITED STATES
CALIFORNIA-FLORIA-ILLINIOS-N.COROLINA-MASSACHUSET
1800 s. 15TH Street. Philadelphia, Pa 19145 USA
Special offers to Cambodia/Lao, Thai, & Vietnam:
• China
• Eva
• All Nippon
• Korean
• Singapore
• Thai
• Northwest
• Cathay
• Asiana
• Japan
To book a reservation call @
PHONE 215-462-0886/CELL 215-833-3669
OFFICE HOURS:
Monday-Friday/4-8/PM/EST
Saturday-Sunday/10-4/PM/EST
We're accepted all methods of payment. We're very proud to serve you for the last 11 years, and your business with is highly appreciated.


Nationwide
Insurance & Financial Service
We offer Cheap Price for Every Client
Business Liability Insurance
Home Insurance
Health Insurance
Auto Insurance
Life Insurance
Discount 30% when you purchase
Home & Auto Insurance
ចុះតម្លៃ ៣០ % បន្ថែមបើលោកអ្នកទិញ
ធានារ៉ាប់រង ផ្ទះ និងរថយន្តរួមគ្នា
South Philadelphia office:
600 Washington Ave Suite #8
Philadelphia, Pa 19147
Tel: (215) 463-1257
Fax: (215) 463-2036
North Philadelphia office:
6603 Bustleton Ave.
Philadelphia, Pa 19149
Tel: (215) 335-2140
Fax: (215) 335-2147


TIPSY
BAR & LOUNGE
Live D.J. every Fri & Sat night from 9 p.m. - 2 p.m.
(pool table)
Ralph Rinn
Tel: 215.305.5763
Cell: 267.968.3413
Michael Lay (General Manager)
215.409.4772
Email: tipsybar@gmail.com
Sun-Thu: 10 - 12 a.m.
Fri & Sat: 10 - 2 a.m.
Kitchen Open Daily
Sun-Sat: 10 - 11 p.m.
3904 Frankford Ave.
Philadelphia, Pa 19124

